## មេរៀន ធម៌

# ជំនួយសតិ

## ភាគទី ១


រៀបរៀងដោយ

ខ្ញុំព្រះករុណា

ខ្ញុំបាទ **ប៊ុត សាវង្ស**

មេរៀន ធម៌

# ជំនួយសតិ

ភាគទី ១

រៀបរៀងដោយ

ខ្ញុំព្រះករុណា

ខ្ញុំបាទ ប៊ុត សាវង្ស

ហាមលក់

៥០០០ឆ្នាំ

WWW.5000-YEARS.ORG



ឯកសារនេះបាន ទាញចេញពី គេហទំព័រ

www.5000-years.org

មេរៀន ធម៌

# វិនយសតិ

រៀបរៀងដោយ

ខ្ញុំព្រះករុណា

ខ្ញុំបាទ **ប៊ុត សាវង្ស**

# ទស្សនៈផ្ទាល់

អត្ថបទធម៌ « **ជំនួយសតិ** » នេះសំខាន់ណាស់ពីព្រោះ :

១ - ពោលអំពីតិកមាតិកា ២២ ក្នុងគម្ពីរ **អភិធម្ម ធម្មសង្គណី** គ្រប់សព្វ ព្រមទាំងមានអត្ថាធិប្បាយ ពន្យល់ខ្លះៗផង ។

២ - អត្ថបទនេះ នឹងបានជាឯកសារដ៏សំខាន់សំរាប់កុលបុត្រ អ្នកសិក្សាគម្ពីរ **ព្រះអភិធម្ម** ពេលណា ដែលត្រូវការស្រាវជ្រាវរក ខ្លឹមសារពិតប្រាកដ ។

៣ - ជាជំនួយស្មារតី ចំពោះអ្នកមានឆន្ទៈប្រាថ្នាសិក្សាចេះចាំ - យល់ដឹង នូវអត្ថនិងសភាវៈរបស់ព្រះអភិធម្ម ។

៤ - អត្ថបទនេះ មានន័យចាត់ទុកថា ជា

សង្ខេបនាមួយយ៉ាងតូច ផ្នែកគម្ពីរ **ព្រះអភិធម្ម** ពីព្រោះកម្ររកលោកអាចារ្យណា មានសមត្ថភាពចេះដឹងចាក់ធ្លុះមោះមុតនូវសភាវធម៌ និពន្ធចងក្រងឡើងណាស់ ។

អាត្មាភាព **សម្តេចព្រះមង្គលទេពាចារ្យ** សូមកោតសរសើរចំពោះឆន្ទះ វិរិយះ ចិត្តះ វិមំសា របស់លោកគ្រូធម្មាចារ្យ **ម៉ុត សាវង្ស** ដែល ជំរុញអោយកើតចេញជាអត្ថបទជំនួយសតិនេះឡើង ។

អត្ថបទនេះ គួរពួកពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋានយកចិត្តទុកដាក់រៀនសូត្រ អោយចេះចាំ គិតអោយយល់គ្រប់តិកៈមាតិកានីមួយៗ ហើយរក្សាទុកជា ឯកសារ កុំអោយបាត់របាត់តទៅ ! ។

*ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៦*

ហត្ថលេខា

**អ៊ុម ស៊ុម** សង្ឃត្ថេរោ

# មាតិកាធម៌


| លេខរៀង | | ឈ្មោះធម៌ | ទំព័រ |
|---|---|---|---|
| ១ | : | តិកមាតិកាទី ១ | ១ |
| ២ | : | តិកមាតិកាទី ២ | ១៤ |
| ៣ | : | តិកមាតិកាទី ៣ | ១៨ |
| ៤ | : | តិកមាតិកាទី ៤ | ៣១ |
| ៥ | : | តិកមាតិកាទី ៥ | ៣៩ |
| ៦ | : | តិកមាតិកាទី ៦ | ៥១ |
| ៧ | : | តិកមាតិកាទី ៧ | ៦០ |
| ៨ | : | តិកមាតិកាទី ៨ | ៦៦ |
| ៩ | : | តិកមាតិកាទី ៩ | ៧៣ |
| ១០ | : | តិកមាតិកាទី ១០ | ៧៨ |
| ១១ | : | តិកមាតិកាទី ១១ | ៨៦ |
| ១២ | : | តិកមាតិកាទី ១២ | ៩២ |
| ១៣ | : | តិកមាតិកាទី ១៣ | ៩៨ |
| ១៤ | : | តិកមាតិកាទី ១៤ | ១០១ |
| ១៥ | : | តិកមាតិកាទី ១៥ | ១០៤ |
| ១៦ | : | តិកមាតិកាទី ១៦ | ១០៨ |
| ១៧ | : | តិកមាតិកាទី ១៧ | ១១៦ |
| ១៨ | : | តិកមាតិកាទី ១៨ | ១២០ |
| ១៩ | : | តិកមាតិកាទី ១៩ | ១២៤ |
| ២០ | : | តិកមាតិកាទី ២០ | ១៣១ |
| ២១ | : | តិកមាតិកាទី ២១ | ១៣៣ |
| ២២ | : | តិកមាតិកាទី ២២ | ១៣៨ |

# តិកមាតិកា

## ១ _ តិកមាតិកាទី ១

### ១. កុសលា ធម្មា

ពួកធម៌ជាកុសល បានដល់កុសលចិត្ត ៣៧ ចេតសិក ៣៨

**កុសលចិត្ត ៣៧ គឺ ÷**

- កាមាវចរកុសលចិត្ត ៨
- រូបាវចរកុសលចិត្ត ៥
- អរូបាវចរកុសលចិត្ត ៤
- លោកុត្តរកុសលចិត្ត ២០

* ក្នុងចិត្តនិមួយៗតែងមាន ចេតសិកកើតរួមជាមួយៗ

## ចេតសិក ៣៨ គឺ ៖

- អញ្ញសមានាចេតសិក ១៣
- សោភណចេតសិក ២៥

## អដ្ឋកថា អដ្ឋសាលិនី

* សភាវដែលឈ្មោះថាកុសល ព្រោះអត្ថថា ញុំាង បាបធម៌ដែលបណ្ឌិតខ្ពើមអោយវិនាស **ធម្មា** នៅក្នុងតិកមាតិកានិងទុកមាតិកា ២៦៦ ធម្មាដោយអត្ថថា មិនមែនសត្វ មិនមែនអត្តា សូន្យចាកខ្លួន ឬសូន្យចាកវត្ថុជារបស់ខ្លួន ។

### ចែកជាខន្ធ ៤

* ចំពោះចេតសិក ៣៨ ជាខន្ធ ៣
- វេទនាចេតសិកជាវេទនាខន្ធ

- សញ្ញាចេតសិកជាសញ្ញាខន្ធ

- ចេតសិក ៣៦ ជាសង្ខារក្ខន្ធ

កុសលចិត្ត ៣៧ ជាវិញ្ញាណក្ខន្ធ

**សតិប្បដ្ឋាន**

កុសលធម៌ទាំងឡាយមិនមែននៅក្នុងសៀវភៅទេ តែគឺនៅក្នុងជីវិតប្រចាំថ្ងៃ ជាទីតាំងនៃសតិរលឹកត្រង់លក្ខណៈនៃសភាវដែលកំពុងប្រាកដ ទើបបញ្ញាឃើញថា ជាធម្ម : ពិត១ ។

## ចែកជាអាយតន ២

* កុសលចិត្ត ៣៧ ជាមនាយតនៈ

ចេតសិក ៣៨ ជា ធម្មាយតនៈ

**សតិប្បដ្ឋាន**

ធម៌ទាំងឡាយកើតឡើងព្រោះអាស្រ័យហេតុបច្ច័យ បើយល់ឃើញថាខ្លួនយើងជាអ្នកធ្វើនូវកុសលធម៌ ចុះម៉េចបានជាមានអកុសលធម៌កើតឡើងដែរ

តាមពិតបច្ច័យដែលញ៉ាំងកុសលធម៌អោយកើតឡើង នោះ ពុំមែនជាតួខ្លួនយើងឡើយ ។

## ចែកជាធាតុ ២

* កុសលចិត្ត ៣៧ ជាមនោវិញ្ញាណធាតុ

ចេតសិក ៣៨ ជាធម្មធាតុ ។

## សតិប្បដ្ឋាន

កុសលធម៌ទាំងឡាយគ្រាន់តែជាធាតុប៉ុណ្ណោះ បុគ្គលដោយច្រើនតែងយល់ឃើញថា ជារបស់ខ្លួន ព្រោះខ្លួនជាអ្នកធ្វើ សូមសួរថាទុក្ខវេទនាមានឈឺក្បាលឬឈឺពោះជាដើម តើខ្លួនយើងជាអ្នកធ្វើដែរឬទេ? តាមពិតសង្ខារធម៌ស្រេចនៅលើបច្ច័យ

## ចែកជាសច្ចៈ ២ និង សច្ចវិមុត្តិ

* លោកិយកុសលចិត្ត ១៧ គឺ :

- កាមាវចរកុសលចិត្ត ៨ រូបាវចរកុសលចិត្ត ៥ និង អរូបាវចរកុសលចិត្ត ៤

ចេតសិកសម្បយុត្ត ៣៨ :

កុសលធម៌ត្រឹមប៉ុណ្ណោះជាទុក្ខសច្ចៈ

* ចេតសិកជាអង្គអរិយមគ្គ ៨ គឺ

១ - បញ្ញាចេតសិក ជា សម្មាទិដ្ឋិ

២ - វិតក្កចេតសិក ជា សម្មាសង្កប្បៈ

| | | |
|---|---|---|
| ៣ | | សម្មាវាចា |
| ៤ | វិរតិចេតសិក ៣ ជា | សម្មាកម្មន្តោ |
| ៥ | | សម្មាអាជីវោ |

៦ - វិរិយចេតសិក ជា សម្មាវាយាមោ

៧ - សតិចេតសិក ជា សម្មាសតិ

៨ - ឯកគ្គតាចេតសិកជាសម្មាសមាធិ

លោកុត្តរចេតសិក ៨ នេះជាមគ្គសច្ចៈ

ចំណែកកុសលធម៌ដែលនៅសល់គឺ ÷ លោកុត្តរចិត្ត ២០ ចេតសិក ២៨ ( វៀរមគ្គចេតសិក ៨ ) ជា

សច្ចវិមុត្តិ

* សច្ចវិមុត្តិគឺជាអង្គធម៌បរមត្ថដែលមិនមែនជាអរិយសច្ចធម៌ណាមួយក្នុង អរិយសច្ចធម៌ទាំង ៤ គឺ ផុតចាកអំពីអរិយសច្ចធម៌ ។

## ២ - អកុសលា ធម្មា

ពួកធម៌ជា អកុសល បានដល់អកុសលចិត្ត ១២ និង ចេតសិក ២៧ ។

### អកុសលចិត្ត ១២ គឺ ÷

- លោភមូលចិត្ត ៨
- ទោសមូលចិត្ត ២
- មោហមូលចិត្ត ២

### ចេតសិកសម្បយុត្ត ២៧ គឺ ÷

- អញ្ញសមានាចេតសិក ១៣
- អកុសលចេតសិក ១៤

## អដ្ឋកថា អដ្ឋសាលិនី

ធម្មដែលឈ្មោះថា អកុសល ព្រោះអត្ថថា មិនមែនកុសលអធិប្បាយថា ធម៌ដែលជាបដិប័ក្ខចំពោះកុសល ដូចអមិត្តជាបដិប័ក្ខដល់មិត្ត ។

**ចែកជាខន្ធ ៤**

- វេទនាចេតសិក ជា វេទនាខន្ធ
- សញ្ញាចេតសិកជាសញ្ញាខន្ធ
- ចេតសិក ២៥ ជាសង្ខារក្ខន្ធ

អកុសលចិត្ត ១២ គឺជាវិញ្ញាណក្ខន្ធ

**សតិប្បដ្ឋានវិបស្សនា**

បុគ្គលទាំងឡាយតែងស្វែងរកនូវវត្ថុដែលជាទីប្រាថ្នា ជាទីស្រឡាញ់ពេញចិត្ត កាលដែលស្វែងរកក៏បានតាមសេចក្ដីប្រាថ្នា ហើយក៏ត្រេកអររីករាយ ។ ដូច្នេះការស្វែងរកយ៉ាងនេះ ស្ទើរអស់ពេលវេលាយូរ

ឬឆាប់ប៉ុណ្ណាក៏ដោយ ទីបំផុតក៏ត្រូវបានជួបប្រទះនូវកាមតណ្ហាក្នុងលក្ខណៈដែលថា ៖ «នោះជារបស់អញ» លោភធម៌ជាធម៌ពិតក្នុងជីវិតប្រចាំថ្ងៃ ជាធម៌ដែលមានហេតុបច្ច័យនាំអោយកើត ។ លោភធម៌ដែលគ្របសង្កត់ចិត្តនាំអោយមានការប្រព្រឹត្តនូវទុច្ចរិត ព្រោះវង្វេងភ្លេចសតិ ហើយប្រកាន់ធម៌លោភៈថាជាតួខ្លួនឯង។ សតិប្បដ្ឋានបដិបត្តិ គឺសតិមានការរលឹកត្រង់លក្ខណៈនៃលោភធម៌ បញ្ញាឃើញតួលោភៈជាសភាវធម៌ពិតៗ « ដែលមិនមែនជាតួខ្លួនឯងឡើយ » ។

## អកុសលធម៌ ជា អាយតន ២

* អកុសលចិត្ត ១២ ជាមនាយតនៈ

ចេតសិកទាំង ២៧ ជាធម្មាយតនៈ

## សតិប្បដ្ឋាន

ការបាននូវវត្ថុជាទីពេញចិត្តមិនមានបានអ្វីក្រៅអំពីការបានបន្ថែមនូវសេចក្តីពេញចិត្តនោះ ហើយដែល

ពិតប្រាកដណាស់ គឺព្រាត់ប្រាសចាកចោលនូវវត្ថុនោះទៅវិញ ព្រោះថា នុ៎ះជារបស់អញ គឺជាការយល់ច្រឡំទេ ។

## ធាតុ ២

* អកុសលចិត្ត ១២ ជាមនោវិញ្ញាណធាតុ

ចេតសិក ២៧ ជា ធម្មធាតុ ។

## សតិប្បដ្ឋាន

* ការស្វែងរកកាមដូចជាបុគ្គលដើរហាលថ្ងៃក្តៅហើយស្រេកទឹក ការបានជួបប្រទះនូវកាមដូចបុគ្គលស្រេកទឹក ហើយបាននូវទឹកអំបិលផឹក គឺវានាំអោយរឹតតែស្រេកឃ្លានខ្លាំងឡើងទៀត ដូច្នេះការមិនស្រេកឃ្លានក្នុងកាម « គឺការប្រព្រឹត្តព្រហ្មចរិយធម៌ » ។

## សច្ចធម៌ ២

* អកុសលចិត្ត ១២ និងចេតសិក ២៦ ( វៀរលោភចេតសិក ) អកុសលធម៌ប៉ុណ្ណោះជា ទុក្ខសច្ចៈ ។

- លោភចេតសិកជាសមុទយសច្ចៈ

## សតិប្បដ្ឋាន

* បើយើងចង់បានរបស់អ្វីមួយ ដើម្បីអោយបានរបស់នោះពិតប្រាកដអោយគ្រប់គ្រាន់ផង គឺការឈប់ចង់បានហ្នឹងឯង ព្រោះបើមិនចង់បានហើយអ្វីដែលចង់បាន គឺមិនមានឡើយ ។

មនុស្សលោករស់នៅសព្វៗថ្ងៃ ចេះតែទំនាស់ទាស់ទែងជាមួយអ្នកដទៃ និងទាស់ជាមួយអ្វីៗផ្សេងៗទៀត សេចក្ដីក្ដៅក្រហាយចិត្តក៏មានជានិច្ចជាកាលផងដែរ ប៉ុន្តែបើមនុស្សលោក មិនមាននូវកិលេសដោយខ្លួនឯងទេនោះ គឺពិតជាមិនមានអ្វីដែលសំរាប់អោយទាស់ចិត្តដែរ ដូច្នេះតើអ្វីដែលជាគ្រឿងទាស់ពិតប្រាកដ ?

## ៣ - អព្យាកតា ធម្មា

ពួកធម៌ជា អព្យាកតៈ បានដល់

- វិបាកចិត្ត ៥២
- កិរិយាចិត្ត ២០

អព្យាកតចិត្ត ៧២

- ចេតសិកសម្បយុត្ត ៣៨
- រូបបរមត្ថ និង និព្វានបរមត្ថ

## អដ្ឋសាលិនីអដ្ឋកថា

ធម៌ដែលឈ្មោះថាអព្យាកតៈ ព្រោះអត្ថថា មិនធ្វើអោយច្បាស់ អធិប្បាយថា ÷ លោកមិនពោលទុកដោយសេចក្តីជាកុសល និងអកុសល ។ ក្នុងបណ្តាធម៌ទាំងបីនោះកុសលមានសេចក្តីមិនមានទោស និងមានវិបាកជាសុខជាលក្ខណៈ, អកុសលមានទោសនិងមានទុក្ខជាវិបាកជាលក្ខណៈ, អព្យាកតៈមាន អវិបាក ជាលក្ខណៈ ។

## សតិប្បដ្ឋាន

មិនមានអ្នកគិតក្រៅអំពីចិត្ត ដែលឈ្មោះថាចិត្តដោយអត្ថថា «គិត» ក្នុងអព្យាកតធម៌ វៀរនិព្វានចេញ

## ចែកជា ខន្ធ ៥

- រូបបរមត្ថ ២៨ ជា រូបក្ខន្ធ
- ចេតសិក ៣៨ ជា ខន្ធ ៣
- អព្យាកតចិត្ត ៧២ ជា វិញ្ញាណក្ខន្ធ ។

## សតិប្បដ្ឋាន

ការឃើញរូប គឺ ចក្ខុវិញ្ញាណធ្វើទស្សនកិច្ច ប៉ុណ្ណោះ សតិរលឹកត្រង់លក្ខណៈតែមួយលក្ខណៈមិនប្រជុំរួមជាមួយសភាវធម៌ដទៃ ទើបឃើញដោយបញ្ញាដ៏ប្រពៃនៃចិត្តឃើញគឺចក្ខុវិញ្ញាណចិត្តនោះមិនមានតួខ្លួនអ្នកឃើញផ្សេងអំពីចិត្តឃើញទៀតឡើយ ។ នេះហើយឈ្មោះថា ការចំរើនចិត្តានុបស្សនាសតិប្បដ្ឋាន ។ សូម្បីចិត្តដទៃផ្សេងៗទៀតមួយលក្ខណៈៗសតិរលឹកបានគឺជាការដេញកំចាត់សក្កាយទិដ្ឋិ, សភាវៈដទៃៗផ្សេងៗទៀតក៏ដូច្នោះដែរ ត្រូវតែជាទីតាំងនៃសតិនេះជាឧបាយបណ្តេញ ទិដ្ឋិ

អព្យាកតធម៌ចែកជា

## អាយតនៈ ១២

- ឱឡារិករូប ១២ ជា អាយតនៈ ១០
- អព្យាកតចិត្ត ៧២ ជាមនាយតនៈ
- សុខុមរូប ១៦ ចេតសិក ៣៨ និង និព្វាន គឺ ធម្មាយតនៈ ។

## ធាតុ ១៨

- ឱឡារិករូប ១២ ជា ធាតុ ១០
- ចិត្ត ៧២ ជា វិញ្ញាណធាតុ ៧
- សុខុមរូប ១៦ ចេតសិក ៣៨ និង និព្វាន ជា ធម្មធាតុ ។

អព្យាកតាធម្មាចែកជា សច្ចៈ ២ សច្ចវិមុត្តិ

* រូប ២៨ លោកិយវិបាកចិត្ត ៣២ កិរិយាចិត្ត ២០ និង ចេតសិក ៣៥ ( វៀរវិរតិ ៣ ) ទាំងអស់នេះជា ទុក្ខសច្ចៈ ។

* និព្វាន ជា និរោធសច្ចៈ ។

-*- អព្យាកតធម៌ដែលនៅសល់គឺ ÷ លោកុត្តរវិបាកចិត្ត ២០ ចេតសិកសម្បយុត្ត ៣៦ ( វៀរអប្បមញ្ញា ២ ) នេះជា សច្ចវិមុត្តិ ។

## ពាក្យគួរចងចាំជានិច្ច

ធម៌ទាំងឡាយកើតព្រោះ មានហេតុ មានបច្ច័យដូច្នេះតែវាយ៉ាងម៉េចគឺវាអញ្ចឹងឯង កុំចាំបាច់ចង់កុំអោយវាអញ្ចឹងអី តើយល់ឬទេ ? ហើយម៉្យាងទៀតចិត្តយើងមិនដូចចិត្តគេទេ កុំចង់អោយតែគេគិតដូចយើង បើយើងវិញក៏គិតមិនដូចគេដែរ នេះជាច្បាប់ធម្មជាតិ ។

# ២ _ តិកមាតិកាទី ២

១. **សុខាយវេទនាយ សម្បយុត្តា ធម្មា** ពួកធម៌ ប្រកបជាមួយសុខវេទនា បានដល់

* សុខសហគតចិត្ត ៦៣ គឺ ÷

- សុខសហគតកាយវិញ្ញាណចិត្ត ១

- សោមនស្សសហគតមនោវិញ្ញាណចិត្ត ៦២ ។

(ចូរមើលវេទនាសង្គហៈបរិច្ឆេទទី ៣ )

* ចេតសិកសម្បយុត្ត ៤៦ ( វៀរវេទនា ១ ទោចតុកៈ ៤ និង វិចិកិច្ឆាចេតសិក ១ )

## សតិប្បដ្ឋាន

ពួកធម៌ដែលប្រកបជាមួយសុខវេទនាគឺជា សញ្ញាខន្ធ, សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ ។

សត្វលោកស្វែងរកសេចក្ដីសប្បាយរីករាយពេញចិត្តនិងសេចក្ដីសប្បាយសុខស្រួលផ្លូវកាយ ប៉ុន្តែសេចក្ដីដឹងខ្លួនជាសុខក្នុងការសោយអារម្មណ៍គឺគ្រាន់តែជាប្រភេទនៃនាមធម៌ម្យ៉ាងដែលមានផស្សៈជាបច្ច័យតាក់តែងប៉ុណ្ណោះ ជារបស់ដែលត្រូវបាត់បង់ទៅវិញកាលដែលសតិរលឹកបានបញ្ញាឃើញច្បាស់យ៉ាងនេះ

គឺឃើញច្បាស់នូវការសោយអារម្មណ៍ជា សភាវធម៌ម៉្យាងមានលក្ខណៈជាបរមត្ថៈមិនមែនសត្វ បុគ្គលតួខ្លួននេះ គឺវេទនានុបស្សនាសតិប្បដ្ឋាន ។

វេទនាឯណានិមួយដែលសតិរលឹកបាន គឺត្រូវតែជាវេទនាពិតក្នុងជីវិតប្រចាំថ្ងៃ គឺជាវេទនាដែលផស្សប្បច្ច័យអោយកើតឡើងប៉ុណ្ណោះ សត្វបុគ្គលតួខ្លួនអ្នកធ្វើវេទនាមិនមាន ។

**២ - ទុក្ខាយ វេទនាយ សម្បយុត្តាធម្មា** ពួកធម៌ ប្រកបជាមួយទុក្ខវេទនា បានដល់ :

* ទុក្ខសហគតចិត្ត ៣ គឺ ÷

- ទុក្ខសហគតកាយវិញ្ញាណចិត្ត ១ និងទោមនស្សសហគតចិត្ត ២

* ចេតសិកសម្បយុត្ត ២១ គឺ ÷

- អញ្ញសមានា ១១ ( វៀរបីតិ វេទនា )

- មោចតុក: ៤ ទោចតុក: ៤ និង ថីនៈ មិទ្ធៈ ។

ពួកធម៌ទាំងអស់នេះគ្រាន់តែជាខន្ធ អាយតនៈ ធាតុ សច្ចៈ ប៉ុណ្ណោះ ។

## សតិប្បដ្ឋាន

មិនមែនជាសត្វបុគ្គលណាជាអ្នកប្រកបដោយទុក្ខវេទនានោះឡើយ គឺជាពួកធម៌សុទ្ធៗ ។ សុខវេទនាក្តី ទុក្ខវេទនាក្តី សុទ្ធតែជាទីតាំងនៃសតិរលឹកបានទាំងអស់ សុខផ្លូវកាយ សប្បាយផ្លូវចិត្ត ទុក្ខផ្លូវកាយទោមនស្សផ្លូវចិត្ត ប៉ុន្តែធម៌បដិបត្តិត្រូវតែសតិកើតដោយមានបច្ច័យនៃសតិពិតៗដែលបច្ច័យនៃសតិនោះមិនមែនបុគ្គលទេ ។

**៣ - អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា** ពួកធម៌ប្រកបដោយវេទនាមិនជាទុក្ខ មិនជាសុខ : បានដល់

* ឧបេក្ខាសហគតចិត្ត ៥៥ និង

- ចេតសិក ៤៦ ( វៀរវេទនា បីតី និង ទោចតុក ៤ )

* វេទនាដែលកើតគ្រប់ចិត្តទាំងអស់មិនដែលប្រកបជាមួយវេទនាឡើយ ។

* រូប ២៨ និង និព្វាន ក៏មិនប្រកបជាមួយវេទនាដែរ ។

### សតិប្បដ្ឋាន

* ហេតុអ្វីបានជាមនុស្សមានសេចក្តីទុក្ខតាមផ្លូវចិត្តច្រើនជាងទុក្ខតាមផ្លូវកាយ ?

- ពីព្រោះមនុស្សមិនព្រមទទួលស្គាល់សេចក្តីពិតនៃជីវិត មិនមានបញ្ញាដឹងថាហ្នឹងឯងជីវិត រួចហើយក៏ហួងហែងនូវជីវិត ទើបមានសេចក្តីទុក្ខតាមផ្លូវចិត្ត ។ សេចក្តីទុក្ខតាមផ្លូវចិត្តរមែងមិនមានដល់អ្នកដែលមិនហួងហែងជីវិតឡើយ ។

# ៣ _ តិកមាតិកានី ៣

## ១. វិបាកា ធម្មា

* ពួកធម៌ជាវិបាក វិបាកគឺជាផលដ៏ឆ្អិនរបស់កម្ម

សំដៅយកតែនាមធម៌គឺចិត្តនិងចេតសិក ។

- បានដល់ ៖ វិបាកចិត្ត ៥២ និង ចេតសិកសម្បយុត្ត ៣៨ ។

*** វិបាកចិត្ត ៥២ គឺ**

- លោកិយវិបាកចិត្ត ៣២
- លោកុត្តរវិបាកចិត្ត ២០

*** លោកិយវិបាកចិត្ត ៣២ គឺ**

- កាមាវចរវិបាកចិត្ត ២៣
- មហគ្គតវិបាកចិត្ត ៩

*** កាមាវចរវិបាកចិត្ត ២៣ គឺ ៖**

- អកុសលវិបាកអហេតុកចិត្ត ៧
- កុសលវិបាកអហេតុកចិត្ត ៨
- មហាវិបាកចិត្ត ៨ ។

*** អកុសលវិបាកអហេតុកចិត្ត ៧ គឺ ៖**

១ - ចក្ខុវិញ្ញាណ ចិត្តឃើញរូបារម្មណ៍មិនល្អ

២ - សោតវិញ្ញាណ ចិត្ត ឮសំលេងមិនល្អ

៣ - ឃានវិញ្ញាណ ចិត្ត ធុមក្លិនមិនល្អ

៤ - ជីវ្ហាវិញ្ញាណចិត្ត ដឹងរសជាតិមិនល្អ

៥ - កាយវិញ្ញាណចិត្តដឹងផោដ្ឋព្វៈមិនល្អ

៦ - សម្បដិច្ឆន្នៈ ក៏ទទួលអារម្មណ៍ ៥ មិនល្អ

៧ - សន្តីរណៈក៏ពិនិត្យអារម្មណ៍មិនល្អ

* នេះគឺជាច្បាប់យុត្តិធម៌របស់ អកុសលកម្មដែលត្រូវអោយផល ។

## សតិប្បដ្ឋាន

អកុសលវិបាកចិត្តទាំង ៧ គឺវាគ្រាន់តែជាចិត្តប៉ុណ្ណោះ ជាពិសេសវិញ្ញាណចិត្តទាំង ៥ តាមបញ្ចទ្វារមានចិត្តឃើញជាដើមដែលធ្វើទស្សនកិច្ច តាមពិតមិនមែនខ្លួនយើងទេជាអ្នកឃើញនោះ ចិត្តឃើញក្តី ចិត្តឮក្តី ចិត្តផ្សេងៗទៀតក្តី មួយលក្ខណៈៗសតិរលឹកបាន

ឈ្មោះថា ចិត្តានុបស្សនាសតិប្បដ្ឋានដោយពិត ។

## កុសលវិបាកអហេតុកចិត្ត ៨

បញ្ចវិញ្ញាណចិត្តទាំង ៥ និងវិបាកមនោធាតុ ១ (សម្បដិច្ឆន្នៈ) វិបាកមនោវិញ្ញាណធាតុ ២ (សោមនស្សសន្តីរណៈ១ ឧបេក្ខាសន្តីរណៈ ១ ) សុទ្ធតែជាចិត្តដឹងអារម្មណ៍ល្អ ព្រោះជាផលវិបាកនៃកុសលកម្ម បុថុជ្ជនអ្នកមិនបានស្តាប់រមែងមិនបានដឹងចិត្តជាអកុ-សលវិបាក ឬក៏ចិត្តជាកុសលវិបាកដូចនេះក្នុងជីវិតរាល់ថ្ងៃទេ ហើយក៏ប្រកាន់ជាតួខ្លួនឬថារបស់ខ្លួន ។

## * មហាវិបាកចិត្ត ៨

* ចេតនាមហាកុសលប្រព្រឹត្តទៅក្នុង ទាន សីល ភាវនាគឺជាកម្មប្បច្ច័យញុំាងអោយមហាវិបាកចិត្តប្រកបជាមួយចេតសិកកើតឡើងធ្វើបដិសន្ធិកិច្ចគឺកើតក្នុងកាមសុគតិភពបន្តពីចុតិចិត្ត គឺស្លាប់អំពីជាតិមួយមុនមក (ចុតិរូចបដិសន្ធិ )

* មហាកុសលកម្មមិនត្រឹមតែអោយកើតបដិសន្ធិប៉ុណ្ណឹងទេគឺ ÷

បានញុំាងវិបាកជីវិតអោយរស់បន្តទៅអោយបានដឹងនូវអារម្មណ៍ល្អៗ មានវិបាកជាសុខក្នុងជីវិត

* ផលវិបាកដែលជាសុខហើយដែលបានដឹងអារម្មណ៍ល្អៗនេះមានកំរិតតាមកម្លាំងកុសលកម្ម ដូច្នេះមនុស្សលោកអ្នកមានបញ្ញាតែងមានធម៌សន្តោសគឺចេះល្មមតាមសច្ចភាវៈនៃជីវិត ។

ចំណែកមនុស្សល្ងង់ដែលមិនចេះល្មម មិនមានបញ្ញាឃើញសច្ចធម៌របស់ជីវិត រមែងត្រូវតណ្ហាគ្របសង្កត់ចិត្តប្រាថ្នាចង់បាននូវរបស់ដែលមិនអាចបានព្រោះខ្វះបុណ្យ កាលមិនបានហើយក៏ក្តៅក្រហាយចិត្តបណ្តាលអោយចិត្តកើតរោគ មិនមានពេទ្យក្នុងលោកអាចព្យាបាលបានឡើយ រោគចិត្តរីករាលដាលទៅជាមានការច្រណែននឹងអ្នកដទៃមានសេចក្តីកំណាញ់

។ល។ ប៉ុន្តែកុំទាន់អស់សង្ឃឹមអីថ្នាំព្យាបាលរោគរបៀបនេះគឺពិតជាមាន អោយតែអ្នកជម្ងឺ ព្រមលេបព្រមផឹកដោយខ្លួនឯង

ទី ១ - អ្នកឈឺរោគនេះបានដឹងថាខ្លួនឯងមានរោគមែន ថែមទាំងបានដឹងសមុដ្ឋាននៃរោគនេះទៀតផង ។

ទី ២ - អ្នកជម្ងឺត្រូវស្គាល់ថ្នាំដែលសំរាប់ព្យាបាលរោគច្បាស់លាស់

ទី ៣ - អ្នកជម្ងឺអាចមាននូវសមត្ថភាពលេបថ្នាំបានពិតៗ

* បើយ៉ាងនេះគឺពិតជាសះស្បើយ

* ដែលថាស្គាល់រោគនៃខ្លួនឯងនោះ គឺស្គាល់អកុសលចិត្ត ថាចិត្តពិតជាមានរោគមានជម្ងឺមែន ឯចំណែកសមុដ្ឋានរបស់រោគគឺ ÷ តណ្ហា ( សត្វលោកមានទុក្ខតាមផ្លូវចិត្តសោកៈបរិទេវៈជាដើម ព្រោះតណ្ហា

ជាដែនកើតជាសមុទយៈ )

*    ដែលជាថ្នាំសំរាប់ព្យាបាលនោះបានផល់សេចក្តី សន្តោស គឺ ៖

- ល្មមចំពោះរបស់ដែលមាន

- ល្មមចំពោះរបស់ដែលបាន

- ល្មមចំពោះរបស់ដែលគួរ ( របស់ដែលគួរគឺបានដោយសុចរិត )

*    ឯចំណែកសមត្ថភាពសំរាប់លេបថ្នាំគឺធមិសន្តោសនេះបានគឺបញ្ញាបានដឹងនូវសេចក្តីពិតនៃជីវិតប្រចាំថ្ងៃ ព្រោះថាជីវិតនេះមួយចំណែកគឺជាផលវិបាករបស់កម្មចាស់ ហើយជីវិតនេះមួយចំណែកទៀតកំពុងសន្សំនូវកម្មថ្មី ទាំងបុញ្ញកម្ម ទាំងបាបកម្ម ដូច្នេះដរាបណាកម្មនៅតែមាន ពិភពលោកនេះនៅតែជារោងល្ខោននៃជីវិតដែលមានសាច់រឿងទៅតាមកម្មល្អ កម្មអាក្រក់ ជាអ្នកចាត់ចែង ម្តងដើរតួជាស្តេចជាសេដ្ឋី

ផ្លូវណាដើរត្រូវជាអ្នកសូមទានគេ ឬក៏ត្រូវគេធ្វើទារុណ-កម្មផ្សេងៗ ។ ល ។

* បើជាតួអង្គហើយសុខចិត្តសំដែងអោយវាចប់មួយរឿងៗទៅកុំចាំបាច់ចង់កែសាច់រឿងគេធ្វើអ្វី ព្រោះកម្មគេបានចងក្រងរួចស្រេចទៅហើយ ។

* ប៉ុន្តែបើនឿយណាយហើយ លែងចង់ដើរតួអង្គក្នុងឆាកល្ខោននៃជីវិតនេះបន្តទៅទៀតនោះ ត្រូវសងបំណុលចៅកែអោយវារួចទៅ ព្រោះតណ្ហាវាជាចៅកែនៃរោងល្ខោននេះ តែបើនៅតែជំពាក់បំណុលតណ្ហាទេនោះ កម្មនៅតែចាត់ចែងសាច់រឿងអោយវិបាកប្រព្រឹត្តទៅជាតួអង្គតទៀត ។

* សូមជ្រាបជាពិសេសថាគ្រប់តួអង្គទាំងអស់មកអំពីក្តីល្ងង់មិនមានវិជ្ជាជីវិត ( វិបស្សនាវិជ្ជា ) ទើបបុលបំណុលតណ្ហា ហើយក៏ជាអ្នកបំរើតណ្ហាទៅ ។

## ២ - វិបាកធម្ម ធម្មា

ពួកធម៌នាំអោយមានវិបាកបានដល់

- កុសលចិត្ត ៣៧ ចេតសិក ៣៨

- អកុសលចិត្ត ១២ ចេតសិក ២៧ ( រួមចិត្ត ៤៩ ចេតសិក ៥២ )

* ចេតនាចេតសិកប៉ុណ្ណោះដែលជាកម្មប្បច្ច័យនាំអោយមានវិបាកធម៌ ប៉ុន្តែពួកសម្បយុត្តធម៌គឺចិត្ត និងចេតសិកដែលប្រកបជាមួយចេតនា ៤៩ ក៏ជាពួកធម៌នាំអោយមានវិបាកដែរ ប៉ុន្តែដោយឧបនិស្សយប្បច្ច័យប៉ុណ្ណោះ គឺទីអាស្រ័យដ៏មានកម្លាំងជាប្រក្រតីញ៉ាំងពួកធម៌ជាវិបាកអោយកើតឡើង មិនជាកម្មប្បច្ច័យ ទេ ព្រោះមិនមែនជាចេតនា ។

* ប៉ុន្តែដែលជាកម្មប្បច្ច័យផង ជាឧបនិស្សយប្បច្ច័យផងបានដល់ចេតនានៅក្នុងចិត្ត ៤៩ ដួង ។

## សតិប្បដ្ឋាន

* ពួកធម៌ដែលនាំអោយមាននូវផលវិបាកកើតឡើងនោះ មានចែកជាលោកិយនិងលោកុត្តរ ដូចខាងក្រោម

- លោកិយគឺ ÷ កុសលចិត្ត ១៧ និងអកុសលចិត្ត ១២ រួមទាំងចេតសិក ៥២ ។

- លោកុត្តរគឺ ÷ លោកុត្តរចិត្ត ២០ និងចេតសិក ៣៦ ។ ( ចំពោះសេចក្តីរៀបរាប់នូវចេតសិកប្រកបជាមួយចិត្តចូររៀនក្នុងសៀវភៅ អភិធម្មត្ថសង្គហៈ ) ។

* ចំពោះពួកធម៌ដែលនាំអោយកើតនូវវិបាកដែលជាលោកុត្តរ គឺមិននាំអោយកើតមានវិបាកបដិសន្ធិឡើយ ។ ឯចំណែកពួកធម៌ដែលនាំអោយកើតនូវវិបាកជាលោកិយ ( ចេតនា ២៩ និង សម្បយុត្តធម៌ ) គឺនាំអោយមានវិបាកបដិសន្ធិ ។ កម្មគឺចេតនានេះជាពូជ ផលវិបាកស្រេចនៅលើពូជនេះគឺដំណើរនៃសង្ខារធម៌សុទ្ធ

មនុស្ស សត្វគ្រាន់តែសន្មតិតាមប្រភេទតាមភូមិ ឬតាមជាតិនៃបរមត្ថសង្ខារតែប៉ុណ្ណោះ ។

* បដិសន្ធិគឺជា វិបាករបស់កម្ម បដិសន្ធិក្នុងស្ថានផ្សេងៗគឺស្រេចតែនៅលើកម្ម

* ទាំងកម្ម ទាំង បដិសន្ធិ សុទ្ធតែពុំមែនជាមនុស្សជាសត្វបុគ្គល ឬទេវតាឡើយ គឺជាសង្ខារធម៌ បរមត្ថសុទ្ធ ។

* នៅក្នុងភពដែលមានខន្ធ ៥ កម្មមិនមែន នាំអោយកើតតែវិបាកបដិសន្ធិទេ គឺកម្មនាំអោយកើតរូបទៀតដែរ ដូចជាបសាទរូប ៥ ហទយវត្ថុ ១ ភាវរូប ២ និង ជីវិតរូបជាដើម ។ រូប ជារូបក្ខន្ធវិបាកបដិសន្ធិចេតសិកជាវេទនាខន្ធសញ្ញាខន្ធ និងសង្ខារក្ខន្ធ ។ ឯចំណែកវិបាកបដិសន្ធិចិត្តគឺជាវិញ្ញាណក្ខន្ធ ។

* មាតា បីតា ជាអ្នកបង្កើតកូនប្រុសស្រី មានគុណលើកូន ព្រោះអំណាចព្រហ្មវិហារធម៌ ប៉ុន្តែ មាតា

បីតា មិនមែនបង្កើតខន្ធ ៥ ទេ ព្រោះបច្ច័យដែលនាំអោយខន្ធ ៥ កើតមិនមែនមាតា បីតា ឬមនុស្សសត្វបុគ្គលណាឡើយ ។

មាតាបីតាបង្កើតកូនបានមែន តែមិនអាចបង្កើតចិត្តរបស់កូនបានទេ តាមពិតបុគ្គលមិនអាចនឹងបង្កើតចិត្តរបស់ខ្លួនឯងបានផង ចាំបាច់ពោលថ្វីចំពោះចិត្តអ្នកដទៃ ចិត្តគឺធម្មជាតិដឹងច្បាស់នូវអារម្មណ៍ ចិត្តជាធម្មជាតិគិតនឹកចិត្ត គឺធម្មជាតិសន្សំសន្តានទៅដោយអំណាចជវនវិថី ។ ចិត្តគ្រាន់តែជាចិត្ត កើតឡើងមួយខណៈ ហើយត្រូវរលត់ទៅវិញ ទើបចិត្តមួយខណៈផ្សេងទៀតកើតបន្ត ។ តាំងតែបដិសន្ធិចិត្ត រហូតដល់ចុតិចិត្តគឺជាខណចិត្តបន្តគ្នារាប់មិនអស់ ដូច្នេះនៅពេលណាមានចិត្តអ្វីកើតឡើងប្រាកដសតិរលឹកបាន បញ្ញាឃើញត្រឹមតែជាចិត្តពិតៗ លះបង់សេចក្តីប្រកាន់នូវចិត្តនោះថា ជាតួខ្លួន ថាជារបស់ខ្លួនថាជាយើងបាននេះគឺ ចិត្តានុ

បស្សនាសតិប្បដ្ឋាន ជាធម៌បដិបត្តិ ។

* ដោយការសន្សំសន្តានចិត្តក្នុងសង្សារវដ្ត ដ៏យូរលង់មកខុសៗគ្នាទើបមនុស្សយើងមានចិត្តផ្សេងៗគ្នា នេះគឺបរមត្ថសច្ចៈ កាលណាបើមនុស្សលោកយល់ដល់ការពិតនេះ ក៏រមែងលះបង់បាននូវការកង្វល់ហួងហែងមិនឈ្លោះទាស់ទែងគ្នា និងសំរួលទៅតាមអធ្យាស្រ័យនៃគ្នានិងគ្នា ថែមទាំងជួយផ្តល់នូវឱវាទដំបូន្មានល្អៗក្នុងកាលដ៏សមគួរទៀតផង ។

## ៣ - នេវវិបាក នវិបាកធម្ម ធម្មា

ពួកធម៌ជាវិបាកក៏មិនមែនជាធម៌នាំអោយមានវិបាកក៏មិនមែនបានដល់

- កិរិយាចិត្ត ២០ ចេតសិក ៣៥
- រូប ២៨ និង និព្វាន ។ ( មិនមែនពួកធម៌ ២ ពួកមុន )

### សតិប្បដ្ឋាន

សេចក្តីមិនកង្វល់គឺជាទីពឹងនៅក្នុងវដ្តសង្សារដ៏ធំធេងនេះ ការមិនប្រកាន់នាំអោយមិនមានក្តីកង្វល់ ការឃើញសច្ចធម៌នាំអោយមិនមានការប្រកាន់ ។

# ៤ _ តិកមាតិកាទី ៤

## ១. ឧបាទិន្នុបាទានិយាធម្មា

ពួកធម៌មានកម្មកិលេសនាំអោយកើតទាំងជាអារម្មណ៍នៃការប្រកាន់មាំ បានដល់ :

- លោកិយវិបាកចិត្ត ៣២ និងចេតសិក ៣៥
- កម្មជរូប ២០ រូប ។

* ពួកធម៌ទាំងអស់នេះគឺជាខន្ធ អាយតនៈ ធាតុ សច្ចៈ សភាវធម៌គឺជាអារម្មណ៍របស់វិបស្សនា ។

### សតិប្បដ្ឋាន

សេចក្តីប្រកាន់មាំកើតឡើងនៅក្នុងអារម្មណ៍ណា

ផុសផុលនៅក្នុងអារម្មណ៍ណា កាលដែលបញ្ញាឃើញនូវអារម្មណ៍នោះតាមសេចក្តីពិតដោយប្រច័ក្សលក្ខណៈនៃសភាវៈបរមត្ថ នេះគឺឧបាយដែលត្រូវលះបង់សេចក្តីប្រកាន់ ។ ដូច្នេះទីតាំងនៃសេចក្តីប្រកាន់គឺនាមរូបក្នុងជីវិតប្រចាំថ្ងៃនាមរូបចែកជា កាយ វេទនា ចិត្ត ធម៌ នាមរូបក្នុងជីវិតរាល់ថ្ងៃ កាលបើជាទីតាំងនៃសតិវិបស្សនាក៏ជាការលះបង់នូវអភិជ្ឈានិងទោមនស្ស ។

* សូមយល់ចូលចិត្តថាបើមិនមានឧបាទានក្នុងសភាវធម៌ណាទេនោះក៏មិនត្រូវទៅបង្កើតធ្វើនូវសភាវធម៌នោះសំរាប់អោយជាអារម្មណ៍នៃ**វិបស្សនា** កាលណាដែលពុទ្ធបរិស័ទបានសិក្សា អង្គធម៌បរមត្ថគឺ ឧបាទិន្នធម៌ ក៏អាចជ្រាបបានថា ÷ លោកិយចិត្តុប្បាទនិងរូបដែលជាផលជាវិបាករបស់កម្ម មានជាប្រចាំក្នុងជីវិតរាល់ថ្ងៃនេះ គឺអ្វីខ្លះ ហើយដែល **ត្រូវឧបាទានចាប់យកជាអារម្មណ៍** ។ ដូចនេះត្រូវតែឧបាទិន្នធម៌

ជាអារម្មណ៍ នៃវិបស្សនាវិញទើបលះនូវឧបាទានចេញបាន ។

* ឧបាទិន្នធម៌គឺធម៌ដែលកើតអំពីលោកិយកម្ម មានចិត្តឃើញ ចិត្តឮ ចិត្តដឹងក្លិនចិត្តដឹងរស ចិត្តដឹងផោដ្ឋព្វៈជាដើម ឬក៏សុខវេទនានិងទុក្ខវេទនាតាមផ្លូវកាយសុទ្ធតែវិបាករបស់កម្ម កាលដែលកើតឡើងវង្វេងភ្លេចសតិក៏ជាអារម្មណ៍នៃឧបាទាន ។

* ការកំចាត់ឧបាទានត្រូវយកទីតាំងនៃឧបាទានមកជាទីតាំងនៃសតិវិញ ។

## ២ - អនុបាទិន្នុបាទានិយាធម្មា

ពួកធម៌មិនមានកម្មកិលេសនាំអោយកើត តែជាអារម្មណ៍នៃការប្រកាន់មាំ បានដល់ :

- លោកិយកុសលចិត្ត ១៧
- អកុសលចិត្ត ១២
- កិរិយាចិត្ត ២០

- ចេតសិកសរុបទាំងអស់ ៥២

- រូប ៣ សមុដ្ឋានទៀត ( វៀរកម្មជរូប )

* ពួកធម៌នេះមិនកើតមកពីកម្មក្កិលេសទេ តែនៅតែជាអារម្មណ៍នៃឧបាទាន ព្រោះជាលោកិយ ។

## សតិប្បដ្ឋាន

* ឧប = ចូលទៅជិត

* អាទាន = ចាប់យក កាន់យក

ឧបាទានៈគឺ ÷ ការប្រកាន់មាំដោយការចាប់យកនូវលោកិយធម៌មកប្រកាន់ថាជារបស់អញ ឬប្រកាន់ថាតួខ្លួនអញ ព្រោះមិនបានដឹងការកើតឡើងនៃសង្ខារធម៌ គឺការកើតឡើងនៃទុក្ខ និងមានការវិនាសជាម្ចាស់ ។

* (អ + ទិន្ន + អាទាន )=អទិន្នាទាន គឺការកាន់យកនូវរបស់ដែលគេមិនបានអោយ ដោយការលួចប្លន់ បរិស័ទមានសីល គឺមិនលួច មិនកាន់យកនូវរបស់ដែលមានម្ចាស់គេនៅគ្រប់គ្រងរក្សា ប៉ុន្តែរបស់ណាជារបស់

យើង យើងកាន់យកប្រើប្រាស់តាមត្រូវការ នេះគឺបញ្ញាថ្នាក់សីលដោយការចេះដឹងបានត្រឹមត្រូវ មិនប្រព្រឹត្តនូវអំពើលួចប្លន់ឆក់ដណ្ដើមអំពីម្ចាស់ទ្រព្យឡើយ ។

កុសលថ្នាក់សីលនេះអាចមិនកាន់យករបស់ដែលគេមិនបានអោយដែលជាការលះបង់នូវអទិន្នាទាន ប៉ុន្ដែមិនអាចលះបង់នូវឧបាទានបានឡើយ ដោយនៅមានការប្រកាន់ឧបាទានក្នុងថាជារបស់ខ្លួន ឬថាជាតួខ្លួន ។

* វិបស្សនាញាណ បានឃើញនូវសង្ខារធម៌ទាំងឡាយមានការកើតឡើងហើយ វិនាសទៅវិញជាធម្មតា បានឃើញនូវម្ចាស់នៃសង្ខារធម៌តាមសេចក្ដីពិត គឺការរលត់ការវិនាស ការអស់ទៅការសូន្យទៅ ។

បញ្ញាថ្នាក់នេះទើបអាចលះបង់នូវ ឧបាទាន បាន គឺមិនប្រកាន់នូវអ្វីៗទាំងពួង ដែលមានការកើតឡើងហើយ រមែងវិនាសទៅវិញជាធម្មតានោះថាជាតួខ្លួន ឬ

ថាជារបស់ខ្លួនទៀតឡើយ ដោយការមិនចាប់យកនូវសង្ខារទើបជាការបាននូវទីពឹងបានដល់កោះ មិនរសាត់អណ្តែតក្នុងសមុទ្ទសង្សារដែលជាការនៅក្នុងកងទុក្ខទៀតឡើយ ។

## ៣ - អនុបាទិន្នានុបាទានិយាធម្មា

ពួកធម៌មិនមានកម្មកិលេសនាំអោយកើត ទាំងមិនជាអារម្មណ៍នៃការប្រកាន់មាំ

- លោកុត្តរចិត្ត ៤០ និងចេតសិក ៣៦ និព្វាន ។

### សតិប្បដ្ឋាន

និព្វានមិនត្រឹមតែមិនមែនជាអារម្មណ៍នៃឧបាទានប៉ុណ្ណោះទេ ថែមទាំងជាអារម្មណ៍រំលត់ឧបាទានទៀតផង ព្រោះខណៈនៃអរិយមគ្គកើតឡើងគឺមាននិព្វានជាអារម្មណ៍ ។

អរិយមគ្គជាលោកុត្តរធម៌ លះកិលេសបានពិតប្រាកដ កិលេសណាដែលអរិយមគ្គលះហើយ មិន

ត្រឡប់កើតវិញឡើយ ព្រោះហេតុនេះមគ្គជាលោកុត្តរ និមួយៗមានសោតាបត្តិមគ្គជាដើមកើតតែម្ដងគត់ ហើយ ត្រឹមតែមួយខណៈប៉ុណ្ណោះក្នុងសង្សារវដ្ដ ។

អរិយមគ្គ គឺជាធម្មៈសុទ្ធៗ «លោកុត្តរាធម្មា»

អរិយមគ្គបាននូវបច្ច័យជាទីអាស្រ័យដ៏មានកម្លាំង គឺ គោត្រភូញ្ញាណ ។

គោត្រភូញ្ញាណគឺបញ្ញាជាន់សង្កត់ឈានកន្លងលះបង់នូវភាពជាបុថុជ្ជនទៅរកអរិយជនពិតៗ ។

គោត្រភូញ្ញាណ គឺជាមហាកុសលញ្ញាណសម្បយុត្ត លះបង់នូវសង្ខតនិមិត្តគឺអារម្មណ៍ជាសង្ខារដោយតទង្គប្បហាន តោងយកនិព្វានជាអារម្មណ៍ ។

គោត្រភូញ្ញាណគឺជាធម្មៈសុទ្ធៗដោយបរមត្ថៈមិនមានបុគ្គលតួខ្លួនជាអ្នកធ្វើទេ តែអាស្រ័យដោយអនុលោមញ្ញាណ អនុលោមញ្ញាណ គឺបញ្ញាក្នុងមហាកុសល មានកិច្ចលះបង់នូវការជំទាស់រារាំងនូវលក្ខណៈ

របស់សង្ខារដែលវិបស្សនាញាណខាងដើមបានឃើញ មានអនិច្ចលក្ខណៈជាដើម និងលះបង់ការជំទាស់រារាំង ក្នុងដំណើរទៅរកព្រះនិព្វានដែលជាការលះបង់ដោយ ឥទង្គប្បហាន គឺលះបង់ដោយអង្គនៃវិបស្សនានោះ ។

អនុលោមញាណគឺ ញាណដែលស្របតាម វិបស្សនាញាណខាងដើម ឃើញតាមដោយសង្ខារធម៌ កំពុងប្រាកដនូវលក្ខណៈក្នុងភាពជាអារម្មណ៍របស់អនុ លោមញាណនឹងឯង មិនត្រឹមតែប៉ុណ្ណោះថែមទាំងព្រម ក្នុងការអោយលះបង់នូវសង្ខារ បញ្ជូនដំណើរទៅរក ការបានឃើញនូវនិព្វានដែលស្ងប់ប្រណីត ផ្ទុយអំពី សង្ខារធម៌ទៀតផង ។

* វិបស្សនាញាណមួយថ្នាក់ៗសុទ្ធតែជាសង្ខារ ធម៌អាស្រ័យនូវបច្ច័យដែលជាសង្ខារធម៌ដែរ វិបស្សនា ចំរើន ដោយការមានសតិរលឹកដឹងនូវអារម្មណ៍ជា បរមត្ថធម៌ មិនមែនដោយការតាំងខ្លួនទៅធ្វើឬទៅ

បដិបត្តិនោះទេ គឺផ្តើមដោយការសង្កេតនិងសិក្សានូវសភាវធម៌ក្នុងជីវិតប្រចាំថ្ងៃ ។

ការស្តាប់ព្រះធម៌យល់ជាហេតុនៃការមានសតិ ។ ការស្តាប់នូវព្រះធម៌យល់គឺជាមហាកុសលញាណសម្បយុត្តចិត្តប្បាទ គឺត្រឹមតែជាការកើតឡើងនូវកុសលធម៌ដែលប្រកបដោយបញ្ញាថ្នាក់ស្តាប់ប៉ុណ្ណោះ គឺជាបរមត្ថធម៌ពិតៗ សត្វបុគ្គលតួខ្លួនមិនមាន ស្មារតីសតិរលឹកនូវសភាវធម៌រូបក៏រលត់បាត់ទៅដែរ បញ្ញាក៏រលត់ទើបពោលថា សត្វបុគ្គលអ្នកបដិបត្តិធម៌មិនមានគឺមានតែធម៌បដិបត្តិសុទ្ធៗ ។

# ៥ _ តិកមាតិកាទី ៥

## ១. សង្កិលិដ្ឋសង្កិលេសិកា ធម្មា

ពួកធម៌សៅហ្មង ទាំងគួរដល់នូវការសៅហ្មង គឺ ៖ អកុសលចិត្ត ១២ និង ចេតសិក ២៧ ។

* ពាក្យគួរដល់ការសៅហ្មងគឺជាអារម្មណ៍នៃកិលេស ព្រោះជាលោកិយ

## សតិប្បដ្ឋាន

មនុស្សលោកខ្លាចស្លាប់ព្រោះការជាប់ជំពាក់ចិត្តនឹងអ្វីៗជុំវិញជីវិតការរស់នៅ ទោះជារបស់មានវិញ្ញាណ ឬក៏អត់វិញ្ញាណក៏ដោយ មាសប្រាក់ កិត្តិយសកេរ្តិ៍ឈ្មោះ និងការសប្បាយរីករាយភ្លើតភ្លើន ជាប់ជំពាក់ក្នុងជីវិតដែលបានបរិភោគនូវកាមគុណ ទោះបីជីវិតនោះត្រដាបត្រដួសយ៉ាងណាក៏ដោយ ក៏មនុស្សនៅតែខ្លាចស្លាប់ ។ ជាការបញ្ជាក់ថា លោភៈឬកាមតណ្ហារបស់មនុស្សហ្នឹងឯងដែលនាំអោយមនុស្សខ្លាចស្លាប់។ តាមពិតទៅសេចក្តីស្លាប់ មិនគួរខ្លាចទេ ព្រោះជាធម្មតានៃការកើត ប៉ុន្តែអ្វីដែលគួរអោយខ្លាចនោះគឺលោភៈ ឬកាមតណ្ហាដែលវាធ្វើអោយមនុស្សចេះខ្លាចស្លាប់ និងចេះភ័យខ្លាចក្នុងប្រការផ្សេងៗច្រើនមុខទៀតផង ។

ការយំរៀបរាប់ ដោយការសោកស្តាយ ចំពោះ សត្វ ឬសង្ខារដែលវិនាសព្រាត់ប្រាសទៅ សេចក្តីសោកសង្រេងក្រៀមក្រំទាំងអស់សុទ្ធតែកើតមកអំពីសេចក្តីស្រឡាញ់គឺលោភៈ ឬកាមតណ្ហាហ្នឹងឯង មនុស្សលោកក្បត់នឹងខ្លួនឯង ព្រោះថា ជាមួយគ្នានឹងការភ័យខ្លាច និងមានការសោកស្តាយក៏ខំស្វែងរកនូវរបស់អោយជាទីពេញចិត្ត ឬក៏ខំជាប់ជំពាក់ខ្លាំងដែរ ។ លោភៈជានាមធម៌យ៉ាងជាទីតាំង នៃសតិរលឹកសតិរលឹកទាន់ពេល ដែលលោភៈកំពុងប្រាកដ គឺមិនមែនមនុស្ស សត្វ បុគ្គលតួខ្លួនជាអ្នកជាប់ជំពាក់ឬត្រូវការប្រាថ្នាចង់បាននោះទេ បញ្ញាឃើញច្បាស់នូវសភាវៈលោភធម៌ជា បរមត្ថសង្ខារពិតៗ លះបង់ការប្រកាន់ដោយទិដ្ឋិគឺ ឃើញខុសថាលោភៈជាខ្លួន ការលះបង់នូវអកុសលធម៌គឺលះបង់នូវពេលដែលសភាវធម៌កំពុងប្រាកដដោយការមានសតិរលឹកដឹងទាន់ ហើយ

បញ្ញាឃើញច្បាស់នូវលក្ខណៈនៃសភាវធម៌នោះៗ ។

បើសភាវធម៌កើតឡើងមិនចំពោះថា កុសលឬក៏អកុសល អព្យាកតៈអ្វីឡើយអោយតែជាលោកិយៈ មិនមានសតិរលឹកដឹងទាន់ទេនោះក៏ជាឱកាសនៃ កិលេស។

## ២ - អសង្កិលិដ្ឋសង្កិលេសិកាធម្មា

ពួកធម៌ដែលមិនសៅហ្មងតែគួរដល់នូវការសៅហ្មង

- លោកិយកុសលចិត្ត ១៧
- លោកិយវិបាកចិត្ត ៣២
- កិរិយាចិត្ត ២០ និង ចេតសិក ៣៨ រូប ២៨ ។

### សតិប្បដ្ឋាន

ការបាននូវរបស់ដែលជាទីពេញចិត្ត មិនមានបានអ្វីក្រៅអំពីការបាននូវសេចក្ដីបន្ថែមការពេញចិត្តនោះអោយកើនច្រើនឡើងទៀតតែប៉ុណ្ណោះ ទីបំផុតការព្រាត់ប្រាសចាករបស់ដែលជាទីស្រឡាញ់នឹងត្រូវ

បានមកដល់ នៅពេលដែលព្រាត់ប្រាសមកដល់មិន មាននៅសល់អ្វីក្រៅអំពីការសោកស្តាយ និងការសន្សំសន្តានពេញទៅដោយកិលេសតណ្ហា ដែលជាគ្រឿងសៅហ្មង ។ ការព្រាត់ ព្រោះបានជួបបើមិនមានការបានជួបទេ ការព្រាត់ប្រាសក៏ពុំមានដែរ ប៉ុន្តែមនុស្សល្ងង់ខ្លៅបើមាន ការព្រាត់ប្រាសអ្វីមួយដែលជាទីពេញចិត្តក៏យំសោក ដោយត្រូវការចង់បាននូវរបស់ដែលព្រាត់ប្រាសនោះមកវិញ ។

ទឹកភ្នែកដែលច្រើនជាងទឹកមហាសមុទ្រ ក៏ព្រោះតែមានការពេញចិត្តដោយលោភៈជាប់ជំពាក់នឹងរបស់ដែលបានជួបហ្នឹងឯង ។

សង្ខារធម៌ទាំងឡាយជាទុក្ខទោសព្រោះមិនទៀងមនុស្សលោកធ្វើការវែកញែកបែងចែក ការជួបនិងការព្រាត់ ឬការកើតនិងការស្លាប់ ឬការជានិងការឈឺ ឬភាពក្មេងនិងចាស់ជរា អោយដាច់ចេញអំពីគ្នា ហើយ

ធ្វើការពេញចិត្តនឹងម្យ៉ាង ទាស់ចិត្តនឹងម្យ៉ាងទៀត ។ សត្វលោក ពេញចិត្តនឹងបានលាភ តែទាស់ចិត្តនឹងការអត់លាភ ពេញចិត្តនឹងបានយស បានសុខ បានសរសើរ ប៉ុន្តែក៏ទាស់ចិត្តផងដែរនឹងភាពផ្ទុយគ្នា សត្វលោកញាប់ញ័រមិនមានទីពឹងដូចត្រីក្នុងទីដែលមានទឹកតិច ។ ធម្មជាតិណាដែលមានការកើតជាធម្មតាធម្មជាតិនោះ សុទ្ធតែមានការវិនាសទៅវិញជាធម្មតានេះជាចំណុចសំខាន់ដែលបញ្ញាចក្ខុបានឃើញតាមពិតសង្ខារធមិមានការមិនទៀងហ្នឹងឯងដែលជាទោស អ្វីៗដែលសត្វលោកទាស់ចិត្តនោះវាជារបស់ធម្មតា ដូចតែគ្នានឹងអ្វីៗដែលសត្វលោកពេញចិត្តស្រឡាញ់នោះដែរ ប៉ុន្តែដែលទាស់ចិត្ត ខឹងក្រោធកើតឡើងនោះ ព្រោះការស្រឡាញ់ពេញចិត្តគឺលោភៈទេតើដែលនាំអោយកើត ។ ក្មេងម្នាក់ធ្លាប់តែដើរទៅរៀន តែក្រោយមកឪពុកម្ដាយរបស់ក្មេងនោះ បានទិញកង់អោយកូនជិះដែលនាំ

អោយក្មេងនោះឯង មានការសប្បាយចិត្តច្រើន ។

ក្រោយមកទៀតឪពុកម្តាយបានទិញម៉ូតូអោយកូនជិះ ដែលធ្វើអោយរីងរឹតតែពេញចិត្តមែនទែន ប៉ុន្តែជិះបានតែពីរបីថ្ងៃគាត់ឈប់អោយកូនគាត់ជិះម៉ូតូតទៅទៀត ព្រោះខ្លាចចោរប្លន់ម៉ូតូហើយគ្រោះថ្នាក់ដល់កូនគាត់ ឯចំណែកក្មេងនោះវិញ ព្រោះតែការជំពាក់ចិត្តនឹងម៉ូតូចង់ជិះម៉ូតូបន្តទៀត ក៏កើតទុក្ខយ៉ាងខ្លាំងក្នុងការជិះដោយកង់ទៅរៀនលើកក្រោយនេះ ជាការសំដែងអោយឃើញថាការទាស់ចិត្ត ការមិនសប្បាយចិត្ត មិនមែនមកអំពីជិះកង់ មិនបានជិះម៉ូតូនោះឡើយ ។

ពិតណាស់សេចក្តីស្រឡាញ់នាំអោយកើតទុក្ខសោកខ្សឹកខ្សួលនាំអោយចេះខឹង ចេះស្អប់ ចេះភ័យបុគ្គលធ្វើរបស់អោយជាទីស្រឡាញ់ពេញចិត្តច្រើនឈ្មោះថាធ្វើនូវសេចក្តីទុក្ខសោក ការភិតភ័យសំរាប់ទុកអោយខ្លួនឯងច្រើនដែរ ។ ក្នុងលោកនេះមានវត្ថុជាទី

ត្រេកអរ ដែលជានុយឬជាអន្ទាក់របស់មច្ចុរាជ ឯការរីករាយត្រេកអរដោយនន្ទិរាគៈ គឺជាការជាប់នូវអន្ទាក់ដោយពិត ប៉ុន្តែសត្វលោកមើលឃើញនូវអន្ទាក់នោះជាកម្រងផ្កាទៅវិញ ។ សត្វលោកសំគាល់នូវការដែលជាប់អន្ទាក់របស់មច្ចុរាជថាជាការបាននូវទីពឹងដ៏មាំទាំ ថែមទាំងមានការមើលងាយអ្នកដទៃទៀតផង មិនខុសគ្នាអំពីជ្រូកស្រុកដែលគេចិញ្ចឹមយកសាច់សំរាប់លក់ ឬសំរាប់បរិភោគនោះឡើយ ។

បុគ្គលណាបានដឹងច្បាស់ថា អារម្មណ៍ក្នុងលោកគឺសុទ្ធតែជាគ្រឿងជាប់ជំពាក់បុគ្គលនោះមិនឆោតល្ងង់ឡើយ ។

## ៣ - អសង្កិលិដ្ឋាសង្កិលេសិកាធម្មា

ពួកធម៌ដែលមិនសៅហ្មងទាំងមិនគួរដល់ការសៅហ្មងបានដល់លោកុត្តរធម៌ទាំងអស់

- លោកុត្តរចិត្ត ៤០ ចេតសិកសម្បយុត្ត ៣៦

## សតិប្បដ្ឋាន

* មានតែលោកុត្តរធម៌ប៉ុណ្ណោះដែលមិននាំអោយមានការជាប់ជំពាក់ ព្រោះមិនមែនជាអារម្មណ៍នៃឆន្ទរាគៈ ។ រូបសំលេងក្លិនរសផោដ្ឋព្វៈ និងធម្មារម្មណ៍ជាតិជាលោកិយសុទ្ធតែអាចជាចំណីនៃកិលេសបានទាំងអស់ និងជាចំណីនៃសេចក្តីវិនាសដោយពិតប្រាកដទៀតផង ។

ជាធម្មតារបស់នុយគេតែងធ្វើយ៉ាងណា អោយប្រណីតនិងអោយជាទីចាប់ចិត្តដល់ពពួកត្រីទាំងឡាយប៉ុន្តែគួរអោយស្ដុតខ្លាចនូវអាផ្លាដែលបង្កាប់នៅក្នុងនុយពួកត្រីដែលលេបនុយហើយ ក៏ត្រូវព្រានធ្វើតាមសេចក្តីប្រាថ្នា ។ ព្រានសន្ទូចគឺជាឈ្មោះនៃមារបានដល់កិលេសមារ សន្ទូចដែលមាននុយយ៉ាងប្រណីត គឺជាឈ្មោះលាភសក្ការៈនិងកិត្តិយសកេរ្តិ៍ឈ្មោះ សេចក្តី

សរសើរលោកិយសុខកិលេសកាម វត្ថុកាមរូបសំលេង ក្លិនរសផោដ្ឋព្វៈ ។ បុគ្គលដែលមានការត្រេកអរជាប់ជំពាក់ប្រាថ្នានូវលាភសក្ការៈជាដើមគឺជាការលេបនុយមារអាចធ្វើតាមសេចក្តីប្រាថ្នាគឺថាកិលេសមារនឹងធ្វើអោយសត្វលោកធ្លាក់ក្នុងអបាយភូមិដល់នូវការវិនាសយ៉ាងធំ ឬថានឹងធ្វើអោយសត្វលោកមិនមានទីពឹងនៅក្នុងមហាសមុទ្រទុក្ខ សត្វលោកមិនរួចចាកជាតិជរាមរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួលទុក្ខទោមនស្សនិងសេចក្តីចង្អៀតចង្អល់ចិត្តឡើយ ។

វណ្ណរូបជាលោកក្នុងការរស់នៅក្នុងខណៈឃើញ សទ្ទរូបជាលោកនៃការរស់នៅក្នុងខណៈឮ គន្ធរូបគឺក្លិនជាលោកនៃការរស់នៅក្នុងខណៈធុំក្លិន រសរូបគឺរសារម្មណ៍ ជាលោកនៃការរស់នៅក្នុងខណៈដឹងរសផោដ្ឋព្វៈជាលោកនៃការរស់នៅក្នុងខណៈដឹងផោដ្ឋព្វៈធម្មារម្មណ៍ ជាលោកនៃការរស់នៅក្នុងខណៈនៃមនោ

វិញ្ញាណដែលដឹងនូវធម្មារម្មណ៍នោះៗ ។

នេះជាលោកបរមត្ថជាលោកក្នុងអរិយវិន័យ ។ តើព្រះគុណម្ចាស់ ញាតិញោមពុទ្ធបរិស័ទ រស់នៅក្នុងលោកបរមត្ថ ឬក៏រស់នៅក្នុងលោកបញ្ញត្តិ ?

លោកបញ្ញត្តិគឺលោកនៃសភាវៈច្រើនប្រជុំរួមគ្នាហើយបញ្ញត្តិហៅថាលោកមនុស្សមានផែនដី ព្រៃព្រឹក្សា មហាសមុទ្រ មានភ្នំមានមនុស្ស មានសត្វ ។ល។

ការដឹងបានថា មានការរស់នៅក្នុងលោកបរមត្ថពិតៗគឺក្នុងខណៈមានសតិប្បដ្ឋានគឺសតិរលឹករូបធម៌ឬនាមធម៌ដែលកំពុងប្រាកដ ។

រូបធម៌ នាមធម៌ គឺជាលោកដោយបរមត្ថ មានរយៈពេលឆាប់រហ័សណាស់ក្នុងការបែកធ្លាយគឺតាំងនៅពុំបានយូរឡើយ ជីវិតដែលរស់នៅប្រកបជាមួយចិត្តក៏រលត់ទៅតាមចិត្ត សតិក៏រលត់ វិបស្សនា ក៏រលត់តែសភាវធម៌ថ្មីកើតមកជំនួស ហាក់ដូចជាសភាវធម៌មុន

មិនបានរលត់ ហើយឋិតនៅបានយូរហូតរាប់ខែរាប់ឆ្នាំទៀតផង ។

រូបសំលេងក្លិនរសផោដ្ឋព្វៈប្រាកដបានត្រឹមតែជាអារម្មណ៍នៃវិថីចិត្តក្នុងទ្វារនិមួយៗ រួចហើយក៏កន្លងទៅរលត់ទៅទាំងវិថីចិត្តទាំងអារម្មណ៍ គឺជាការបែកធ្លាយនៃលោក ។

ការនឹកគិតដល់រឿងរបស់រូបសំលេងក្លិនរសផោដ្ឋព្វៈ គឺជាលោកគំនិត សូម្បីរូបឬសំលេងជាដើមកន្លងទៅហើយក៏ដោយឬពុំទាន់មកដល់ ។

## លោកគំនិត

មួយថ្ងៃៗជីវិតរស់នៅក្នុងលោកនៃការគិតច្រើនណាស់ ការគិតនាំអោយមានចិត្តជាអកុសល ឬជាកុសលកើតឡើង ការគិតនាំអោយមានសោមនស្ស ទោមនស្ស ឧបេក្ខា វេទនាបីនេះណាមួយកើតឡើងពុំខាន ការគិតនាំអោយមានការស្អប់ការស្រឡាញ់កើត

ឡើង ការគិតជាលោកបរមត្ថសូន្យចាកសត្វបុគ្គលអ្នកគិត ។

# ៦ _ តិកមាតិកាទី ៦

## ១. សវិតក្កសវិចារាធម្មា

ពួកធម៌ប្រកបដោយវិតក្កៈទាំងប្រកបដោយវិចារៈ

- សវិតក្កសវិចារចិត្ត ៥៥ ដួង ( កាមចិត្ត ៤៤ + បឋមជ្ឈានចិត្ត ១១ ) ។

ចេតសិក ៥០ ( វៀរវិតក្កៈវិចារៈ )

### សតិប្បដ្ឋាន

ពួកធម៌ដែលមានការត្រិះរិះពិចារណា មិនមែនមនុស្សសត្វបុគ្គលណាៗឡើយ គឺគ្រាន់តែជាចិត្តនិងចេតសិកប៉ុណ្ណោះ ។

* រាល់ការកើតឡើងនៃនាមធម៌នឹងរូបធម៌មួយខណៈៗតាមទ្វារទាំង ៦ រកតួខ្លួនឯងមិនមាន ព្រោះ

គ្រាន់តែជាផលរបស់បច្ច័យប៉ុណ្ណោះ កាលដែលកើតឡើងមិនមានផ្លូវមក កាលដែលរលត់ទៅវិញមិនមានផ្លូវទៅប្រៀបដូចផ្លេកបន្ទោរឰដ៏អាកាស កាលបើនាមរូបរកតួខ្លួនឯងមិនមានផងយ៉ាងនេះ តើមានអ្វីទៅដែលជារបស់នាមរូប ។

កាលបើខន្ធទាំងឡាយកើតឡើងហើយ ការបែកធ្លាយនៃខន្ធទាំងនោះក៏មានប្រាកដដែរ បុគ្គលល្ងង់ខ្លៅតែងក្តៅក្រហាយ និងសោយសោក ព្រោះហេតុតែថាកូនអញមានទ្រព្យអញមាន តាមពិតរកតែខ្លួនឯងមិនទាំងមានផង តើកូនទាំងឡាយមានមកពីណាទ្រព្យទាំងឡាយមានមកពីណា ។

* បុគ្គលល្ងង់ខ្លៅ គឺជាឈ្មោះនាមរូប និងអវិជ្ជាធាតុដែលអាស្រ័យនឹងនាមរូប ។

* ការក្តៅក្រហាយសោយសោកគឺជា ទុក្ខសច្ចៈ ។

* កូនរបស់អញមានទ្រព្យរបស់អញមាន

គឺជាតួនៃតណ្ហាឧបាទាន ។

* អត្តាហិអត្តនោនត្ថិ ខ្លួនមិនមានខ្លួន គឺជាសភាពពិតនៃនាមរូបដែលបច្ច័យតាក់តែងអោយកើតឡើង

- នាមធម៌ជាធាតុដឹងអារម្មណ៍អាស្រ័យនាមធម៌ដែលរលត់ទៅមុនជាបច្ច័យផង អាស្រ័យវត្ថុរូបផង ព្រមទាំងបច្ច័យផ្សេងៗទៀតផងទើបកើតឡើងជាសភាវៈមិនមែនសត្វ

- រូបធម៌ជាធាតុមិនដឹង អាស្រ័យសមុដ្ឋានគឺកម្មចិត្តឧតុអាហារកើតឡើង ព្រមដោយធាតុដី ទឹក ភ្លើងខ្យល់ ។ នាមរូបប្រជុំរួមគ្នាសន្មតិថាសត្វ បុគ្គល ប៉ុន្តែនាមរូបរកតែខ្លួនឯងមិនមានប្រៀបបីដូចពន្លឺថ្ងៃ ឬពន្លឺប្រទីប ឬក៏ចំហាយកំដៅនៃភ្លើង ដែលរកភាពទៀងទាត់ដោយខ្លួនឯងមិនមាន ។

ពន្លឺប្រទីបមិនមានអ្វីជារបស់ខ្លួន ទាំងមិនមានអ្វីជាភារៈនៃខ្លួនឯងយ៉ាងណានាមរូបក៏យ៉ាងនោះដែរ ។

សកម្មភាពនៃការហ្លួងហែងមិនមានព្រោះមិនមានឧបាទាន ការប្រកាន់ហ្លួងហែងថា នុ៎ះរបស់អញមិនមាន គឺមិនមានតណ្ហា អវិជ្ជារលត់អស់មិនមាននៅសល់ព្រោះវិជ្ជាកើតឡើង ព្រះអរហត្តមគ្គ លះអស់នូវអវិជ្ជាតណ្ហាឧបាទានដូច្នេះទើបព្រះខីណាស្រពលែងតាក់តែងនូវអភិសង្ខារគឺសកម្មភាពនៃឧបាទាន អភិសង្ខារគឺកម្មមិនមាន វិញ្ញាណមិនប្រាកដគឺមិនមានបដិសន្ធិចិត្តដែលជាវិបាករបស់កម្ម បើវិញ្ញាណមិនមាន នាមរូបក៏មិនមានសឡាយតនៈ ក៏មិនមាន ។ ល ។ ជាតិជរាមរណៈនិងគំនរទុក្ខទាំងអស់ក៏មិនមាន នេះជាទីបំផុតទុក្ខគឺទុក្ខនិរោធៈបានដល់ព្រះនិព្វាន ។

* មគ្គបដិបទាដែលបានអោយដល់នូវទុក្ខនិរោធជាគ្រូរំលត់នូវឆន្ទរាគៈ ធ្វើទីបំផុតនៃទុក្ខអោយជាក់ច្បាស់នេះគឺមគ្គសច្ចៈ ។

## ២ - អវិតក្កវិចារមត្តា ធម្មា

ពួកធម៌មិនមានវិតក្កៈ មានតែវិចារៈ បានដល់ :

- ទុតិយជ្ឈានចិត្ត ១១ និងចេតសិក ៣៦ ( វៀរវិចារៈ ) ព្រមទាំងវិតក្កចេតសិកទាំងអស់ក្នុងចិត្ត ៥៥ ផង ។

### សាធិប្បដ្ឋាន

នាមរូបកើតមាន ព្រោះមានវិញ្ញាណជាបច្ច័យ សូម្បីនៅក្នុងគភ៌នៃមាតា បើវិញ្ញាណរលត់នាមរូប ក៏មិនអាចចំរើនដុះដាលបានឡើយ ដូច្នេះគប្បីឃើញថា នាមរូបកើតមានព្រោះវិញ្ញាណជាបច្ច័យ បើមិនមានបដិសន្ធិវិញ្ញាណទេនោះ ក៏មិនមាននាមរូបប្រព្រឹត្តទៅបានដែរនៅក្នុងផ្ទៃនៃមាតានោះ ។

បដិសន្ធិវិញ្ញាណមិនមែនជាវិញ្ញាណនៃមាតាបីតា ឬក៏វិញ្ញាណនៃបុគ្គលណាឡើយ ជាធម្មតាបើមិនមាន

វិញ្ញាណមួយមុនរលត់ទៅហើយជាបច្ច័យទេ ក៏មិនមានវិញ្ញាណជាខណៈមួយទៀតអាចកើតឡើងបានឡើយ ។ បដិសន្ធិវិញ្ញាណបានកើតបន្តអំពីវិញ្ញាណចុងក្រោយនៃជាតិមុន ដោយកម្លាំងកម្មណាមួយចាត់ចែងអោយកើតបន្តក្នុងទុគ្គតិភពឬសុគតិភព ។

* មាតា បិតាបង្កើតកូនបានមែន ប៉ុន្តែមិនអាចបង្កើតវិញ្ញាណកូនបានឡើយ គឺថាទាំងវិញ្ញាណទាំងនាមរូបខណៈបដិសន្ធិកើតឡើងដោយកម្លាំងកម្មណាមួយជាកុសល ឬអកុសលកម្មជា កម្មប្បច្ច័យ ពុំមានអត្តាព្រលឹងតួខ្លួនស្មុះអន្ទោលទៅកើតទៀត ឬដាច់សូន្យឡើយ

មាតា បិតាអាចទូន្មានប្រៀនប្រដៅកូនប្រុសស្រីបាន តែមិនអាចហ្លួងហែងបញ្ញាកូនបានជាដាច់ខាតដូច្នេះត្រូវមាតា បិតាស្គាល់អោយច្បាស់ថាអ្វីជាកូន អ្វីជាបញ្ញាកូន ។

## ៣ - អវិតក្កាវិចារធម្មា

ពួកធម៌មិនមានវិតក្កៈទាំងមិនមានវិចារៈ បានដល់

- ទ្វិបញ្ចវិញ្ញាណចិត្ត ១០

ឈានចិត្ត ៥៥ ចាប់អំពីតតិយជ្ឈានចិត្តឡើងទៅ

- ចេតសិក ៣៦ និងវិចារចេតសិកទុតិយជ្ឈាន ព្រមទាំងរូប ២៨ និព្វាន ។

* វិចារចេតសិកនៅក្នុងចិត្ត ៥៥ ដែលប្រកប ជាមួយវិតក្កៈជាតិកវិមុត្តិក្នុងតិកមាតិកាទី ៦ ។

**សតិប្បដ្ឋាន**

ហ្នឹងឯងជីវិត សំរេចតាមសេចក្ដីពិតរបស់បច្ច័យ បុគ្គលណាបានដឹងច្បាស់នូវភាពពិតនៃជីវិតដោយ បញ្ញាដ៏ប្រពៃបុគ្គលនោះ អាចកាត់បន្ថយនូវសេចក្ដី កង្វល់ ការហួងហែងតាមកម្លាំងនៃបញ្ញា ។

ជាតិត្រកូល ទ្រព្យសម្បត្តិមិនមែនជារបស់ប្រសើរ

សំខាន់សំរាប់ជីវិតទេ តែវាជាវត្ថុសំរាប់សម្លាប់អ្នកដែលល្ងង់ខ្លៅមិនមានបញ្ញាឃើញការពិត ហើយវង្វេងស្រឡាញ់ជាប់ជំពាក់ជាមួយនឹងវា ។ របស់ដែលគួរអោយខ្លាចណាស់នោះ គឺរបស់ណាដែលយើងស្រឡាញ់ជាប់ជំពាក់ ព្រោះថាសេចក្តីទុក្ខកើតមកអំពីការស្រឡាញ់ជាប់ជំពាក់ ។ បញ្ញា ស្មារតីប្រព្រឹត្តទៅដើម្បីអរិយមគ្គអង្គ ៨ ទើបជារបស់ប្រសើរថ្លៃថ្លាព្រោះជាផ្លូវដែលបានធ្វើអោយជាក់ច្បាស់នូវព្រះនិព្វានជាទីក្សេមចាកយោគៈអ្នកមាន អ្នកក្រ អ្នកល្អ អ្នកអាក្រក់ ជាដើមគ្រាន់តែសន្មតិប៉ុណ្ណោះ ប៉ុន្តែសេចក្តីពិតគឺ ÷ ជីវិតជាអ្នកដែលត្រូវប្រហារជីវិត ជីវិតត្រឹមតែជាអ្នកមានទោសយ៉ាងធ្ងន់ត្រូវទទួលនូវទារុណកម្មសព្វបែបយ៉ាងដែលក្នុងនោះមានមហាទារុណកម្មមួយគឺ «ស្នេហា» ស្នេហាជាបីសាចធ្វើអោយជីវិតទៅជាវង្វេងឆ្កួត ។

* នាមរូប ជាពន្ធនាគារក្នុងសង្សារវដ្តៈ សេចក្ដីប្រកាន់មាំចំពោះនាមរូប គឺជាការជាប់នៅក្នុងពន្ធនាគារ ។

* វិញ្ញាណដូចការចាក់ដោយលំពែង នាមរូបដូចមុខរបួស កងទុក្ខដូចការឈឺនូវមុខរបួស ដូច្នោះឯង ។

# ៧ _ តិកមាតិកាទី ៧

## ១. បីតិសហគតា ធម្មា

ពួកធម៌ប្រព្រឹត្តទៅជាមួយនឹង បីតិ បានដល់

- បីតិសហគតចិត្ត ៥១

ចេតសិក ៤៦ ( វៀរទោចតុកៈ ៤ វិចិកិច្ឆាបីតិ ) ពាក្យថាប្រព្រឹត្តទៅក្នុងទីនេះគឺសម្បយុត្តធម៌ ពួកធម៌ដែលប្រកបជាមួយបីតិក្តី បីតិក្តីគ្រាន់តែជាសភាវធម៌ពិតមិនទៀង មានបច្ច័យប្រជុំតាក់តែង តែងអស់ទៅសូន្យទៅ ។

### សតិប្បដ្ឋាន

នៅពេលដែលយើងគិតនឹករឿងអ្វីមួយ ការនឹកនំាអោយគាប់ចិត្តក៏មានទាស់ចិត្តក៏មាន ឬការនឹកគិតនំាអោយកើតការជ្រះថ្លាក្នុងកុសលផ្សេងៗក៏មាន សតិថ្នាក់នឹកគិត មានរឿងគិតជាអារម្មណ៍នំាអោយជ្រះថ្លា តែសតិថ្នាក់សតិប្បដ្ឋានវិបស្សនា មាននាមធម៌គិតជា

អារម្មណ៍ បញ្ញាឃើញច្បាស់ថាការគិតនឹកមានប្រាកដ ប៉ុន្តែរឿងដែលគិតក្តី សត្វបុគ្គលជាអ្នកគិតក្តីពុំមានដោយបរមត្ថឡើយ ។

ខ្លួនយើងក្តី ទ្រព្យរបស់យើងក្តី មានព្រមជាមួយការគិតនឹកកើតឡើង ហើយក៏មិនមាន ព្រមពេលជាមួយនឹងការគិតនឹករលត់ទៅវិញដែរ បានន័យថាខ្លួនយើងក្តីទ្រព្យរបស់យើងក្តីមិនមានយ៉ាងដទៃផ្សេងពីការគិតឡើយ ហើយក៏មិនមែនជាការគិតនឹកហ្នឹងដែរ ។

* ចិត្តនឹកគិតថាជាផ្ទះរបស់យើងផ្សេង ផ្ទះរបស់អ្នកដទៃផ្សេង ត្រូវតាមសម្មតិសច្ចៈ ប៉ុន្តែរូបសំលេងក្លិនរសផោដ្ឋព្វៈ មាននាទីត្រឹមតែជាអារម្មណ៍នៃបញ្ច-វិញ្ញាណ តាមវិស័យផ្សេងៗគ្នាប៉ុណ្ណោះ ដូចជាវណ្ណរូបមានកិច្ចនាទីធ្វើជាអារម្មណ៍អោយចក្ខុវិញ្ញាណដោយមិនចំពោះថាចក្ខុវិញ្ញាណនៃមនុស្ស សត្វ ម្ចាស់ឬមិនមែនម្ចាស់នោះឡើយ ហើយចក្ខុវិញ្ញាណនោះសោត ក៏មិន

មែនជាមនុស្ស សត្វ បុគ្គលណាទាំងអស់ ចក្ខុវិញ្ញាណជាវិញ្ញាណក្ខន្ធជាមនាយតនៈ ជាទុក្ខសច្ចៈជាមនិន្ទ្រីយ៍ ជាវិបាកធម៌ ព្រោះកម្មជាបច្ច័យ សតិរលឹកបានឈ្មោះថា ចិត្តានុបស្សនា សតិប្បដ្ឋាន ។ រូបធម៌នាមធម៌ជាសង្ខត មានការកើត ហើយវិនាសទៅវិញ ស្មើគ្នាជាបរមត្ថសច្ចៈ ។

## ២ - សុខសហគតា ធម្មា

ពួកធម៌ប្រព្រឹត្តទៅ ជាមួយនឹងសុខវេទនា គឺ ÷

- សុខសហគតចិត្ត ៦៣

ចេតសិក ៤៦ ( វៀរទោចតុកៈ វិចិកិច្ឆា និងសុខវេទនា ៦៣ )

* សុខវេទនាដែលកើតក្នុងចិត្ត ៦៣ មិនប្រកបជាមួយសុខវេទនាឡើយ ហើយចិត្ត ៦៣ និងចេតសិក ៤៦ ដែលប្រកបជាមួយនោះក៏មិនមែនជាយើងដែរ ។

# សតិប្បដ្ឋាន

សុខផ្លូវកាយ សប្បាយផ្លូវចិត្ត គឺជាប្រភេទនៃនាមធម៌ម៉្យាងដែលមិនគួរប្រមាទធ្វេសប្រហែស ។

សុខវេទនាផ្លូវកាយគឺជាកុសលវិបាកដែលកើតឡើង ព្រោះកុសលកម្មជាបច្ច័យមិនទៀង ជាទុក្ខមិនមែនជាតួខ្លួនឡើយ សតិរលឹកត្រង់លក្ខណៈដែលកំពុងប្រាកដ គឺវេទនានុបស្សនា ។

* ទិដ្ឋិប្រកាន់ថាតួខ្លួនជាអ្នកធ្វើសុខវេទនាអោយកើតឡើង តណ្ហាស្វែងរកសុខ ហើយប្រកាន់ថាសេចក្តីសុខរបស់យើង ប៉ុន្តែសុខទុក្ខកើតពីផស្សៈ ជាបច្ច័យបច្ចុប្បន្ន រួចក៏រលត់បាត់ទៅវិញភ្លាម ។

ដែលថានោះជារបស់យើង គឺគ្រាន់តែជាតណ្ហាប៉ុណ្ណោះ សតិរលឹកត្រង់លក្ខណៈនៃតណ្ហា ទើបដឹងច្បាស់ថា អ្វីៗជារបស់ខ្លួនមិនមានគឺមានត្រឹមតែជាតណ្ហាប៉ុណ្ណោះ ។

* សោមនស្សវេទនា គឺសប្បាយផ្លូវចិត្តដោយអកុសលក៏មានដោយកុសលក៏មាន ។

* សត្វលោកលំបាកយ៉ាកយ៉ាប់ក្នុងការស្វែងរកសេចក្តីសុខ ។

* សុខវេទនាបៀតបៀនសត្វលោក ធ្វើអោយសត្វលោកលំបាកក្នុងការស្វែងរកវា ។

* សុខវេទនាបោកបញ្ឆោតសត្វលោក ធ្វើអោយសត្វលោកជាប់ក្នុងវដ្តទុក្ខអស់កាលយូរ ។

## ៣ - ឧបេក្ខាសហាគតា ធម្មា

ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនាបានដល់-ឧបេក្ខាសហាគតចិត្ត ៥៥

ចេតសិក ៤៦ ( វៀរទោចតុកៈបីតិ និងឧបេក្ខាវេទនា ៥៥ )

* តិកៈវិមុត្តិនៃមាតិកាទី ៧ គឺ ៖

- ទុក្ខសហាគតចិត្ត ៣ ដួង ចេតសិក ២២ ។

- សោមនស្សវេទនាដែលមិនប្រកបដោយបីតិ ក្នុងចិត្ត ១១ សុខវេទនាកុសលវិបាក ១ ។

- ឧបេក្ខាវេទនា ៥៥

- រូប ២៨ និព្វាន ។

ពួកធម៌ក្នុងតិកវិមុត្តិនេះ មិនប្រកបដោយបីតិផង សុខផងឧបេក្ខាផង ។

## សតិប្បដ្ឋាន

បច្ច័យ ៤ មានគ្រឿងស្លៀកពាក់ដណ្តប់ អាហារ បរិភោគជាដើម សំរាប់ដោះស្រាយនូវទុក្ខលំបាក ផ្លូវកាយ តែមិនអាចដោះស្រាយសេចក្តីទុក្ខផ្លូវចិត្ត បានឡើយ ព្រោះសេចក្តីទុក្ខផ្លូវចិត្ត មានតណ្ហាជាហេតុ ជាសមុដ្ឋាន ។

* បុគ្គលមានទ្រព្យសម្បត្តិច្រើនប៉ុណ្ណាក៏ដោយ អោយតែមិនមានបញ្ញា មិនអាចថាមិនកង្វល់ មិនហ្មង ហែងបានឡើយ ហើយក៏រមែងបានដល់នូវសេចក្តីទុក្ខ

ក្នុងរបស់ដែលហួងហែងនោះឯងនេះគឺទុក្ខតាមផ្លូវចិត្ត។

* យើងចង់បានរបស់អ្វីមួយដោយអំណាចលោភៈ ដើម្បីអោយបាននូវរបស់នោះពិតៗគឺទាល់តែលែងចង់បានវា ព្រោះលោភៈដែលជាការចង់បាននោះមិនមែនអស់ទៅដោយសារការបាននូវវត្ថុបំណងនោះឡើយ ហើយផលាបណាការចង់បាននូវតែមានឬរឹតតែច្រើននោះ ផលាបនោះការខ្វះឬការក្រខ្សត់នៅតែមានឬរឹតតែខ្វះខាតច្រើនតាមកម្លាំងនៃលោភៈដែរ

* សម្បត្តិក្នុងលោកទាល់តែបញ្ញាទើបឆ្អែត ។

# ៨ _ តិកមាតិកាទី ៨

## ១. ទស្សនេន បហាតព្វា ធម្មា

ពួកធម៌ត្រូវលះដោយទស្សនៈ បានដល់

- លោភចិត្ត ៤ ដួងដែលប្រកបដោយទិដ្ឋិ ចេតសិក ២១

- មោហចិត្ត ១ ដួងដែលប្រកបដោយវិចិកិច្ឆា ចេតសិក ១៥ ។

## ២ _ ភាវនាយ បហាតព្វា ធម្មា

ពួកធម៌ត្រូវលះដោយភាវនា បានដល់ :

- មោហចិត្ត ១ ដួង ដែលប្រកបដោយឧទ្ធច្ចៈ ចេតសិក ១៥

* ចំណែកអកុសលចិត្តប្បាទ ៦ ដួងទៀតត្រូវលះដោយទស្សនៈក៏មាន ត្រូវលះដោយភាវនាក៏មាន ។

**ចំណាំ** - អកុសលចិត្ត ៦ ដួងនេះបើលះដោយទស្សនៈ ត្រូវមានចេតសិក ២៥ តែបើលះដោយភាវនាវិញ ត្រូវមានចេតសិកតែ ២៣ ប៉ុណ្ណោះ ព្រោះឥស្សាមច្ឆរិយលះដោយទស្សនៈអស់ទៅហើយ ។ ពាក្យថាទស្សនៈប្រែថាឃើញបានដល់សោតាបត្តិមគ្គ ភាវនាចំរើនគឺមគ្គ ៣ ខាងលើ ។

## សតិប្បដ្ឋាន

សោតាបត្តិមគ្គឈ្មោះថា ទស្សនៈ គឺព្រោះបាន ឃើញនូវព្រះនិព្វាន ហើយលះនូវអកុសលធម៌ ជាការ មិនធ្លាប់បានឃើញមកក្នុងសង្សារវដ្ត

* អរិយមគ្គកើតឡើង ព្រោះឧបនិស្ស័យនៃ វិបស្សនា ។

* វិបស្សនាក៏ព្រោះអាស្រ័យហេតុ បច្ច័យផ្សេងៗ ដែលពុំមានបរមត្ថជាសត្វ បុគ្គល ដើម្បីធ្វើធម៌បង្កើតធម៌ ឡើយ ។ មានការសួរដោយច្រើនថា ៖ បដិបត្តិធម៌ដូច ម្តេច ដើម្បីអោយឆាប់ដល់ព្រះនិព្វាន សូមឆ្លើយថា ផ្លូវទៅព្រះនិព្វានគឺពិតជាមាន តែត្រង់ឆាប់ឬយូរឆ្លើយ មិនបានព្រោះជាសម្មត្តភាពនៃបញ្ញា មិនមែនជាការ បង្គាប់បញ្ញាត្រឹមតែមួយរយៈពេលនោះបានទេ ។

* សេចក្តីកង្វល់នឹងខ្លួនថាកើតមាន ជាសត្វ ជាបុគ្គល នេះគឺជាអ្នកនៅក្នុងវដ្តដោយពិត ។ បុគ្គល

ឃើញដោយបញ្ញាដ៏ប្រពៃនូវធម្មជាតិដោយពិតដែលមានចលនាក្នុងការកើតនិងចលនាក្នុងការវិនាសទៅវិញ លះបង់ការកង្វល់នឹងតួខ្លួនថាកើតមាន ធ្វើអោយមច្ចុរាជរកមើលមិនឃើញ នេះគឺជាអ្នកចេញអំពីវដ្ដៈតាមផ្លូវដ៏ប្រសើរបំផុត ពុំមានផ្លូវដទៃណាប្រសើរជាងឡើយគឺមគ្គអង្គ ៨ ។

ការអស់ជីវិតដោយចុតិចិត្តមិនមែនជាដំណើរទៅកាន់ព្រះនិព្វានឡើយ ព្រោះចុតិចិត្តមិនមែនជាអរិយមគ្គតែមានអ្នកយល់ខុសច្រើនណាស់ថា ការស្លាប់ទៅមិនកើតទៀតនៃបុគ្គលណា បុគ្គលនោះបាននូវសេចក្ដីសុខក្នុងព្រះនិព្វាន ។

* ការអស់ជីវិតគឺមរណៈគ្រាន់តែជាការបែកធ្លាយខន្ធក្នុងកំណើតមួយប៉ុណ្ណោះ ដោយពុំមែនជាការរលាស់ចោលនូវខន្ធដូចអរិយមគ្គដែលកើតឡើងនោះឡើយ ។ ដូច្នេះបញ្ចក្ខន្ធគឺមិនមែនជានិព្វានហើយចុតិក៏

មិនមែនជាផ្លូវទៅនិព្វាន ទើបបុគ្គលត្រូវបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្នដោយនៅមានជីវិតរស់ ព្រោះមានអរិយមគ្គកើតឡើងជាផ្លូវទៅនិព្វានយ៉ាងពិតប្រាកដ ។

* បុគ្គលយល់ឃើញថាមានតួខ្លួនក្រោយពីស្លាប់ទៅកើតក្នុងលោកដទៃទៀត ការយល់នេះជាសក្កាយទិដ្ឋិ ហើយការលះបង់នូវសក្កាយទិដ្ឋិនេះឯង ដោយអរិយមគ្គ ទើបជាអ្នកបានដល់នូវព្រះនិព្វានក្នុងការដែលនៅមានជីវិតនៅឡើយ ព្រោះមិនមានការត្រិះរិះថា ខ្លួនជាអ្នកនៅក្នុងលោកនេះទៀត ។

* មនុស្សលោតចុះពីលើឡានដែលកំពុងតែបើកទៅមុខ រួចហើយឡាននោះក៏ត្រូវក្រឡាប់ធ្លាក់ជ្រោះដោយមនុស្សមិនស្លាប់ ។

ឡានជាឈ្មោះនៃបញ្ចក្ខន្ធ មនុស្សជាឈ្មោះសក្កាយទិដ្ឋិ លោតចុះពីឡានជាឈ្មោះអរិយមគ្គ រួចពីស្លាប់ជាឈ្មោះបានដល់និព្វាន ឡានធ្លាក់ជ្រោះជាឈ្មោះ

ផរាមរណៈនៃបញ្ចក្ខន្ធ ។

## ៣ - នេវ ទស្សនេន នភាវនាយ បហាតព្វា ធម្មា

ពួកធម៌ដែលមិនមែនជាធម៌ត្រូវលះដោយមគ្គទាំង ៤ បានដល់ពួកធម៌ជាកុសលនិងពួកធម៌ជាអព្យាកត ។

### សតិប្បដ្ឋាន

* ធម៌ដែលត្រូវលះគឺពួកអកុសលធម៌ប៉ុណ្ណោះ ហើយពួកអកុសលធម៌នេះត្រូវលះដោយបញ្ញាពិត១ ។

* អ្នកដែលមិនបានស្តាប់ធម៌អោយយល់ចូលចិត្ត បានចោទថាព្រះពុទ្ធសាសនាដឹកនាំមនុស្សអោយក្រ ព្រោះត្រូវលះបង់នូវការស្វែងរកទ្រព្យ គេមិនបានយល់ថា មេក្រគឺលោភៈត្រូវលះបង់ដោយបញ្ញា គេមិនបានគិតអំពីការគ្រប់គ្រាន់ ឆ្អែតឆ្អន់ ធុញទ្រាន់ នឿយណាយនោះទេ តែគេគិតអំពីគូប្រជែងក្នុងការយកឈ្នះឬយកកុំអោយអ្នកណាមើលងាយគេ ។

* សូមមនុស្សលោកបានយល់ថា សូម្បីតែអត្តភាពមនុស្សនេះវាជាទារុណកម្មមួយយ៉ាងធ្ងន់ណាស់ទៅហើយ ដែលម្នាក់ៗលំបាកក្នុងការចិញ្ចឹមបីបាច់ថែទាំ មិនគួរមានការរីករាយចំពោះទារុណកម្មប្រចាំវត្ថុះឡើយ ។

* ផលវិបាករបស់កម្ម មិនមែនជាធម៌ត្រូវលះបង់ឡើយ តែត្រូវលះបង់នូវអកុសលធម៌ ព្រះអរិយបុគ្គលជាគហបតីសេដ្ឋី ជាព្រះរាជា ជាអ្នកមានសម្បត្តិច្រើនៗព្រោះថាជាសម្បត្តិកើតអំពីបុណ្យ មិនត្រូវលះដោយអរិយមគ្គទេ ។

* បុគ្គលមិនមានបញ្ញាតែងគិតលំបាកហើយចង្អៀតចង្អល់ចិត្តក្នុងការលះ ព្រោះលោភៈជាប់ជំពាក់ក្នុងរបស់ដែលគិតថាត្រូវលះ តាមពិតការលះបង់នូវឧបាទានក្ខន្ធដោយអរិយមគ្គអង្គប្រាំបីជាផ្លូវលោកុត្តរគឺលះឆន្ទរាគៈហ្នឹងឯង ឆន្ទរាគៈជាសត្រូវផ្នែកល្បួងលោម។

# ៩ _ តិកមាតិកាទី ៩

## ១. ទស្សនេន បហាតព្វហេតុកា ធម្មា

ពួកធម៌ប្រកបជាមួយហេតុដែលត្រូវលះដោយទស្សនៈ បានដល់ :

- លោភចិត្ត ៤ ដួងដែលប្រកបដោយ ទិដ្ឋិចេតសិក ២១

- មោហចិត្ត ១ ដួងដែលប្រកបដោយវិចិកិច្ឆាចេតសិក ១៤ ( វៀរមោហៈ )

* មោហចេតសិកដែលប្រកបដោយវិចិកិច្ឆាជាអហេតុកៈ ។

## ២ _ ភាវនាយ បហាតព្វហេតុកា ធម្មា

ពួកធម៌ប្រកបជាមួយហេតុដែលត្រូវលះដោយភាវនា បានដល់ - មោហចិត្ត ១ ដួងដែលប្រកបដោយឧទ្ធច្ច ចេតសិក ១៤ (វៀរមោហៈ) មោហចេត-

សិកក្នុងមោហ មូលចិត្តជា អហេតុកៈ ។

* ពាក្យថាអហេតុកៈគឺមិនមានហេតុប្រកបជាមួយ ។

* ចំណែកអកុសលចិត្តុប្បាទ ៦ ដួងទៀតសុទ្ធតែប្រកបដោយហេតុ ហើយត្រូវលះដោយទស្សនៈក៏មាន ត្រូវលះដោយភាវនាក៏មាន ។

* ពាក្យថា ចិត្តុប្បាទ គឺការកើតឡើងនៃចិត្តដែលព្រមដោយចេតសិក ព្រោះធម្មតាតែកាលណាចិត្តកើតឡើងត្រូវមានចេតសិកកើតរួម ។

* ចិត្តជាធំជាប្រធានក្នុងការដឹងអារម្មណ៍ សូម្បីមិនមានចេតសិកខ្លះ ក៏ចិត្តកើតឡើងបានដែរ តែបើមិនមានចិត្តក៏មិនមានចេតសិកណាមួយកើតឡើងបានឡើយ ។

* អារម្មណ៍ទាំងឡាយទោះជាប្រណីតយ៉ាងណាក៏ដោយ ឬស្មុគ្រស្មាញទាប ក៏មានតែចិត្តនិងចេតសិកប៉ុណ្ណោះដែលបានដឹង ។ ធម្មជាតិដឹងនូវអារម្មណ៍គ្រប់ពេលវេលាមិនមែនជាសត្វបុគ្គលឡើយ ។ អ្វីណាដែលចិត្តបានដឹង អ្វីនោះហៅថាអារម្មណ៍ អារម្មណ៍ដែលប្រាកដជាលោកដោយប្រភេទផ្សេងៗ ទោះជារូបក្តី ជានាមក្តីត្រូវកន្លងទៅដោយការបែកធ្លាយ ។ វិថីតាមទ្វារទាំង ៦ ជាវិថីចិត្ត ឬខ្សែតំណនៃចិត្តក្នុងការដឹងអារម្មណ៍ ។

* អារម្មណ៍គឺជាភ្ញៀវក្នុងលោកទាំង ៦ មានលោកភ្នែកជាដើម ចំណែកអ្នកដែលទទួលភ្ញៀវក្នុងលោក ៦ គឺចិត្តនិងចេតសិក ។

មួយថ្ងៃៗមានការទទួលភ្ញៀវច្រើនណាស់ មិនដឹងជាប៉ុណ្ណាទៅទេ តែបើការទទួលភ្ញៀវព្រមដោយ

មោហៈក៏មិនអាចដឹងនូវភ្ញៀវនោះទៅតាមសេចក្ដីពិតបានឡើយ ។

តាមពិតគឺមានសុទ្ធតែជាភ្ញៀវបរមត្ថក្នុងជីវិតរាល់ថ្ងៃ ទាំងភ្ញៀវក្នុងភ្ញៀវក្រៅ ទាំងភ្ញៀវមានរូប ភ្ញៀវអត់រូប ។

## ៣ - នេវ ទស្សនេន នភាវនាយ
## បហាតព្វហេតុកា ធម្មា

ធម៌ទាំងឡាយដែលមិនមែនជាពួកធម៌មានហេតុត្រូវលះដោយមគ្គ ៤ គឺ ៖

- ពួកធម៌ជាកុសល និងពួកធម៌ជាអព្យាកត ។
- មោហចេតសិកក្នុងមោហមូលចិត្ត ២ ដួង ។

### សតិប្បដ្ឋាន

* បុគ្គលចាប់ផងកាំបិតចិតបន្លែមិនមែនដើម្បីអោយសឹកផងទេ គឺដើម្បីធ្វើការងារតែប៉ុណ្ណោះ ប៉ុន្តែ

ជាធម្មតា រាល់ពេលធ្វើការងារដោយកាំបិត ផងកាំបិត រមែងសឹកបន្តិចម្តងៗ ព្រោះការចាប់កាន់ផងរឿយៗ ។ យ៉ាងណាមិញសតិរលឹកលក្ខណៈនៃរូបធម៌ ឬនាមធម៌ មិនមែនដើម្បីអោយអស់អាសវក្កិលេសនោះទេ តែគឺ ដើម្បីការដឹងច្បាស់ដោយបញ្ញាចំពោះសភាវធម៌ពិត ។ ពិតមែនតែកិច្ចការងាររបស់សតិ វិបស្សនា ដើម្បីការ ចាក់ធ្លុះតាមពិតនូវលក្ខណៈនៃនាមរូប ប៉ុន្តែការសឹករិច រិលនៃអាសវក្កិលេសបន្តិចៗទៅតាមសតិ វិបស្សនា ដូចជាការសឹកផងកាំបិតដែរ រហូតសឹកដាច់អស់ដោយ អរហត្តមគ្គ ។

* ក្នុងខណៈសតិរលឹកបាននូវសភាវធម៌ ប្រៀប ដូចការចាប់ផងកាំបិត យើងមិនត្រូវចង់អោយអស់នូវ អាសវក្កិលេសភ្លាមៗនោះទេ តែបើមានការចង់យ៉ាង នេះកើតឡើង ក៏សតិស្មារតីមានចំពោះការចង់ដោយ រលឹកដឹងហើយឃើញតាមសេចក្តីពិតថា ការចង់អោយ

អស់កិលេសនេះ វាជានាមធម៌ប៉ុណ្ណោះ មិនមែនយើងជាអ្នកចង់ទេ ។

* ការសំខាន់ គឺរលឹកដឹងបាននូវសភាវធម៌ក្នុងជីវិតប្រចាំថ្ងៃត្រូវតែឃើញថាមិនមែនយើង មិនមែនសត្វបុគ្គលអោយបានច្បាស់ ។

## ១០ – តិកមាតិកាទី ១០

### ១. អាចយគាមិនោ ធម្មា

ពួកធម៌ដល់នូវការសន្សំកពូន គឺជាហេតុនាំអោយបដិសន្ធិ បានដល់ - កុសលចិត្ត ជាលោកិយ ១៧ ចេតសិក ៣៨

- អកុសលចិត្ត ១២ និង ចេតសិក ២៧ ។

* មោហាមូលចិត្តឧទ្ធច្ចសម្បយុត្តមិននាំអោយមានវិបាកបដិសន្ធិទេ តែនាំអោយមានវិបាកក្នុងបវត្តិកាល ។ ចិត្តុប្បាទនេះក៏ឈ្មោះថាពួកធម៌សន្សំកពូនដែរ ។

# សតិប្បដ្ឋាន

* បុគ្គលដឹងនូវកំហុសរបស់ខ្លួន ហើយលះបង់នូវកំហុសនោះចោលជាការល្អប្រពៃ ។

ក្នុងបណ្តាកំហុសទាំងឡាយអំពើដែលនាំអោយមានបដិសន្ធិជាកំហុសមួយធ្ងន់ណាស់ ។

ជីវិតគឺជាទារុណកម្មដែលជាផលវិបាកនៃកំហុស ព្រោះថា ជីវិតជាទុក្ខដោយការកើតចាស់ឈឺស្លាប់ ។

ជីវិតជាទុក្ខស្មើៗសន្មតិថា ១០ កាលណាមានសេចក្តីសោកខ្សឹកខ្សួល ទុក្ខទោមនស្សនិងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏ជីវិតជាទុក្ខខ្លាំងលើស ឬថាច្រើនជាង ១០ ប៉ុន្តែអាស្រ័យសុខសោមនស្ស ទុក្ខក៏ថយចុះមកត្រឹម ៩ ឬ ៨ សេចក្តីនេះសត្វលោកសំគាល់ថាជីវិតជាសុខ តាមពិតជីវិតនៅតែជាទុក្ខ ហេតុនេះបុគ្គលមិនគួរស្វែងរកសុខក្នុងទុក្ខ ដូចជាការស្វែងរកត្រជាក់ក្នុងភ្លើងឬការស្វែងរកម្លប់ក្នុងទីវាលនោះឡើយ ។

សុខដ៏ពិតប្រាកដ មិនមែននៅលើការសោយអារម្មណ៍ជាសុខនោះទេ តែសុខពិតគឺនៅត្រង់មិនមានភាពប្រែប្រួលមិនមានទុក្ខជាទីបំផុត មានតែសុខចំណែកមួយ សុខនោះមិនចេះប្រែប្រួល ព្រោះមិនមែនជាសភាវធម៌ដែលបច្ច័យប្រជុំតាក់តែងឡើយ គឺជាសុខផុយពីទុក្ខមិនមានជាតិជរាមរណៈ ។

## ២ - អបចយគាមិនោ ធម្មា

ពួកធម៌មិនសន្សំកព្វូន គឺជាធម៌អោយដល់នូវព្រះនិព្វាន បានដល់មគ្គ ៤ ជាលោកុត្តរ

- លោកុត្តរកុសលចិត្ត ២០ ចេតសិកសម្បយុត្ត ៣៦ ។

### សតិប្បដ្ឋាន

* ផ្លូវនៅក្នុងលោកជាផ្លូវទឹក ផ្លូវគោក ឬផ្លូវអាកាស មិនមែនជាផ្លូវចេញអំពីទុក្ខបានឡើយ ព្រោះមិនផុតពីបញ្ចក្ខន្ធ សូម្បីផ្លូវជាកុសលកម្មក្នុងលោកិយ

ជាផ្លូវទៅកាន់ទេវលោកក៏ដោយ ឬព្រហ្មលោកក៏ដោយ ក៏ចេញមិនផុតពីខន្ធដែរ ទោះបីជាបុគ្គលមានរិទ្ធិអាចដើរមួយជំហានបានមួយចក្រវាឡហើយដើរជាច្រើនលានឆ្នាំក៏នៅក្នុងលោកដដែល កាលដែលនៅក្នុងលោកក៏នៅក្នុងទុក្ខ មានតែអរិយមគ្គអង្គ ៨ ទេ ដែលជាផ្លូវទៅរកទីបំផុតនៃលោក ។

* លោកដែលមានបណ្តោយប្រមាណ ១ ព្យាមទទឹងប្រមាណ ១ ហត្ថនេះជាលោកមិនងាយទៅអោយដល់ទីបំផុតបានឡើយ ។ ចុតិរួចបដិសន្ធិរាប់មិនបានប្រមាណមិនអស់ដោយមិនអាចដឹងនូវទីបំផុតខាងដើមបានឡើយ ហើយដំណើររបៀបនេះត្រូវលះបង់នូវអ្វីៗទាំងអស់ក្នុងអតីតកាលគំនរទឹកភ្នែក គំនរទឹកដោះមាតាគំនរឈាមច្រើនជាងទឹកសមុទ្រ គំនរឆ្អឹងធំជាងភ្នំគំនរមាតា គំនរបីតា បុត្រធីតា ភរិយា ស្វាមី ។ ល ។ គឺសុទ្ធតែច្រើនៗប្រសិនបើប្រមូលផ្តុំគ្នានោះ ។

យ៉ាងពិតប្រាកដអ្វីៗនៅក្នុងបច្ចុប្បន្នជាតិនេះត្រូវតែរាប់បញ្ចូលទៅក្នុងគំនររអតីតកាលផងដែរ ព្រោះតែដំណើរនៃលោក សត្វលោកត្រូវលះបង់នូវរបស់ទាំងអស់គ្រប់យ៉ាងហើយទៅតាមកម្ម នេះព្រោះតែលោកសមុទយៈ ។

* លោកសមុទយៈគឺតណ្ហាសេចក្តីប្រាថ្នាមិនចេះគ្រប់ការស្រេកឃ្លានមិនចេះឆ្អែត ការមិនអស់អាល័យធាតុនាំអោយមានកម្មនេះគឺហេតុនាំអោយកើតលោក។

* ទីបំផុតនៃលោកគឺ ៖

ព្រះនិព្វានជាលោកនិរោធ ។ លោកមិនមានព្រោះមិនមាននូវលោកសមុទយៈគឺជាលោកនិរោធ ។ លោករលត់គឺការមិនកើតឡើងនៃលោក ។

## ៣ - នេរោចយតាមិនោ នាបចយតាមិនោ ធម្មា

ពួកធមិសន្សំកពូនក៏មិនមែនមិនសន្សំកពូនក៏មិន

មែនបានដល់អព្យាកតាធម្មា ។

* ពួកធម៌ជាអព្យាកតគឺមិនមែនកុសលនិងមិនមែនអកុសល មិននាំអោយមាននូវវិបាកជាវត្ថុៈហើយក៏មិនមែនជានិយ្យានិកធម៌ដែលជាធម៌នាំសត្វចេញចាកទុក្ខដែរ ។

## សតិប្បដ្ឋាន

* ព្រះនិព្វានមិនមែនជានិយ្យានិកធម៌ ព្រោះថានិយ្យានិកធម៌គឺជាអរិយមគ្គ សត្វលោកដើរទៅកាន់ទីបំផុតទុក្ខតាមផ្លូវអរិយមគ្គ ជាសម្មាបដិបទាពិត ។

* មនុស្សងងឹតភ្នែកពីកំណើតមិនអាចមើលរូបឃើញឡើយ មានបុគ្គលដទៃម្នាក់បានយកសំពត់ក្រខ្វក់ចាស់មកនិយាយនឹងមនុស្សងងឹតភ្នែកនោះថា នេះជាសំពត់ថ្មីសល្អស្អាតអ្នកចូរយកវាទៅស្លៀកដណ្តប់ចុះ ។

មនុស្សងងឹតភ្នែកនោះបានស្លៀកដណ្តប់នូវសំពត់ចាស់ក្រខ្វក់ដោយសេចក្តីពេញចិត្តត្រេកអរីករាយ ។

លុះសម័យតមកខាងក្រោយ ពួកញាតិបានជួយព្យាបាលដោយថ្នាំពិសេស ធ្វើអោយភ្នែកលែងងងឹតក៏បានមើលឃើញច្បាស់នូវរូប ទាន់ពេលដែលមើលរូបឃើញសេចក្តីពេញចិត្តត្រេកអររីករាយចំពោះសំពត់ចាស់ក្រខ្វក់ក៏រលត់បាត់អស់ ព្រោះបានឃើញសំពត់ថ្មីសល្អស្អាត ជាសំពត់ដទៃផ្សេងអំពីសំពត់ដែលខ្លួនគាត់ស្លៀកដណ្តប់ ។

មនុស្សងងឹតភ្នែកពីកំណើតគឺជាឈ្មោះនៃបុថុជ្ជនដែលមិនមានបញ្ញាចក្ខុ ។

សំពត់ចាស់ក្រខ្វក់ជាឈ្មោះនៃឧបាទានក្ខន្ធ ៥ ការពេញចិត្តចំពោះសំពត់ចាស់ក្រខ្វក់ជាឈ្មោះឆន្ទរាគៈក្នុងឧបាទានក្ខន្ធ ៥ ការភ្លឺនូវភ្នែកជាឈ្មោះនៃបញ្ញាចក្ខុរបស់ព្រះអរិយបុគ្គល ការរលត់នូវសេចក្តីត្រេកអរពេញចិត្តចំពោះសំពត់ចាស់ក្រខ្វក់ព្រោះបានឃើញសំពត់ ថ្មីសល្អស្អាតគឺជាឈ្មោះនៃការរលាស់ចោលនូវ

ឆន្ទរាគៈដោយអរិយមគ្គអង្គ ៨ ដែលមានព្រះនិព្វានជាអារម្មណ៍ ។

អ្នកបោកបញ្ឆោតគឺជាឈ្មោះនៃចិត្តដែលជាធំ ជាប្រធានក្នុងការដឹងអារម្មណ៍ ហើយជាទីអាស្រ័យជាទីតាំងនៃឆន្ទរាគៈ ព្រោះហេតុដូច្នេះហើយបានជាក្នុងការដែលប្រកាន់ក៏រមែងប្រកាន់ចំពោះរូប វេទនា សញ្ញាសង្ខារនិងវិញ្ញាណ ។

* សេចក្តីប្រកាន់ក្នុងអ្វីណា ព្រោះតែចិត្តបានដឹងច្បាស់នូវអ្វីនោះឯង បើមិនមានចិត្តដឹងច្បាស់នូវអារម្មណ៍ទេ សេចក្តីប្រកាន់ឆន្ទរាគៈក៏មិនមានដែរ សេចក្តីប្រកាន់គឺឧបាទានជាបច្ច័យនៃការធ្វើកម្ម សត្វទាំងឡាយរមែងថោកទាប ឬខ្ពង់ខ្ពស់ព្រោះកម្មជាបច្ច័យក្នុងការបែងចែក ។

កម្មគឺជាភពព្រោះជាកន្លែងកើត កន្លែងរស់នៅនៃសត្វទាំងឡាយ ។ សត្វទាំងឡាយដែលកើតឡើងជា

ឈ្មោះឧបបត្តិភព ឧបបត្តិភពគឺជាផលវិបាករបស់កម្ម ដែលបានកើតឡើង គឺជាជាតិកំណើតនៃសត្វទាំងឡាយ ។ ជរាមរណៈសោកៈបរិទេវៈទុក្ខទោមនស្សៈនិងឧបាយាសៈ ជាផលរបស់ជាតិកំណើតដោយឧបនិស្សយប្បច្ច័យ។ ភពរលត់ព្រោះរលត់ឧបាទាន ។ ការរលត់ភពគឺជាព្រះនិព្វានជរាព្យាធិមរណៈនិងភ័យមិនមាន ក្សេមចាកទុក្ខទាំងពួង ។

## ១១ _ តិកមាតិកាទី ១១

### ១. សេក្ខា ធម្មា

ពួកធម៌ជារបស់សេក្ខបុគ្គល បានដល់ មគ្គ ៤ ជាលោកុត្តរនិងសាមញ្ញផល ៣ ខាងក្រោម

- លោកុត្តរចិត្ត ៣៥ ( វៀរអរហត្តផលចិត្ត ៥ ) និង ចេតសិកសម្បយុត្ត ៣៦ ។

# សតិប្បដ្ឋាន

* សត្វលោកគឺជាអ្នកទោសត្រូវប្រហារជីវិត តាំងតែពីបដិសន្ធិមកត្រូវអនិច្ចតាធម៌នាំទៅរកការប្រហារជីវិត ។ បុរសត្រូវពេជ្ឈឃាដនាំទៅកាន់ទីប្រហារជីវិតនៅតាមផ្លូវបានជួបកូនជាទីស្រឡាញ់ ប្រពន្ធជាទីស្រឡាញ់ ញាតិ មិត្តបងប្អូនជាទីស្រឡាញ់ បុរសជាអ្នកទោសមិនអាចនៅសប្បាយរីករាយជាមួយអ្នកដែលជាទីស្រឡាញ់ពេញចិត្តនោះបានឡើយ ។

វិថីចិត្តតាមផ្លូវភ្នែកមានរូបជាអារម្មណ៍ ហើយមិនអាចឈប់នៅឬបង្អង់នៅជាមួយរូបនោះបានទេ ត្រូវតែទៅចោលរូបនោះជារហូត មិនត្រឡប់មករករូបនោះវិញឡើយ ទោះជាអារម្មណ៍ណាៗក៏ដោយក្នុងលោកទាំងអស់ ទៅណា ? ទៅស្លាប់ ព្រោះហេតុដូចនេះមិនគួរត្រេកអរចំពោះរបស់ដែលត្រូវលះបង់ចោលនោះឡើយ ព្រោះថាគ្មានអ្វីជារបស់ខ្លួនទេ ។

* វិថីនៃជីវិតជាប់តាមខណៈចិត្តមួយខណៈៗ ។ ខណៈចិត្តមួយរលត់ទៅនាំអោយខណៈចិត្តមួយទៀតកើតបន្តមិនដាច់ តាមពិតទៅដំណើរទៅមុខនៃជីវិតសូម្បីតែខ្លួនឯងក៏យកទៅមិនបានផងគឺកើតឡើងហើយត្រូវរលត់ទៅវិញ មិនចាំបាច់ថាមានអ្វីជារបស់ខ្លួនយកទៅបាននោះឡើយ ។

* លោភៈស្រឡាញ់ជាប់ជំពាក់ក្នុងអារម្មណ៍ណាជារូបក្តី ជាសំលេងក្តី ក្លិនរសផោដ្ឋព្វៈក្តី សូម្បីតែលោភៈខ្លួនឯងក៏មិនអាចតាំងនៅបានមាំមួនផង តើមានអ្វីជារបស់ដែលលោភៈបានទៅទៀតនោះ ដូចសំលេងស្គរការពារតែខ្លួនឯងមិនបានផង តើនឹងត្រូវហួងហែងថាតួស្គរជារបស់អញ អន្លូងជារបស់អញ ឯណាបាន ។

* ការខឹងក្រោធ ឈ្លោះប្រកែកទាស់ទែង តើដើម្បីបានអ្វី? បើសភាវធម៌រកតែតួខ្លួនឯងមិនមានផង ។

## ២ - អសេក្ខា ធម្មា

ពួកធម៌ជារបស់អសេក្ខបុគ្គល បានដល់អរហត្តផល

- អរហត្តផលវិបាកចិត្ត ៥ និងចេតសិកសម្បយុត្ត ៣៦

### សតិប្បដ្ឋាន

* ធម្មជាតិណាដែលមានការកើតឡើងជាធម្មតា ធម្មជាតិនោះរមែងវិនាសទៅវិញជាធម្មតា ។ ការសិក្សាដោយសីលសមាធិបញ្ញាជាសិក្ខារបស់ព្រះសេក្ខបុគ្គលក្នុងការត្រាស់ដឹងនូវអរិយសច្ចធម៌ ។

បញ្ញាចក្ខុឃើញសង្ខារធម៌មានការកើតឡើងនិងវិនាសសូន្យទៅវិញជាធម្មតា បញ្ញាដល់នូវការចាក់ធ្លុះសច្ចធម៌ពិត ព្រោះការមិនដឹងនូវការកើតនិងការវិនាសនៃសង្ខារតាមពិតទើបមានតណ្ហា ជាហេតុនៃទុក្ខពិត

សេចក្ដីសោកខ្សឹកខ្សួល ទុក្ខទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្តកើតមានព្រោះតែសេចក្ដីស្រឡាញ់គឺតណ្ហា ។ តណ្ហានាំអោយកើតនូវកម្ម កម្មនាំអោយកើតនូវជាតិ ជរាមរណៈកើតមានព្រោះជាតិ

អរិយមគ្គអង្គ ៨ លះនូវអនុស័យដាច់ជាសមុច្ឆេទ ការមិនមាននូវទុក្ខព្រោះមិនមានតណ្ហាជាទុក្ខនិរោធ ។

* ទុក្ខនិរោធគឺព្រះនិព្វាន ជាអសង្ខតៈ មិនមានបច្ច័យតាក់តែង គឺមិនមានបច្ច័យតាក់តែងនូវកិលេសតណ្ហា មិនមានបច្ច័យតាក់តែងទុក្ខ ។

## ៣ - នេវសេក្ខា នាសេក្ខា ធម្មា

ពួកធម៌មិនមែនជាធម៌សេក្ខៈ មិនមែនជាធម៌អសេក្ខៈ គឺ ៖

- លោកិយចិត្ត ៨១ ចេតសិកសម្បយុត្ត ៥២ រូប ២៨ និព្វាន ។

# សតិប្បដ្ឋាន

* ភ្លើងមិនឆ្អែតដោយអុស សមុទ្រមិនឆ្អែតដោយទឹក តណ្ហាមិនឆ្អែតនិងអារម្មណ៍ដែលជាទីប្រាថ្នាត្រូវការឡើយ ។

* តណ្ហាក្នុងលោក ៦ ប្រៀបដូចខ្លា មានមាត់ ៦ ស៊ីអាហារ ៦ ប្រភេទ ខ្លាតណ្ហានេះស៊ីចំណីអាហារ គឺអារម្មណ៍ ៦ មិនចេះឆ្អែតទេ សេចក្តីសោកសេចក្តីភ័យព្រោះតណ្ហាជាបច្ច័យ បើតណ្ហាមិនមានទេ សេចក្តីសោក សេចក្តីភ័យក៏មិនមានដែរ ។

* សតិ វិបស្សនាជាគ្រឿងហាមរាំងនូវក្រសែរបស់តណ្ហា ព្រោះដឹងសភាវៈពិត ។

* សភាវធម៌កើតឡើងព្រោះអាស្រ័យបច្ច័យ គឺសុទ្ធតែត្រឹមត្រូវតាមបច្ច័យទាំងអស់ ដោយមិនចាំបាច់ចង់កុំអោយវាអញ្ចឹងទេ តែវាយ៉ាងម៉េចគឺវាអញ្ចឹងឯងកាលណាបានដឹងតាមពិតនូវសភាវៈពិតក៏មិនប្រាថ្នា

ដើម្បីកែប្រែរបស់ពិតអោយទៅជាយ៉ាងដទៃ ឬថាមិនត្រូវការស្វែងរករបស់ដទៃមកដូរជំនួសរបស់ពិតដែលកំពុងប្រាកដ នេះជាការស្ងប់ ។

# ១២ _ តិកមាតិកាទី ១២

## ១. បរិត្តា ធម្មា

ពួកធម៌មានសភាពតូចឆ្មារបានដល់កាមាវចរធម៌ គឺ៖

- កាមាវចរចិត្ត ៥៤ ចេតសិកសម្បយុត្ត ៥២ និងរូប ២៨ ។

* ពួកធម៌ជាបរិត្តៈ ព្រោះជាធម៌មានប្រមាណតិចឆាប់រហ័សក្នុងការបែកធ្លាយ មានអានុភាពតិច ។

* កាមាវចរជវនកើតបន្តគ្នាមិនច្រើនជាង ៧ ខណៈ ។

## សតិប្បដ្ឋាន

* ជាធម្មតានៃផែនដីតែងតែជាទីទទួលរងនូវការធ្លាក់ចុះនៃវត្ថុស្អាតល្អ ឬក៏ស្មោកគ្រោកជាធម្មតា ប៉ុន្តែផែនដីមិនញាប់ញ័រ ដោយការត្រេកអរឬថ្នាំងថ្នាក់ឡើយ យ៉ាងណា បញ្ញាភាវនាអាចអប់រំចិត្តអោយដូចជាផែនដីបាន គឺចិត្តមិនញាប់ញ័រដោយការត្រេកអររីករាយជាលោភៈឬថ្នាំងថ្នាក់ខឹងក្រោធឡើយ ។

ចិត្តជាធម្មជាតិដឹងអារម្មណ៍ អារម្មណ៍ប្រៀបបីដូចជាវត្ថុស្អាតល្អ ឬស្មោកគ្រោកដែលតែងតែធ្លាក់ចុះលើផែនដី ចិត្តប្រៀបបីដូចជាផែនដីដែលតែងតែទទួលដឹងនូវអារម្មណ៍តាមទ្វារទាំង ៦ ទោះបីជាចិត្តប្រភេទណាក៏ដោយ អប់រំសតិរលឹកត្រង់លក្ខណៈនៃចិត្តឃើញ ចិត្តឮ ចិត្តធុមក្លិន ចិត្តដឹងរស ចិត្តដឹងផោដ្ឋព្វៈ ឬចិត្តដឹងធម្មារម្មណ៍ បញ្ញាឃើញច្បាស់ចិត្តជាធម្មៈពិតៗដោយច្រើនក្នុងជីវិតប្រចាំថ្ងៃចិត្តជាបរិត្តៈ ឬជាកាមាវចរ

ប្រៀបបីដូចជាផែនដី ព្រោះជាធម្មជាតិមានអារម្មណ៍ ។

ពិតមែនតែចិត្តជាលោភចិត្តឬជាទោសចិត្តមោហចិត្ត ប៉ុន្តែអាស្រ័យសតិភាវនានិងបញ្ញាភាវនា រលឹកដឹងលក្ខណៈរបស់អារម្មណ៍ ដែលជាធម្មតាព្រោះមានចិត្តទើបមានអារម្មណ៍ ។

* គ្រាន់តែជាអារម្មណ៍របស់ចិត្តនិងគ្រាន់តែជាចិត្តដឹងអារម្មណ៍ ទើបការដឹងសេចក្តីពិតយ៉ាងនេះអាចលះបង់បាននូវការស្រឡាញ់ជាប់ជំពាក់ បដិឃៈថ្នាំងថ្នាក់ចេញអំពីចិត្តបាន ។

* អភិសង្ខារគឺកម្មមិនមានក្នុងផែនដីយ៉ាងធំធេងនេះ ព្រោះផែនដីមិនមាននូវអវិជ្ជាតណ្ហាឧបាទានយ៉ាងណាមិញ ចិត្តដែលមិនមាននូវអវិជ្ជាតណ្ហា ឧបាទានក៏មិនមានការតាក់តែងនូវអភិសង្ខារគឺកម្មដែរ ។

## ២ - មហគ្គតា ធម្មា

ពួកធម៌ដល់នូវសភាពធំបានដល់មហគ្គតធម៌គឺ ៖

- មហាគ្គតចិត្ត ២៧ និង ចេតសិកសម្បយុត្ត ៣៥ ។

* ធម៌ដែលឈ្មោះថាមហាគ្គតៈ ព្រោះអត្ថថាដល់នូវសភាពជាធំ ព្រោះអាចគ្របសង្កត់កិលេស ព្រោះមានផលដ៏សម្បូណ៌និងព្រោះការបន្តគ្នាបានយូរ មិនធ្លាក់ចុះភវង្គ

## សតិប្បដ្ឋាន

* ជីវិតសត្វលោកទាំងអស់មានមួយចំណែកទៅហើយ ដែលត្រូវបានទៅជាចំណីទុក្ខ គឺជាជីវិតអតីតកាល នៅមានមួយចំណែកទៀតក៏មុខតែជាចំណីទុក្ខទាំងអស់ ។

តាំងតែពីកើតទល់គ្នានឹងស្លាប់ជីវិតជាចំណីទុក្ខគ្រប់ពេល ព្រោះថាបញ្ចក្ខន្ធជាទុក្ខទំពាស៊ីនូវជីវិតសព្វសត្វ ។

* ជីវិតគឺជាទារុណកម្មព្រោះការរស់នៅសុំរាប់ធ្វើវាចំណីអោយសេចក្ដីទុក្ខ ហើយមហាទារុណកម្មនេះ

ត្រូវជ្រាបថា មិនមែនមួយជាតិឡើយ គឺរាប់អនេកជាតិមកហើយ ដោយត្រឹមតែកើតមករស់នៅអោយជាចំណីទុក្ខប៉ុណ្ណោះ ។

* ជីវិតរួចអំពីទារុណកម្មលុះត្រាតែជីវិតឈប់ត្រេកអរនឹងអារម្មណ៍ក្នុងលោក ៦ ឱ ! ជីវិតអ្នកអើក៏ល្ងង់ម្ល៉េះ អ្នកដូចជាជ្រូកស្រុកអញ្ចឹង អ្នកនៅមិនព្រមឈប់ត្រេកអរចំពោះអារម្មណ៍ក្នុងលោកដែលអ្នកបានរស់នៅនោះឡើយ អ្នកចាញ់បោកមារហើយ មារនឹងធ្វើទារុណកម្មដល់អ្នកតទៅទៀតតាមសេចក្តីប្រាថ្នា ។

* នែ ! ជីវិតខ្ញុំឈ្មោះសតិ សូមរំលឹកដាស់តឿនអ្នកថាអារម្មណ៍ក្នុងលោក ៦ ជាអន្ទាក់ទេ នែ ! ជីវិតខ្ញុំឈ្មោះបញ្ញា សូមចង្អុលប្រាប់ផ្លូវអ្នក ចូរអ្នកទៅចុះអ្នកនឹងបានដល់ទីដែលសុខពិត ។

## ៣ - អប្បមាណា ធម្មា

ពួកធម៌ប្រមាណមិនបានគឺ ÷ លោកុត្តរធម៌ទាំង

អស់ ( ៤០ , ៣៦ , និព្វាន )

* ធម៌ទាំងឡាយជាអប្បមាណៈព្រោះអត្ថថា ការប្រមាណមិនមានក្នុងធម៌នេះឡើយ ទោះជាសម្បយោគៈក្តី អារម្មណ៍ក្តី ។

- និងជាធម៌បដិសេធ បមាណធម៌ ធម៌ទាំងឡាយមានរាគៈជាដើម ធ្វើអោយមានប្រមាណឈ្មោះថា បមាណធម៌ ។

**សតិប្បដ្ឋាន**

* រូបសំលេងក្លិនរសផោដ្ឋព្វៈនិងធម្មារម្មណ៍ជាសង្ខតៈគឺ មិនមែនជាព្រះនិព្វានទេ សោមនស្សវេទនាក្តី ព្រមទាំងវេទនាផ្សេងៗទៀតក្តីក៏មិនមែនជាព្រះនិព្វាន លោភៈមិនមែននិព្វាន ខឹងក្រោធសុទ្ធតែមិនមែនជាព្រះនិព្វាន ។

* ការមានសតិ វិបស្សនាមិនជាប់ជំពាក់មិនជំអក់នៅក្នុងធម៌ជាសង្ខតៈទាំងអស់ទើបសតិ វិបស្សនា

ជាធម៌បដិបត្តិប្រព្រឹត្តទៅ ដើម្បីជាក់ច្បាស់នូវព្រះនិព្វាន។

* កិលេសមិនមែនត្រឹមតែមិនមែនជានិព្វានប៉ុណ្ណឹងទេ ថែមទាំងជាសត្រូវទៀតផង ព្រះគុណម្ចាស់ញាតិញោម ពុទ្ធបរិស័ទ បដិបត្តិធម៌មិនមែន ដើម្បីបាននូវការចំរើនលោភៈ ទោសៈ ជាដើមនោះឡើយគឺធម៌បដិបត្តិដើម្បីទៅអោយដល់ទុក្ខនិរោធ ។

# ១៣ _ តិកមាតិកាទី ១៣

## ១. បរិត្តារម្មណា ធម្មា

ពួកធម៌មានបរិត្តធម៌ជាអារម្មណ៍

- កាមាវចរវិបាកចិត្ត ២៣ បញ្ចទ្វារាវជ្ជនចិត្ត ១ និង ហសិតុប្បាទចិត្ត ១ ត្រូវជាចិត្ត ២៥ ចេតសិក ៣៣។

## ២ _ មហគ្គតារម្មណា ធម្មា

ពួកធម៌មានមហគ្គតធម៌ជាអារម្មណ៍ បានដល់ :

- វិញ្ញាណញ្ចាយតនចិត្ត ៣ និងនេវសញ្ញានាសញ្ញាយតនចិត្ត ៣ ត្រូវជា ចិត្ត ៦ ដួង ចេតសិកសម្បយុត្ត ៣០ ។

## ៣ - អប្បមាណារម្មណា ធម្មា

ពួកធម៌មានអប្បមាណធម៌ជាអារម្មណ៍ គឺ ÷

- លោកុត្តរចិត្ត ៤០ និងចេតសិកសម្បយុត្ត ៣៦ ។

* អកុសលចិត្ត ១២ មហាកុសលញ្ញាណវិប្បយុត្តចិត្ត ៤ មហាកិរិយាញ្ញាណវិប្បយុត្តចិត្ត ៤ ត្រូវជា ២០ ចិត្តនិងចេតសិកសម្បយុត្តតាមសមគួរ មានបរិត្តធម៌ជាអារម្មណ៍ក៏មាន មានមហគ្គតធម៌ជាអារម្មណ៍ក៏មាន តែមិនមានអប្បមាណធម៌ជាអារម្មណ៍ឡើយ ហើយបើចិត្តុប្បាទ ២០ ដួងនេះមានបញ្ញត្តិជាអារម្មណ៍ តិកមាតិកាទី ១៣ មិនគប្បីពោលគឺតិកវិមុត្តិ ។

- មហាកុសលញ្ញាណសម្បយុត្តចិត្ត ៤ មហាកិរិយាញ្ញាណសម្បយុត្តចិត្ត ៤ អភិញ្ញាជវនចិត្ត ២

មនោទ្វារាវជ្ជនចិត្ត ១ ត្រូវជា ១១ ចិត្តចេតសិកសម្បយុត្តតាមសមគួរ មានបរិត្តធម៌ឬមហគ្គតធម៌ ឬអប្ប-មាណធម៌ជាអារម្មណ៍ ប៉ុន្តែជាតិកវិមុត្តិ ព្រោះចិត្តប្បាទ ១១ នេះមានបញ្ញត្តិជាអារម្មណ៍ ។

- នៅចិត្តុប្បាទ ២១ ទៀតជាតិកវិមុត្តិមាន បញ្ញត្តិជាអារម្មណ៍តែម៉្យាង ។

- រូប ២៨ និងនិព្វានជា អនារម្មណៈ

## សតិប្បដ្ឋាន

* វិជានលក្ខណំ ចិត្តមានការដឹងច្បាស់នូវ អារម្មណ៍ជាលក្ខណៈ ចិត្តជាធំជាប្រធានក្នុងការដឹង អារម្មណ៍ ការដឹងច្បាស់នេះមិនមែនវិបស្សនាទេ គ្រាន់ តែជាលក្ខណៈនៃចិត្តប៉ុណ្ណោះ ។ ការដឹងច្បាស់នូវ អារម្មណ៍ប្រកបដោយទោសៈ មោហៈក៏មាន ប្រកប ដោយកុសលចេតនាថ្នាក់ទានសីល ឬអលោភៈ អទោសៈ អមោហៈ ក៏មាន ។ ល ។ ធាតុពិតទាំងអស់

នេះ តើគួរមានការត្រិះរិះថាខ្លួនអ្នកដឹងឬខ្លួននៅក្នុងរូបដែរឬទេ ? ព្រោះថាចិត្តគ្រាន់តែជាធម្មជាតិម្យ៉ាងក្នុងការដឹងអារម្មណ៍ ហើយក៏ត្រូវវិនាសគឺរលត់បាត់អស់ទៅ ដូចជាអណ្តាតប្រទីបដែលរលត់ទៅនិងមានការឆេះបន្តតែប៉ុណ្ណោះ ។ ការដឹងអារម្មណ៍ដឹងរឿងមិនមែនជាសត្វទេ ។

# ១៤ _ តិកមាតិកាទី ១៤

## ១. ហីនា ធម្មា

ពួកធម៌ថោកទាប បានដល់

- អកុសលចិត្ត ១២ និងចេតសិកសម្បយុត្ត ២៧។

* ដូចអកុសលា ធម្មាដែរ ។

### សតិប្បដ្ឋាន

* អំពើអាក្រក់របស់អ្នកដទៃវាអាក្រក់មែនហើយ តែវាមិនមែនអាក្រក់ជាងអំពើអាក្រក់របស់យើងទេ ។

* បុគ្គលខ្លាចសត្រូវខាងក្រៅដោយមិនដឹងថាសត្រូវពិតប្រាកដ គឺចិត្តបាបរបស់ខ្លួនឯង ។

* បុគ្គលខំការពារសេចក្តីស្លាប់មិនអោយកើតមានដល់ខ្លួនចំពោះហេតុការណ៍ផ្សេងៗ ប៉ុន្តែបុគ្គលម្នាក់ៗ ស្លាប់រាប់ផងមិនអស់ក្នុងសង្សារវដ្តព្រោះតែតណ្ហារបស់ខ្លួនឯង ។

* បើសិនជាបុគ្គលម្នាក់ៗ មានកញ្ចក់ឆ្លុះមើលចិត្តរបស់ខ្លួនឯងឃើញនោះមុខជាដឹងថាអ្វីដែលគួរឆ្អើម ។

* ប្រសិនបើបុគ្គលមានច្រមុះគូជាមួយចិត្ត ហើយអាចដឹងក្លិនរបស់ចិត្តបានប្រាកដជាលំបាកទ្រាំនឹងក្លិនឆ្អាបមែនទែន ។

* បុគ្គលខ្លាចភ្លើងនរក នេះមកពីមិនមានកាយបសាទគូជាមួយរាគៈទោសៈ មោហៈ បើសិនជាមានកាយវិញ្ញាណដឹងកំដៅរបស់កិលេសបានមិនចាំបាច់មានភ្លើងនរកទេ ព្រោះគេមិនទុកមេភ្លើងឡើយ ។

## ២ - មជ្ឈិមា ធម្មា

ពួកធម៌ជាកណ្ដាលបានដល់កណ្ដាលហីនៈនិង បណីត

- លោកិយកុសលចិត្ត ១៧
- លោកិយវិបាកចិត្ត ៣២
- កិរិយាចិត្ត ២០ និង ចេតសិក ៣៨ រូប ២៨ ។

## ៣ - បណីតា ធម្មា

ពួកធម៌ប្រណីតឧត្តមបានដល់លោកុត្តរធម៌គឺ

- លោកុត្តរចិត្ត ៤០ ចេតសិក ៣៦ និព្វាន ។

### សតិប្បដ្ឋាន

* អំពើល្អរបស់អ្នកដទៃ គឺល្អមែនហើយ ប៉ុន្តែពុំមែនអំពើល្អរបស់យើងទេ ។

* បុគ្គលតែងអាក់ខានក្នុងការធ្វើបុណ្យ ព្រោះតែគិតថាអាត្មាអញធ្វើអំពើល្អអោយដល់អ្នកដទៃ ប៉ុន្តែ

តាមពិត អំពើល្អតាក់តែងចិត្តរបស់ខ្លួនតែប៉ុណ្ណោះ ដោយមិនបានប្រាសចាកអំពីចិត្តឡើយ ។

* របស់អ្វីមួយដែលគ្រើម១បុគ្គលជុសខាត់រឿយ១ ក៏គង់តែរលោងស្អាតបាន យ៉ាងណាមុញចិត្តដែលគ្រោតគ្រាតដោយកិលេស បុគ្គលព្យាយាមលាងជម្រះជុសខាត់ដោយកុសលធម៌មានទានកុសលជាដើម ហើយមានប្រក្រតីអប់រំសតិប្បដ្ឋានវិបស្សនាគង់តែភ្លឺថ្លាស្អាតបរិសុទ្ធមិនខានឡើយ ។

# ១៥ _ តិកមាតិកាទី ១៥

## ១. មិច្ឆត្តនិយតា ធម្មា

ពួកធម៌មានសភាពខុសនិងទៀងគឺទៀងតែអោយផលក្នុងជាតិបន្ទាប់ស្លាប់ដោយពិតប្រាកដ

- លោភមូលចិត្តប្រកបដោយទិដ្ឋិ ៤ ដួង ចេតសិក ២១ ដែលប្រព្រឹត្តនៅក្នុងនិយតមិច្ឆាទិដ្ឋិ

- ទោសមូលចិត្ត ២ ដួង និងចេតសិក ២២ ដែលប្រព្រឹត្តនៅក្នុងអនន្តរិយកម្ម ៥ យ៉ាង

* នេះគឺគរុកម្មខាងអកុសល ។

## សតិប្បដ្ឋាន

* ពួកកម្មដែលមានសភាពដ៏ខុសនិងទៀងគឺជាទោសនៃវដ្តៈ ម្យ៉ាងដ៏សែនខ្លាំងក្លា ។ បុគ្គលមិនគួរត្រេកអរចំពោះវដ្តៈឡើយ ព្រោះវដ្តៈមានទោសដែលគួរអោយតក់ស្លុតភ័យខ្លាចណាស់ ។

វដ្តៈមានបីគឺ ÷ កិលេសវដ្តៈ ១ កម្មវដ្តៈ ១ វិបាកវដ្តៈ ១ អរិយមគ្គជាផ្លូវនាំសត្វចេញចាកអំពីវដ្តៈទើបជាផ្លូវដ៏ប្រសើរ ។

* កិលេសជាពួកធម៌សន្សំតាមតំណនៃខណៈចិត្ត ការសន្សំកិលេសច្រើនឡើងៗ ដោយអំណាចអកុសលជវន,គរុបាបកម្មកើតឡើងដោយអំណាចការសន្សំកិលេស ។

កុសលធម៌ ជាបុណ្យកុសលក្នុងការកំចាត់នូវកិលេសដែលរារាំងដំណើរចេញចាកទុក្ខ តាមពិតសតិវិបស្សនាជាទីអាស្រ័យដ៏មានកម្លាំងញុំាងកុសលកម្មថ្នាក់ក្រោមៗ មានទានសីលជាដើមអោយមានកម្លាំង ព្រោះសតិវិបស្សនាបានលះបង់នូវការមិនដឹងនូវ កិ-លេស ដូចជាកិលេសប្រភេទរារាំងការធ្វើទានជាដើម។

កិលេសមារនាំអោយបុគ្គលគិតឃើញថាការធ្វើទានរក្សាសីលជាអំពើខាតប្រយោជន៍ ខូចមុខរបរនាំអោយក្រីក្រ វិនាសទ្រព្យ តែបើកាលណាបានដឹងថានេះ ជាគំនិតប្រកបដោយទិដ្ឋិនិងតណ្ហាទេនោះ ទើបប្រជុំកម្លាំង បុណ្យច្បាំងនឹងមារ

## ២ - សម្មត្តនិយតា ធម្មា

ពួកធម៌មានសភាពត្រូវនិងទៀងគឺទៀងតែអោយផលក្នុងខណៈបន្ទាប់អំពីមគ្គចិត្តរលត់

* មគ្គចិត្តប្បាទនេះមិនបានអោយផលក្នុងវដ្តៈទេ

ព្រោះមិនមែនជាកម្មដែលកើតឡើងដោយអំណាចឧបាទាន តែជាលោកុត្តរមគ្គក្នុងការរំលត់នូវឧបាទាន គឺបានផល ។

- លោកុត្តរកុសលចិត្ត ២០ ចេតសិកសម្បយុត្ត ៣៦ ។

## ៣ - អនិយតា ធម្មា

ពួកធម៌មិនមែនជាធម៌ដែលទៀងទាំងពីរឡើយ គឺ៖

- អកុសលចិត្តុប្បាទ ១២ ( វៀរនិយតមិច្ឆាទិដ្ឋិ និងអនន្តរិយកម្ម ៥ )
- លោកិយកុសលចិត្តុប្បាទ ១៧
- អព្យាកតធម៌ទាំងអស់ ។

* ពួកធម៌ទាំងអស់នេះ មិនមែនជាមិច្ឆត្តនិយតាធម្មា មិនមែនជាសម្មត្តនិយតាធម្មាទេ ។

### សតិប្បដ្ឋាន

* បុគ្គលតែងត្រូវការសិរីសួស្ដីរំដោះគ្រោះភ័យ ដោយធ្វើពិធីផ្សេងៗ តែគ្រោះភ័យពិតប្រាកដគឺចិត្តបាប

ឯចំណែកសិរីសួស្តីគឺ បញ្ញា ។

* យើងបើកម៉ូតូជិះតាមផ្លូវពេលមួយមានគេជិះកាត់មុខដោយប្រញាប់ប្រញាល់ ធ្វើអោយយើងចាប់ហ្វ្រាំង... ពេលនោះយើងអាចខឹងសំឡឹងសំឡុកឬសំដីអាក្រក់ទៅអោយគេ ប៉ុន្តែបើមានសតិរលឹកបាននៅពេលនោះវិញ ការខឹងក្រោធពុំមានឡើយ ព្រោះមិនមានអ្វីក្រៅអំពីវិបាករបស់កម្ម ដូចជាចក្ខុវិញ្ញាណឃើញរូបក្នុងពេលនោះជាដើម ឬបើសិនចាប់ហ្វ្រាំងខ្លាំងពេកធ្វើអោយដួលរបួសនេះគឺ កាយវិញ្ញាណដែលជាអកុសលវិបាក គឺជារបស់ពិតទាំងជាទោសរបស់ខន្ធ៥

* ប្រយ័ត្នបញ្ចក្ខន្ធរូបខ្លួន ។

# ១៦ _ តិកមាតិកាទី ១៦

## ១. មគ្គារម្មណា ធម្មា

ពួកធម៌មានមគ្គជាអារម្មណ៍ បានដល់

- មនោទ្វារាវជ្ជនចិត្តដែលជាបុរេចារិកនៃបច្ចវេក្ខណញ្ញាណមានមគ្គជាអារម្មណ៍

- មហាកុសល និងមហាកិរិយាញ្ញាណសម្បយុត្តចិត្តទាំង ៨ ដួងរបស់ព្រះអរិយៈក្នុងការពិចារណាមគ្គ ។

- អភិញ្ញាកុសលចិត្ត ១ និងអភិញ្ញាកិរិយាចិត្ត ១ របស់ព្រះអរិយបុគ្គល ដែលប្រព្រឹត្តទៅក្នុងចេតោបរិយញ្ញាណបុព្វេនិវាសញ្ញាណនិងអនាគតំសញ្ញាណ ។

* ត្រូវជាចិត្ត ១១ ចេតសិក ៣៣ ( វៀរវិរតិ ៣ អប្បមញ្ញា ២ )

## សតិប្បដ្ឋាន

* នៅពេលដែលអ្នកដទៃខុសក្នុងរឿងអ្វីមួយ យើងខឹងថែមទាំងជេរប្រទេចផង ស្តីប្រដៅអោយលះបង់នូវកំហុសផង ប៉ុន្តែតើយើងមានប្រដៅខ្លួនឯងអោយលះបង់ចិត្តដែលខឹងនិងវាចាអាក្រក់ផងដែរឬទេ ?

* មនុស្សយើងគួរអប់រំមេត្តាចំពោះដល់សព្វសត្វទាំងអស់ ព្រោះពួកសត្វសុទ្ធតែត្រូវការអោយរួច ផុតអំពីទុក្ខ ម្យ៉ាងទៀតគួរអោយមេត្តា និងករុណាដល់ពពួកសត្វដែលមិនដឹងផ្លូវនៃការរួចចាកទុក្ខការព្យាបាទបៀតបៀន គឺជាអកុសលធម៌ដែលកើតអំពីលោភៈជាប់ជំពាក់ចង់បាន លោភៈគ្រាន់តែជាសភាវធម៌ពិតម្យ៉ាងមានលក្ខណៈចាប់យកប្រកាន់ជាប់នូវអារម្មណ៍ ប៉ុន្តែជាបរមត្ថធម៌សុទ្ធៗមិនមែនជាសត្វឡើយ ។

* ការមិនបាននូវអ្វីនោះ គឺពិតជាប្រសើរ ការចង់បានហើយកើតទុក្ខក្តៅក្រហាយចិត្ត ដើម្បីអោយបាននូវអ្វីណា សូម្បីបាននូវអ្វីនោះមកគឺមិនប្រសើរ ព្រោះអ្វីនោះគឺជាថ្នាំពិស ។

## ២ - មគ្គហេតុកា ធម្មា

ពួកធម៌មានមគ្គជាហេតុ

- លោកុត្តរកុសលចិត្ត ២០ ចេតសិក ២៨ មាន

ចេតសិកអង្គមគ្គ ៨ ជាហេតុ ឬថាចេតសិក ៣៦ ក៏បាន ព្រោះអង្គមគ្គ ៨ ជាបច្ច័យដល់គ្នាទៅវិញទៅមក (ន័យទី ១ ) ។

- លោកុត្តរកុសលចិត្ត ២០ ចេតសិកសម្បយុត្ត មានអលោភៈ អទោសៈបញ្ញាជាហេតុ ( ន័យទី ២ ) ។

- លោកុត្តរកុសលចិត្ត ២០ ចេតសិកសម្បយុត្ត មាន ៣៥ ដោយបញ្ញាជាហេតុផង ជាមគ្គផង ( ន័យទី ៣) ។

## សតិប្បដ្ឋាន

* សតិ វិបស្សនារមែងប្រគល់នូវពណ៌អោយទៅចក្ខុវិញ្ញាណ ព្រោះជាអារម្មណ៍នៃចក្ខុវិញ្ញាណហ្នឹងឯង ដោយមិនហួងហែងថាពណ៌ល្អឬពណ៌អាក្រក់ឡើយ ទំាងពណ៌ ទំាងចិត្តឃើញជារបស់វិនាស ។ ប្រគល់សំលេងអោយទៅសោតវិញ្ញាណ ប្រគល់ក្លិនអោយទៅឃានវិញ្ញាណ ប្រគល់រសអោយទៅ ជិវ្ហា

វិញ្ញាណ ប្រគល់ផោដ្ឋព្វៈអោយទៅកាយវិញ្ញាណ ប្រគល់ធម្មារម្មណ៏ អោយទៅមនោវិញ្ញាណក្នុងមនោទ្វារ

- ហេតុអ្វីបានជាត្រូវប្រគល់ ? ព្រោះសភាវធម៌នោះៗមានកិច្ច មាននាទីធ្វើជាអារម្មណ៍អោយវិញ្ញាណនោះៗកើតឡើង

* វិញ្ញាណកើតឡើងព្រោះអាស្រ័យអារម្មណ៍ណាៗ គឺវិញ្ញាណត្រូវតែមានអារម្មណ៍នោះៗ ដឹងនូវអារម្មណ៍នោះៗ

* វិញ្ញាណមិនមែនសត្វបុគ្គលតួខ្លួនយើង ឬអ្នកដទៃណាៗទេ កើតឡើងដឹងអារម្មណ៍រួចបែកធ្លាយទៅវិញយ៉ាងឆាប់រហ័ស ហើយទើបមានវិញ្ញាណថ្មីៗតែកើតបន្តទៀត ដូចជាអណ្តាតប្រទីប ដូច្នេះមិនគួរប្រកាន់ឈ្មោះប្រកែកទាស់ទែងគ្នាឡើយ ។

# ៣ - មគ្គាធិបតិនោ ធម្មា

ពួកធម៌មានមគ្គជាអធិបតី

- មហាកុសលចិត្ត និងមហាកិរិយាចិត្តញាណសម្បយុត្ត ៨ ដួង ចេតសិក ៣៣ មានមគ្គជាអារម្មណាធិបតិប្បច្ច័យ ក្នុងពេលព្រះអរិយបុគ្គលមានបច្ចវេក្ខណញាណ

- លោកុត្តរកុសលចិត្ត ២០ ចេតសិក ៣៥ មានបញ្ញាឬមានវីរិយជា សហជាតាធិបតិប្បច្ច័យ ។

* ពួកធម៌ក្រៅអំពីពួកធម៌ដែលមានមគ្គជាអារម្មណ៍ជាហេតុនិងជាអធិបតីគឺជាតិកវិមុត្តិទាំងអស់ ។

## សតិប្បដ្ឋាន

* ក្រៅអំពីមគ្គ ជីវិតប្រចាំថ្ងៃនៃសត្វលោកគឺមានរាគៈជាអារម្មណ៍ដ៏ជាទីគោរព និងជាហេតុផងដែរ សកម្មភាពផ្សេងៗនៃសត្វលោកប្រព្រឹត្តទៅដើម្បីស្វែង

រកអារម្មណ៍ល្អៗ របស់ល្អបូជាអោយរាគះ ។

* សត្វលោកមានការយល់ច្រឡំធំណាស់ ដែលយល់ថារាគះជាខ្លួនឬតួខ្លួនជាអ្នកត្រេកអររីករាយ តាមពិតរាគាធិបតីនេះគឺជាមេបីសាចយ៉ាងធំប្រចាំវដ្តះមានខណៈចិត្តជាទីដេកសម្ងំ បើសិនជារាគះជាខ្លួនយើង - តើអ្នកណាជាអ្នកបំរើរាគះ ដោយធ្វើនូវការងារសព្វបែបយ៉ាងដោយកាយ ដោយវាចា និងដោយចិត្តក្នុងជីវិតរាល់ថ្ងៃ ? ម្យ៉ាងទៀតយើងអាចយល់ថា យើងជាអ្នកត្រេកអរសប្បាយរីករាយ ហើយយើងពេញចិត្តត្រូវការនូវសេចក្តីសុខរបៀបបែបនេះណាស់ ទើបយើងធ្វើកម្ម ទោះបីថាកម្មនោះជាបាបក៏ដោយបុណ្យក៏ដោយក៏ចេះតែធ្វើអោយតែអាចបានសប្បាយរីករាយត្រង់នេះឯងដែលរាគះជាឧបាទានជាបច្ច័យនៃកម្ម ។

* រាគះ ត្រេកត្រអាលចំពោះសេចក្តីសុខក្នុងអារម្មណ៍ផ្សេងៗ តណ្ហាប្រាថ្នា ឧបាទានក៏ប្រកាន់មាំ

ដើម្បីអោយបានតាមប្រាថ្នាក៏នាំអោយកើតអំពើធ្វើអាក្រក់ ធ្វើល្អយ៉ាងណាដូចជាមនុស្សអត់អ្នកដឹកដៃដើរមិនត្រូវផ្លូវពិតប្រាកដ ព្រោះតែខ្លួនឯងខ្វាក់ភ្នែក ។

ត្រង់នេះហើយដែលសន្មតិថាសត្វលោកជាអ្នកបំរើតាមចំណង់នៃរាគាធិបតី ។

* សត្វលោកធ្វើជាខ្ញុំបំរើអោយចំណង់នៃរាគៈមិនត្រឹមតែមួយជាតិប៉ុណ្ណោះទេ គឺត្រូវបំរើគ្រប់ៗជាតិដរាបទាល់តែរាគាធិបតី ត្រូវស្លាប់ដោយការប្រហារនឹងដាវគឺអរហត្តមគ្គញ្ញាណ ប៉ុន្តែសត្វលោកមិនងាយស្វែងរកដាវនេះបានស្រួលៗទេ ព្រោះសត្វលោកស្ម័គ្រចិត្តចិញ្ចឹមរាគៈអោយចំរើនធំធាត់ ហើយស៊ូតាមតែនៅធ្វើការបំរើគ្មានរាថយ ។

* ដោយការចំរើនធំធាត់នៃរាគៈយ៉ាងនេះ រាគៈបានគ្រងរាជនៅក្នុងលោកទាំង ៦ អារម្មណ៍ផ្សេងៗត្រូវបានរាគៈចាប់យក មិនមានឱកាសឯណាដែលងាយ

ស្រួលសំរាប់សតិប្បដ្ឋានវិបស្សនាឡើយ ។

សត្វលោកធ្វើការតាមបញ្ជារបស់រាគៈទាំងថ្ងៃទាំងយប់ ដោយស្មោះត្រង់បំផុត សូម្បីពេលដែលត្រូវធ្លាក់នរកម្តងៗ ព្រោះតែធ្វើបាបកម្មផ្សេងៗ ដើម្បីអោយបានលាភសក្ការៈកិត្តិយសកេរ្តិ៍ឈ្មោះ សរសើរសុខយកមកបូជាអោយរាគាធិបតីនោះ ក៏មិនបាននូវទីពឹងអំពីរាគៈឡើយ យ៉ាងនេះហើយក៏ដោយក្រោយពីបានរងទុក្ខធំក្នុងនរកប្រែតរួចហើយត្រូវមកបដិសន្ធិជាមនុស្សបន្តទៀត ក៏ជាអ្នកនៅតែមិនរួញរាក្នុងការបំពេញនូវភារកិច្ចដើម្បីធ្វើខ្ញុំបំរើអោយរាគាធិបតីបីសាចវត្តុះដែរ ។

# ១៧ _ តិកមាតិកាទី ១៧

## ១. ឧប្បន្នា ធម្មា

ពួកធម៌ដែលកើតឡើងហើយ បានដល់ខន្ធ ៥ គឺ ÷

- ចិត្ត ១២១ ជាវិញ្ញាណក្ខន្ធ

- ចេតសិក ៥២ ជាខន្ធ ៣

- រូប ២៨ ជារូបក្ខន្ធ ។

* ឧប្បាទៈ ឋិតិ - ភង្គៈ នៃធម៌ហៅថា ឧប្បន្នា ធម្មា ។

## ២ - អនុប្បន្នា ធម្មា

ពួកធម៌ដែលមិនទាន់កើត

- វៀរតែវិបាកក្នុងភូមិ ៤ និងកម្មជរូបចេញ សង្ខារធម៌ដទៃទៀតជាអនាគតឈ្មោះថា អនុប្បន្នា ធម្មា ។

## ៣ - ឧប្បាទិនោ ធម្មា

ពួកធម៌ដែលប្រុងនឹងកើតឡើង បានដល់អនាគត នៃ

- វិបាកចិត្តុប្បាទទាំងអស់និងកម្មជរូបទាំងអស់ ។

* និព្វានជា តិកវិមុត្ត ព្រោះនិព្វានមិនមានការកើត

ឡើងហើយ និងមិនមែនជាអនាគតឡើយ ។

## សតិប្បដ្ឋាន

* វាត្រូវតែជួចោះឯង ព្រោះបានឃើញជាក់ស្តែង - តើចាំបាច់ម៉េចអញ្ចឹងធ្វើអ្វី ។

* ព្រមទៅទើបស្ងប់ចិត្ត - តើព្រមតាមអ្នកណា ? ឆ្លើយថា មិនមែនព្រមតាមអ្នកណានោះទេ តែគឺព្រមតាមអ្វីណាដែលជារបស់ពិតក្នុងជីវិតប្រចាំថ្ងៃ ត្រូវតែរៀនព្រមបន្តិចម្តងៗ ទោះជាកិលេសប្រកែកក៏ដោយ ។

* បើចេះតែព្រមទៅអញ្ចឹង ចុះបើលោភៈស្រឡាញ់មានតែព្រមលួចរបស់គេ ហើយបើខឹងចង់ជេរក៏ចេះតែព្រមជេរទៅឬយ៉ាងម៉េច ?

- ហ្នឹងឯងដែលថាមិនព្រម សូមជ្រាបអោយច្បាស់ថាគ្រប់តែកិលេសទាំងអស់សុទ្ធតែមិនព្រមទៅតាមសេចក្តីពិតនៃសភាវធម៌ ។

* សតិ វិបស្សនាមិនមែនព្រមបណ្តោយតាម

អំណាចនៃកិលេសនោះទេ ប៉ុន្តែសតិ វិបស្សនាព្រម ចំពោះលក្ខណៈ នៃសភាវធម៌ ។

* ១ គឺវិសេសលក្ខណៈ បានដល់លក្ខណៈ ពិសេសប្រចាំគ្រប់សភាវធម៌ ដែលផ្សេងៗអំពីគ្នា ដូចជាលោភៈមានការប្រកាន់នូវអារម្មណ៍ជាលក្ខណៈ ទោសៈកាច ឬប្រទូស្ត មោហៈមិនដឹងឬវង្វេង ចក្ខុ វិញ្ញាណមានការដឹងនូវរូប ហើយអាស្រ័យចក្ខុវត្ថុជា លក្ខណៈ ដូចនេះជាដើមដែលជាលក្ខណៈពិសេស ផ្សេងៗគ្នានៃបរមត្ថធម៌ មិនមែនជាសត្វបុគ្គលឡើយ ។

* ២ គឺសាមញ្ញលក្ខណៈ បានដល់លក្ខណៈស្មើគ្នា នៃសភាវធម៌គឺស្មើដោយត្រៃលក្ខណ៍មានលក្ខណៈមិន ទៀងជាដើម ដែលជាសង្ខតធម៌ ។

* សតិ វិបស្សនាព្រមតាមលក្ខណៈទាំងពីរយ៉ាង ទើបជាធម៌បដិបត្តិលះកិលេសមានមិច្ឆាទិដ្ឋិជាដើម ។

# ១៨ _ តិកមាតិកាទី ១៨

## ១. អតីតា ធម្មា

ពួកធម៌ជាអតីតៈ បានដល់ចិត្តចេតសិក រូប ដែលបានកន្លងទៅហើយ ។

* ពួកធម៌ដែលកន្លងទៅគឺជាទោសនៃសង្ខារធម៌

* អតីតកាលប្រៀបបីដូចជាយក្សពុំមានត្រាប្រណីក្នុងការទំពាស៊ីសព្វសត្វ ។

* អតីតកាលគឺជាទុក្ខពិត ព្រោះមិនទៀង ។

* ពេលវេលាដែលកន្លងទៅនាំយកទៅជាមួយនូវរូបវេទនា សញ្ញា សង្ខារ និងវិញ្ញាណជានិច្ចពុំមានភ្លេច ។

* អតីតកាលមានបច្ចុប្បន្នជាទីបំផុតខាងចុងតែមិនមានទីបំផុតខាងដើម ។

* បើសិនជាយល់ឃើញថាខន្ធបច្ចុប្បន្នធ្លាប់បានរស់នៅក្នុងអតីតកាល ហើយនឹងបន្តទៅរស់នៅក្នុង

អនាគតកាលទៀតនេះជាគ្រោះថ្នាក់ ។

## ២ - អនាគតា ធម្មា

ពួកធមិជាអនាគត បានដល់ចិត្តចេតសិករូប ដែលមិនទាន់មកដល់នៅឡើយ

* បុគ្គលណាមិនសង្ឃឹមអ្វីៗក្នុងអនាគត មិនសោកស្តាយអ្វីៗក្នុងអតីតៈ និងជាអ្នកឃើញស្វាត់ក្នុងផស្សៈ បុគ្គលនោះមិនត្រូវនាំទៅបានដោយមិច្ឆាទិដ្ឋិ

* សង្ឃឹមអនាគតគឺសង្ឃឹមសង្ខារដែលមិនទាន់មកដល់ស្តាយអតីតៈគឺស្តាយទុក្ខ ឯបច្ចុប្បន្នពឹងមិនបាននេះឯងដែលជាសង្ខារធមិ ។

* សេចក្តីមិនកង្វល់ព្រោះមិនប្រកាន់មាំនោះឯងជាទីពឹង ទីពឹងដទៃក្រៅអំពីនោះមិនមានទេ ព្រះតថាគតត្រាស់ហៅនូវទីពឹងនោះថាជាព្រះនិព្វាន ជាទីអស់ទៅនៃជរានិងមរណៈ អរិយមគ្គអង្គ ៨ នាំអោយបានដល់ទីពឹង ។

## ៣ - បច្ចុប្បន្នា ធម្មា

ពួកធម៌ជាបច្ចុប្បន្ន បានដល់

- ចិត្តចេតសិករូបដែលកើតឡើងហើយចំពោះមុខ ។

* ការមិនប្រកាន់នូវបច្ចុប្បន្នថាជាតួខ្លួន ថាជាសត្វបុគ្គលកំពុងរស់នៅឈ្មោះថា មិនរសេមរសាមក្នុងបច្ចុប្បន្ន ។

* ការកង្វល់ក្នុងសង្ខារឈ្មោះថាប្រាសចាកទីពឹង។

* បុគ្គលឈ្មោះថាបាននូវទីពឹង ព្រោះមិនមានកង្វល់ ។

* ការមិនមានកង្វល់គឺព្រះនិព្វាន មិនមែនជាចិត្តទេ ។

* កិលេសជាគ្រឿងកង្វល់ដែលត្រូវលះបង់ដោយអរិយមគ្គ មិនមែននិព្វានទេ ។

* ចិត្តស្អាតមិនមែននិព្វានទេ ចំណែកអរិយមគ្គក្តី អរិយផលក្តី ក៏មិនមែនព្រះនិព្វាន ប៉ុន្តែអរិយមគ្គលះបង់កិលេសជាគ្រឿងកង្វល់នាំអោយបានដល់និព្វានដែលមិនមាននូវកិលេសជាគ្រឿងកង្វល់ ។

* បច្ចុប្បន្នព្រាត់ប្រាសចាកអតីតៈ អនាគតព្រាត់ចាកបច្ចុប្បន្ន ចំណែកនិព្វានប្រាសចាកកាលទាំងបី ។

* ពុទ្ធបរិស័ទដោយច្រើនបំពេញបុណ្យកុសលហើយ ចង់អោយឆាប់បានដល់នូវព្រះនិព្វាន ព្រោះខ្លាចទុក្ខក្នុងវដ្តៈ ប៉ុន្តែទស្សនៈគឺសោតាបត្តិមគ្គមិនបានឃើញបុគ្គលណាម្នាក់ឬព្រះពុទ្ធអង្គណា សូម្បីតែមួយព្រះអង្គនៅក្នុងព្រះនិព្វាននោះឡើយ ដូច្នោះហើយទើបព្រះពុទ្ធសំដែងថា ធម៌ទាំងពួងជាអនត្តាគឺនិព្វានមិនមានសត្វ បុគ្គលណាទាំងអស់ សូម្បីសង្ខារធម៌បន្តិចបន្តួចក៏គ្មានដែរ មានតែសុខម៉្យាងគត់ ឯចំណែកសង្ខារធម៌វិញក៏មិនមែនជាសត្វបុគ្គលណាដែរ ហើយព្រះនិព្វានក៏មិន

មានក្នុងសង្ខារធម៌ គឺមានតែទុក្ខប៉ុណ្ណោះ

## ១៩ _ តិកមាតិកាទី ១៩

### ១. អតីតារម្មណា ធម្មា

ពួកធម៌មានអារម្មណ៍អតីតៈ បានដល់

- វិញ្ញាណញ្ចាយតនៈ ៣ ដួង

- នេវសញ្ញា នាសញ្ញាយតនៈ ៣ ដួង ចេតសិក ៣០

* អាកាសានញ្ចាយតនកិរិយាជាអារម្មណ៍នៃវិញ្ញាណញ្ចាយតនកិរិយាតែម្យ៉ាង ។

- អាកាសានញ្ចាយតនកុសលជាអារម្មណ៍នៃវិញ្ញាណញ្ចាយតនកុសលផង វិបាកផងកិរិយាផងក៏បាន។

- វិញ្ញាណញ្ចាយតនទាំង ៣ មិនមានអាកាសានញ្ចាយតនវិបាកជាអារម្មណ៍ឡើយ ។

* នេវសញ្ញានាសញ្ញាយតនៈមានអាកិញ្ចញ្ញាយតនៈជាអារម្មណ៍ ( ន័យដូចអរូបទី ២ ដែរ ) ។

* ចិត្ត ៦ ដួងចេតសិក ៣០ នេះមានអតីតារម្មណ៍តែម្យ៉ាង

* ពួកធម៌មានអារម្មណ៍ជាអនាគតតែម្យ៉ាងមិនមាន ។

## សតិប្បដ្ឋាន

* នាមធម៌អាចមានអារម្មណ៍អតីតៈបានព្រោះអនន្តរប្បច្ច័យ អនន្តរៈប្រែថា ៖ មិនមានចន្លោះ គឺខណៈចិត្តមុនបានរលត់ទៅហើយជាបច្ច័យដល់ខណៈចិត្តមួយទៀតអោយកើតឡើងដោយមិនមានរវាងចន្លោះ ការសន្សំសន្តានល្អឬអាក្រក់យ៉ាងណាៗត្រូវបានជម្រុញតៗតាមខណៈចិត្តដោយបច្ច័យនេះឯង ។

* ការចាំជាតិក្នុងអតីតៈ គឺជានាមធម៌បច្ចុប្បន្នដែលមានអារម្មណ៍អតីតៈ ការលើកដល់ខន្ធអនាគតក៏ជា

នាមធម៌ក្នុងបច្ចុប្បន្នដែលមានអារម្មណ៍ជាអនាគត នាមធម៌ គឺវេទនាខន្ធសញ្ញាខន្ធសង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធរួមជាមួយនឹងរូបធម៌ផងត្រូវជាខន្ធ ៥ ។

* ខន្ធ ៥ បច្ចុប្បន្នមិនមែនខន្ធ ៥ ក្នុងអតីតៈជាតិ ឬជាខន្ធ ៥ ក្នុងអនាគតជាតិឡើយ ។

* សេចក្ដីកង្វល់នឹងអតីតជាតិ និងសេចក្ដីកង្វល់នឹងអនាគតជាតិមិនមានព្រោះបញ្ញាឃើញថាខន្ធ ៥ ក្នុងបច្ចុប្បន្នមិនមែនជាខន្ធ ៥ ជាតិមុនជាតិមុខឡើយ ហើយការកង្វល់ចំពោះខន្ធ ៥ បច្ចុប្បន្នក៏មិនមានដែរ ព្រោះបញ្ញាបានប្រគល់អោយសេចក្ដីវិនាសធ្វើជាម្ចាស់នៃខន្ធ ៥ ជាបច្ចុប្បន្ននេះរួចស្រេចបាច់ហើយ ។

## ២ - អនាគតារម្មណា ធម្មា

ពួកធម៌មានអារម្មណ៍ជាអនាគត គឺបានដល់ :

* ពួកធម៌មានអារម្មណ៍ជាអនាគតតែម៉្យាងមិនមាន ។

* មហាវិបាកចិត្តុប្បាទ ៨ ដួង សន្តីរណចិត្តុប្បាទ ៣ ដួង ហសិតុប្បាទចិត្តុប្បាទ ១ ដួង ចិត្តុប្បាទ ១២ ដួងនេះ បើនៅក្នុងបញ្ចទ្វារមានអារម្មណ៍បច្ចុប្បន្ន ប៉ុន្តែក្នុងមនោទ្វារមានអារម្មណ៍គ្រប់កាលទាំង ៣ ។

* មនោទ្វារាវជ្ជនចិត្តុប្បាទ ១ ដួង កាមជវន ២៨ (វៀរហសិតុប្បាទ ១ ) អភិញ្ញា ២ ចិត្តុប្បាទ ៣១ ដួងនេះ មានអារម្មណ៍គ្រប់កាលទាំង ៣ ហើយអាច មានអារម្មណ៍ផុតចាកកាលទាំង ៣ បានគឺមានបញ្ញត្តិ និងនិព្វានជាអារម្មណ៍តាមសមគួរ ។

## សតិប្បដ្ឋាន

* វិថីចិត្តតាមបញ្ចទ្វារមានតែអារម្មណ៍ជា បច្ចុប្បន្នប៉ុណ្ណោះ ចំណែកក្នុងមនោទ្វារវិញ ចិត្តខ្លះ មានអារម្មណ៍ជាអតីតៈឬអនាគតឬបច្ចុប្បន្ន ចិត្តខ្លះ ទៀតអាចមានអារម្មណ៍ក្នុងកាលក្នុងបាន ក្រៅកាលក៏ បានចិត្ត ខ្លះទៀតមានតែអារម្មណ៍ក្រៅកាលប៉ុណ្ណោះ ។

ចំណែក ចិត្តក្រៅទ្វារមិនមានអារម្មណ៍ជាអនាគតឡើយ មានតែអតីតៈបច្ចុប្បន្ននិងបញ្ញត្តិជាអារម្មណ៍តាមសមគួរ .

- តើមានសត្វក្នុងលោក ៦ ឬទេ ?

## ៣ - បច្ចុប្បន្នារម្មណា ធម្មា

ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន បានដល់

- ទ្វិបញ្ចវិញ្ញាណ ( ១០ ដួង )
- មនោធាតុតិកៈ ( ៣ ដួង )

ចេតសិកសម្បយុត្ត ១០ ។

* ចិត្តប្បាទដែលមានបញ្ញត្តិជាអារម្មណ៍ក្តី មាននិព្វានជាអារម្មណ៍ក្តី ជា តិកវិមុត្ត ។

* រូប ២៨ និងនិព្វាន ជាធម៌មិនមានអារម្មណ៍ ។

### សតិប្បដ្ឋាន

* ក្នុងជីវិតប្រចាំថ្ងៃដែលសន្មតិថាជាបុគ្គលម្នាក់ៗ ព្រោះមានធាតុមិនដឹងនូវអារម្មណ៍ គឺរូបធាតុនិងធាតុ

ដឹងអារម្មណ៍ គឺនាមធាតុ ។ លក្ខណៈ មហាភូតរូបខាងក្រៅដូចតែខាងក្នុង ប៉ុន្តែសក្កាយទិដ្ឋិ អាស្រ័យនឹងរូបណា តាំងនៅក្នុងរូបណាក៏ប្រកាន់រូបនោះថាជាសត្វមនុស្សស្រីប្រុស ជាបុគ្គលជាតួខ្លួន ។

* នាមធាតុដឹងនូវអារម្មណ៍ជាធម្មតា មិនថាអារម្មណ៍នោះប្រភេទណាឡើយ រូបឬសំលេង ឬចិត្តចេតសិកថោកទាបប្រណីតឆ្ងាយជិតយ៉ាងណាៗនាមធាតុអាចដឹងបានទាំងអស់ សូម្បីតែព្រះនិព្វានក៏ជាអារម្មណ៍នៃនាមធាតុជំពូកខ្លះដែរ ។

* សតិ - វិបស្សនាព្រមតាមធាតុពិតនៃការដឹងអារម្មណ៍របស់នាមធម៌ ហើយដោយសារការយល់ព្រមអំពីសតិប្បដ្ឋានវិបស្សនាសេចក្តីកង្វល់តាមផ្លូវចិត្ត ក៏ត្រូវកាត់បន្ថយតាមកម្លាំងនៃការព្រមដែរ ព្រោះវាជាការធម្មតានៃការដឹងអារម្មណ៍ ប្រៀបដូចខ្យល់បក់ទោះជាបក់ត្រូវផ្កាឈើក្តី បក់ភ្លើងក្តី បក់ត្រូវមូត្រលាមកក្តី ឬ

បក់ត្រូវអ្វីៗក៏ដោយជាធម្មតារបស់ខ្យល់វាអញ្ចឹងឯង ។

* គួរឃើញនាមធម៌ដែលដឹងនូវអារម្មណ៍ ដូចជាខ្យល់ហើយលះបង់ការយល់ខុសថាតួខ្លួនជាសត្វបុគ្គលអ្នកដឹងនូវអារម្មណ៍នោះចោលចេញទៅ ។

* បើសិនការដឹងនូវអារម្មណ៍ជាតួខ្លួនមែននោះ - តើចាំបាច់ដឹងអារម្មណ៍ដែលនាំអោយកើតទុក្ខកង្វល់ធ្វើអ្វី ? ដូច្នេះបើនូវតែប្រកាន់ថាខ្លួនដឹងនូវអារម្មណ៍ផ្សេងៗនោះ គឺចាញ់សំពត់ជូតធូលីហើយ ។

* ធូលីគ្រឿងស្មោកគ្រោកជាឈ្មោះនៃអារម្មណ៍ សំពត់ជូតធូលីជាឈ្មោះនៃនាមធម៌ជាអកុសលវិបាកដឹងអារម្មណ៍មិនល្អ ។ ជាធម្មតានៃសំពត់ជូតធូលីឬជូតរបស់ស្មោកគ្រោកយ៉ាងណា ជាធម្មតានៃអកុសលវិបាកដែលជានាមធម៌ម្យ៉ាងត្រូវអកុសលកម្មជាបច្ច័យនាំអោយកើតហើយដឹងនូវអារម្មណ៍មិនល្អ ក៏យ៉ាងនោះដែរ ត្រូវតែព្រមតាមសច្ចធម៌ ។

# ២០ _ តិកមាតិកាទី ២០

## ១. អជ្ឈត្តា ធម្មា

ពួកធម៌ជាខាងក្នុង បានដល់បញ្ចក្ខន្ធជាខាងក្នុងគឺដែលសន្មតិថាខ្លួនឯង

## ២ - ពហិទ្ធា ធម្មា

ពួកធម៌ជាខាងក្រៅបានដល់បញ្ចក្ខន្ធដែលសន្មតិថាអ្នកដទៃ រូបដែលមិនជាប់ទាក់ទងនឹងឥន្ទ្រិយ៍ និព្វាន

* រូបដែលមិនជាប់ទាក់ទងនឹងឥន្ទ្រិយ៍មានដីភ្នំព្រៃឈើ សមុទ្រ ទឹកភ្លើង ។ ល ។ ដែលជារូបក្រៅអំពីមនុស្សសត្វ ។

## ៣ - អជ្ឈត្តពហិទ្ធា ធម្មា

ពួកធម៌ទាំងក្នុង ទាំងក្រៅបានដល់ចិត្ត ១២១ ដួងចេតសិក ៥២ រូប ២៨ ។

* បរមត្ថ ៣ នេះឯងដែលសន្មតិថាខ្លួនយើង ឬថា

ជាអ្នកដទៃ ប៉ុន្តែព្រោះអវិជ្ជាក៏នាំអោយមានតណ្ហា ទិដ្ឋិ មានះជាគ្រឿងនាំអោយវដ្តៈយូរ ។

## សតិប្បដ្ឋាន

* មិនការពារ មិនរក្សា មិនរវាំងប្រយ័ត្នឯណា បានបើទ្វារទាំង ៦ នេះសុទ្ធតែទ្វារជាទីចូលមកនៃសត្រូវ គឺបាបអកុសល ដើម្បីប្រមូលកម្លាំងទប់ទល់ជាមួយសតិប្បដ្ឋានវិបស្សនា ។

* ការចំរើនសតិប្បដ្ឋាន គឺជាការចំរើនអធិសីល អធិសមាធិនិងអធិបញ្ញា ព្រោះសតិប្បដ្ឋានជាផ្លូវប្រព្រឹត្តទៅ ដើម្បីសិក្សានូវអរិយសច្ចៈ ។

* កុំសង្ឃឹមថានឹងបានអ្វីអំពីសង្សារវដ្តនេះអោយសោះ បុគ្គលដែលប្រសើរបំផុតបានតែត្រឹមរួចខ្លួនប៉ុណ្ណោះទេ ។

* គោបាក់ស្នែងមិនហ៊ានអួតជល់ជាមួយគោដទៃឡើយ បុគ្គលដែលប្រសើរបំផុតក្នុងការឈ្នះគឺដូចគោ

បាក់ស្មែង.

*  មិនមានពិធីប្រជុំឯណាមួយដែលមិនព្រាត់ប្រាសគ្នាទេ ។

# ២១ _ តិកមាតិកាទី ២១

## ១. អជ្ឈត្តារម្មណា ធម្មា

ពួកធម៌មានអារម្មណ៍ជាខាងក្នុង.

- វិញ្ញាណញ្ចាយតនៈ ៣
- នេវសញ្ញានាសញ្ញាយតនៈ៣ និងចេតសិក ៣០។

* អរូបទី ២ ត្រូវមានអរូបទី ១ របស់ខ្លួនឯងជាអារម្មណ៍ អរូបទី ៤ ត្រូវមានអរូបទី ៣ របស់ខ្លួនឯងជាអារម្មណ៍ ។

ចិត្តុប្បាទ ៦ ដួងនេះមានអារម្មណ៍អជ្ឈត្តៈនិងអតីតៈ ។

* ការសំដែងអំពីរូបជ្ឈានក្តី អរូបជ្ឈានក្តី ដើម្បីអោយឃើញថា កាមាវចរធម៌ជារបស់មិនទៀងគួរមានសតិដកការប្រកាន់ហួងហែងចេញហើយបង្អោនចិត្តទៅកាន់ព្រះនិព្វានដែលក្សេមចាកទុក្ខ ព្រោះបុគ្គលកើតក្នុងទីណាៗមារតែងជាប់តាម ព្រោះអភិសង្ខារគឺកម្មមារគឺខន្ធ មារគឺអាយតនៈជាដើម ។

## ២ - ពហិទ្ធារម្មណា ធម្មា

ពួកធម៌មានអារម្មណ៍ជាខាងក្រៅ បានដល់ :

- រូបាវចរចិត្តុប្បាទ ១៥
- អាកាសានញ្ចាយតនចិត្តុប្បាទ ៣ ។

* ចិត្តុប្បាទ ១៨ ដួងនេះមានបញ្ញត្តិអាស្រ័យសភាវៈជាអារម្មណ៍ ។

- លោកុត្តរកុសលចិត្តុប្បាទ ២០ ដួងលោកុត្តរវិបាក ២០ មាននិព្វានជាអារម្មណ៍ ។

## សតិប្បដ្ឋាន

* កាលណាដកឈ្មោះចេញអស់ទៅ នៅតែបរមត្ថធម៌ជាធម៌មានលក្ខណៈផ្សេងៗដែលមានបច្ច័យតាក់តែង ។ យើងមើលឃើញអ្វីៗជាសម្ភារៈជារបស់ប្រើប្រាស់ ជាមនុស្សជាសត្វ ប៉ុន្តែវណ្ណរូបជារូបារម្មណ៍ជាបរមត្ថជាលោក ជាធម៌ដែលព្រះតថាគតទ្រង់ត្រាស់សំដែង ដើម្បីអោយសត្វលោកបានដឹង ។

* រូបក្នុងរូបថតក្តី រូបក្នុងទូរទស្សន៍ក្តី រូបទូទៅក្តី គឺគ្រាន់តែជាសភាវរូបម្យ៉ាងដែលជាអារម្មណ៍របស់ចិត្តតាមផ្លូវភ្នែក ព្រះធម៌ជួយណែនាំអោយមានសតិបញ្ញាមិនអោយវង្វេងប្រកាន់ខុសក្នុងអាយតនៈទាំងឡាយថាជាសត្វបុគ្គលឬវត្ថុនេះនោះឡើយ ។ អ្នកស្វែងរកធម៌ត្រូវអោយបានឃើញធម៌ពិតៗដែលព្រះអង្គទ្រង់ត្រាស់សំដែង ។

## ៣ - អជ្ឈត្តពហិទ្ធារម្មណា ធម្មា

ពួកធម៌មានអារម្មណ៍ទាំងក្នុង ទាំងក្រៅ បានដល់ៈ

- កាមាវចរចិត្តុប្បាទ ៥៤
- អភិញ្ញាកុសល.កិរិយា ២

* ឥស្សានិងអប្បមញ្ញាមានតែអារម្មណ៍ជាខាងក្រៅ

* អាកិញ្ចញ្ញាយតនៈ ៣ មានអារម្មណ៍បញ្ញត្តិមិនអាស្រ័យសភាវៈជា.តិកវិមុត្តក្នុងទីនេះ

* រូបនិងនិព្វានជាអនារម្មណ៍ ។

### សតិប្បដ្ឋាន

* សត្វលោកដែលអត់បញ្ញា ទោះបីខ្លាំងពូកែក្នុងលោកនេះយ៉ាងណាក៏ដោយ ក៏ជាអ្នកផ្គាប់ផ្គុននូវសត្វអាសិរពិស គឺការត្រេកអរនឹងធាតុ ៤ ដីទឹកភ្លើងខ្យល់ដែរ ។

* ទាស់តែស្តាប់គ្នាមិនបាន កុំអីហៅគ្នាថា ធាតុៗគឺសមមែនទែន ព្រោះម្នាក់ៗជាធាតុមាន ១៨ ធាតុ ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុជាដើម ។

* បុគ្គលភ្ញាក់អំពីដំណេកឡើងមិនបានឃើញនូវដើមឈើមាសដែលខ្លួនបានយល់សប្តិឃើញយ៉ាងណា កាមទាំងឡាយឧបមាដូចជាការយល់សប្តិ ព្រោះអ្វីៗដែលបានកន្លងទៅមិនមានតាំងនៅក្នុងទីណាឡើយ ឬថាកាមទាំងឡាយឧបមាដូចរបស់ខ្ចីគេ ដូច្នេះអ្នកខ្ចីគេគឺត្រូវតែព្រមសងទៅម្ចាស់កាមវិញគឺការមិនទៀង មិនត្រូវឃំស្តាយទេ ទឹកភ្នែកច្រើនពេកហើយ ។

* កាមទាំងឡាយឧបមាដូចដុំសាច់ជាសាធារណៈដល់សត្វដែលបរិភោគសាច់ទាំងឡាយ ។ កាមៈគឺវត្ថុកាមនិងកិលេសកាម រូបសំលេងក្លិនរសជាដើមជារបស់ទូទៅដល់វិញ្ញាណ ប៉ុន្តែសត្វលោកប្រកាន់ឈ្លោះប្រកាប់ប្រចាក់គ្នា ដើម្បីដណ្តើមកាម ទីបំផុតកាមត្រូវ

រឫតផុតធ្លាក់ចូលទៅក្នុងអតីតកាល កាមជាសមរភូមិ បរាជ័យ ជាជ្រោះមរណៈ ។

# ២២ _ តិកមាតិកានី ២២

## ១. សនិទស្សន សប្បដិឃា ធម្មា

ពួកធម៌ដែលអាចឃើញបានទាំងប៉ះខ្ទប់ក៏បានគឺ ប៉ះខ្ទប់នឹងចក្ខុបសាទបានដល់រូបារម្មណ៍ ។

* មិនមានរូបឯណា ១ ដែលគ្របសង្កត់ចិត្តបុរស ដូចជារូបស្ត្រីឡើយ ភិក្ខុអាចលាសិក្ខាបទ បុថុជ្ជនអាច ប្រព្រឹត្តបាបកម្មជាច្រើនយ៉ាង ។ សក់ស្អាត រោមក្រចក ធ្មេញស្បែកស្អាតៗគឺតាមរយៈវណ្ណរូបទាំងអស់ ។

* វណ្ណរូបជារូបក្ខន្ធជារូបាយតនៈ ជារូបធាតុជា ទុក្ខសច្ចៈ ជារូបតែម្យ៉ាងដែលគួរដល់ការឃើញ បុគ្គល សន្សំបារមីយូរអង្វែងណាស់ ទំរាំត្រាស់ដឹងនូវវណ្ណរូប នេះ ។

* មិនមែនឃើញដី ឃើញទឹក ឃើញភ្លើងនោះទេ វណ្ណរូបជាលោកនៃការរស់នៅក្នុងខណៈឃើញ វណ្ណៈដូចជាទឹកឃ្មុំលាយថ្នាំពិសម៉្យាង ជាផ្ទះរកប់វិញ្ញាណមនុស្សនិងទេវតា ។

* វណ្ណរូបជាសភាវៈសែនជ្រៅរហូតដល់ទៅគេសំគាល់ថា វាក់ៗ វាសមជាអន្ទាក់មារមែន ។

* មនុស្សលោកមិនមែនល្ងង់ខ្លៅគ្រប់ ១០នោះទេ ប៉ុន្តែព្រោះសេចក្តីប្រមាទទើបបានជាគ្រប់ ១០ បានន័យថា ការប្រមាទនាំអោយរអិលធ្លាក់ចូលក្នុងអន្លង់ឱឃៈដ៏ធំ ក្នុងបណ្តាសភាវធម៌ទាំងឡាយដែលសំរាប់អោយរអិល វណ្ណរូបក៏ជាប់ឈ្មោះមួយដែរ ។

## ២ - អនិទស្សនសប្បដិឃា ធម្មា

ពួកធម៌មិនអាចឃើញបានតែអាចប៉ះខ្ទប់បានបានដល់

- ឱឡារិករូប ១១ ( វៀរវណ្ណរូប )

* ការប៉ះខ្ទប់ក្នុងទីនេះគឺជាលក្ខណៈនៃបសាទរូប និងគោចររូប ។

## សតិប្បដ្ឋាន

* ឱឡារិករូបគឺជារូបគ្រោតគ្រាតងាយឃើញដោយបញ្ញា ជាងសុខុមរូប ។

* ឱឡារិករូប ១២ មានក្នុងជីវិតប្រចាំថ្ងៃ បសាទរូប ៥ គឺការថ្លានៃភូតរូបដូចកញ្ចក់គួរដល់ការប៉ះខ្ទប់នឹងរូបជាគូៗ គោចររូប ៧ គួរដល់ការប៉ះខ្ទប់នឹងបសាទរូបតាមវិស័យនៃរូបនិមួយៗ និងជាទីគោចរនៃបញ្ចវិញ្ញាណពិតៗ ។

* គោចររូបប្រៀបដូចជ្រុញ ចិត្តដូចដុំសាច់នៅលើជ្រុញកិលេសកាមប្រាថ្នាគោចររូបដូចកាំបិតចិញ្ច្រាំដុំសាច់ ។

* សតិរលឹកបាន មិនវង្វេងក្នុងគោចររូប ជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃ ជាថ្នាំព្យាបាលរបួសអោយ

ចិត្ត ។

* គោចររូប ៧ គឺ រូប ១ សំលេង ១ ក្លិន ១ រស ១ និងភូតរូប ៣ ជាផោដ្ឋព្វៈ គឺបថវីតេជោវាយោ ព្រោះផស្សៈជាប្រក្រតីរាល់ថ្ងៃទើបមានធម្មជាតិម្យ៉ាងសោយនូវរសនៃអារម្មណ៍ទាំងនេះហៅថា វេទនា ព្រោះការមិនដឹង មិនស្គាល់នូវវេទនាទាំង ៣ គឺសុខសោមនស្ស ១ ទុក្ខទោមនស្ស ១ និងឧបេក្ខា ១ សត្វលោកខំយកចិត្តទុកដាក់ចំពោះវេទនានេះ ដោយសំគាល់ថាជីវិតរបស់ខ្លួន គឺជាការសោយនូវអារម្មណ៍ ។

ការសួរសុខទុក្ខគ្នាទៅវិញទៅមកនៃមនុស្សលោកបញ្ជាក់អោយដឹងថាការសោយអារម្មណ៍នេះជាសភាវៈសំខាន់ ។

ព្រោះមិនកំណត់ដឹងនូវវេទនា ទើបមានបញ្ហវេរាក្នុងលោក ។

## ៣ - អនិទស្សនាប្បដិឃា ធម្មា

ពួកធម៌មិនអាចឃើញបានទាំងមិនអាចប៉ះខ្ទប់បាន គឺ ៖ ចិត្តចេតសិកសុខុមរូប និព្វាន ។

* មនុស្សលោកត្រេកអរណាស់ ព្រោះបានជារោគ គឺរួចអំពីជម្ងឺ ប៉ុន្តែបានជាភ្លេចថា បើកុំមានឈឺ - តើចាំបាច់អរនឹងជាធ្វើអ្វី ហើយព្រោះត្រេកអរចំពោះជាហ្នឹងឯងទើបទាស់ចិត្តជាមួយឈឺខ្លាចឈឺ ។

* សត្វលោកស្វែងរកការសប្បាយមកអំពីមានទុក្ខនិងល្ងង់ ។

* សេចក្តីទុក្ខក្បៀងប្រមូលសត្វលោកដែលល្ងង់ខ្លៅអោយទៅត្រេកត្រអាលនឹងសេចក្តីសុខ ។

* សុខក្នុងលោកនេះ មិនមែនព្រះពុទ្ធទ្រង់ពុំបានជ្រាបនោះទេ សេចក្តីសុខក្នុងពេលមុនចេញបួសឬសុខក្នុងទេវលោកព្រហ្មលោកទ្រង់ជ្រាបទាំងអស់តែពេលព្រះអង្គត្រាស់ដឹងហើយ ទ្រង់ប្រកាសថានិព្វាន

# អ្នកបរិច្ចាកប្រាក់ធ្វើធម្មទាន

១ សមាគម ធម្មិក សង្គហ ១២០០ក្បាល

២ លោក នរ មេត្តា និង លោកយាយ ឌួង គុយអេង

ឧបាសិកា គួរ ត្រង់ ព្រមទាំងបុត្រ

យុវជន ហេង ហៃ និង នរ ឥនចក្កវ៉ា ១០០០ក្បាល

បោះពុម្ពលើកទី៣ ចំនួន ២២០០ក្បាល

ភ្នំពេញ ព.ស ២៥៤០

ហាមលក់

ជាបរមសុខ ។

* ខន្ធ ៥ ជាទុក្ខ - តើព្រមហើយឬនៅ ?

* ខន្ធ ៥ ជាទុក្ខ - តើប្រកួតទៀតឬទេ ?

* ខន្ធ ៥ ជាទុក្ខ - តើធ្លាប់ឈ្នះដែរឬទេ ?

* ខន្ធ ៥ ជាទុក្ខ - តើស្រឡាញ់ទៀតឬទេ ?

* ខន្ធ ៥ ជាទុក្ខ - តើឈ្លោះគ្នាទៀតឬទេ ?

* ខន្ធ ៥ ជាទុក្ខ - តើនៅតែកាចឬទេ ?

* ខន្ធ ៥ ជាទុក្ខ - តើរាងហើយឬនៅ ?

* ខន្ធ ៥ ជាទុក្ខ តើនៅតែអញ្ញទៀតឬទេ ?

* ខន្ធ ៥ ជាទុក្ខ - តើចង់គ្រាន់បើទៀតឬទេ ?

* ខន្ធ ៥ ជាទុក្ខ - តើដណ្តើមគ្នាទៀតឬទេ ?

**និព្វានំ បរមំ សុខំ**

**ព្រះនិព្វានជាបរមសុខ**

**ចប់ភាគទី ១**

## នាមសប្បុរសជនដែលជួយក្នុងការបោះពុម្ពសៀវភៅនេះ

--------------

| | | |
|---|---|---|
| ឧបាសិកា | អៀប-ឆៃហុង | ៥០០ដុល្លា |
| " | សុខ-សាមឿន និង តាន់សម្បត្តិ | ៥០០ " |
| " | លឹម-ហ្គិកឆាយ លោកតាន់-សេងឈាង | ៣០០ " |
| " | ឃូ ស៊ីវ-ឃីម និង ជាយីកូវ | ៣០០ " |
| " | គុយ-ណារត្ន | ១៥០ " |
| " | អ៊ុម-ណូយ និង មាស់-សុដ្ឋាបូរី | ១៥០ " |
| " | ប៊ិន | ១០០ " |
| " | ប៉ែន-សួន | ៥០ " |
| " | ឡុង-ផាវណ្ណ | ៥០ " |
| លោក | សៅ-សារូប និងយ៉ែម-គីមណៃ | ៥០ " |
| លោក | ហ៊ន អ្នកស្រី ហោទន | ៥០ " |
| ឧបាសិកា | តាន់-ឡើយ | ៥០ " |
| ឧបាសក | ហោ-លាន អ្នកស្រី អួន-ឆឹង | ៥០ " |
| ឧបាសិកា | តាន់-គីម ប៉ាវ | ៥០ " |
| ឧបាសិកា | ឡុក-ឡូរ៉េត | ៥០ " |
| ឧបាសិកា | ប្រី-យ៉ុម | ៥០ " |
| លោក | ហត អ្នកស្រី ហេង-អ៊ឹម | ៣០ " |
| ឧបាសិកា | ភន-ស៊ាងហៃ | ៣០ " |

| | |
|---|---|
| ឧបាសិកាអៀប-ឆៃអៀម | ១០០ដុល្លា |
| នាង-ស | ១០០ដុល្លា |
| ឧបាសិកា ស្រង់-អៃ | ២០ " |
| ឧបាសិកា លាស់-ស៊ឹម លោក ទូច-សាន | ២០ " |
| ឧបាសិកា ខៀវ-សាន | ២០ " |
| ឧបាសិកា ថេង-មាន | ២០ " |
| ឧបាសិកា ថៅ- អាំង | ២០ " |
| ឧបាសិកា អួន-ញ៉ូ លោក ឆាយ-សាយ | ២១ " |
| លោក អ៊ូ-ឈុនគ្រេង | ២០ " |
| លោក ឈូ-និង ប៊ូរីណា | ២០ " |
| លោក ស៊ីវ-សុខ ហួង និង តូច-លាងហួ | ២០ " |
| លោក ភៀន-ង៉ា | ២០ " |
| ឧបាសិកា សាំង | ២០ " |
| ឧបាសិកា សេង-លាង | ១០ " |
| ឧបាសិកា គីម-អេងគង់ | ១០ " |
| ឧបាសិកា ឌិប-រះ | ១០ " |
| ឧបាសិកា ថៅ-ហួ | ១០ " |
| ឧបាសិកា ឃិន-ផ្លូ | ១០ " |
| ឧបាសិកា ប៊ូ-ធន | ១០ " |
| ឧបាសិកា លីម-គីមណៃ | ១០ " |
| ឧបាសិកា ម៉ឹង-ទូច | ១០ " |
| ឧបាសិកា សឿ-យ៉េត | ៦ " |

| | |
|---|---|
| ឧបាសិកា សុខ-ឡាង | ៥ " |
| ឧបាសិកា សន់-ហ៊ាង | ៥ " |
| ឧបាសិកា សុខ-ប៉ាច | ៥ " |
| ឧបាសិកា ឈ-គីមហោ | ៥ " |
| ឧបាសិកា គង់-សុគន្ធា | ៥ " |
| ឧបាសិកា ទូច-ធឿន | ៥ " |
| ឧបាសិកា ពៅ-ភួង | ៥ " |
| ឧបាសិកា ស្រី-យ៉ៃ | ៥ " |
| ឧបាសិកា ឡុង-ស៊ាងហេង | ៥ " |
| ឧបាសិកា ឡុង-ស៊ាងហ៊ន | ៥ " |
| ឧបាសិកា រស់-ហ៊ុម | ៥ " |
| ឧបាសិកា ឆៃឡា សារូ | ៥ " |
| យាយ សន តាសេង | ៥ " |
| ឧបាសិកា ឆែម-រ៉ប | ៥ " |
| ឧបាសិកា ម៉ម-សឿន | ៥ " |
| ឧបាសិកា អោម-ផុល | ៥ " |
| លោក នូ-នឿន អ្នកស្រី លន់ ហេង | ៥ " |
| លោក ចេ យឹន អ្នកស្រី ឡេង-គួយ | ៥ " |
| ឧបាសិកា សា-រី | ៥ " |
| ឧបាសក តាវ | ៥ " |

| | |
|---|---|
| ឧបាសិកា យ៉ាត-សុភី | ៥ " |
| ឧបាសិកា គង់-អាន | ៣ " |
| ឧបាសិកា ម៉ែន-រឿន | ៣ " |
| ឧបាសិកា ឈុំ-អូច | ២ " |
| ឧបាសិកា កែវ-មុន | ២ " |
| ឧបាសិកា ម៉ៅ-មឿន | ២ " |
| ឧបាសិកា នឹម | ២ " |
| កុមារី លិន ដា | ២ " |
| កុមារី សែម-ភក្រ | ២ " |
| អ្នកស្រី មុំ-សារ៉ាត់ | ១ " |
| ឧបាសិកា ចែម-ផង | ១ " |
| ឧបាសិកា ខី មាឡាង | ១ " |
| លោក វង-ឡូញ | ១ " |

# អារម្ភកថារបស់អ្នកបោះពុម្ពចម្លង

ខ្ញុំព្រះករុណាយើងខ្ញុំជាកូនសិស្ស របស់លោកគ្រូបណ្ឌិតធម្មាចារ្យទាំងអស់នៅសហរដ្ឋអាមេរិក មានសេចក្ដីជ្រះថ្លាចំពោះសៀវភៅជំនួយសតិ ភាគ១-ភាគ២ នេះ ហើយមានបំណងចង់បោះពុម្ពចម្លងចែកជាធម្មទាន ព្រោះហេតុច្នេះ យើងខ្ញុំទាំងអស់គ្នា សូមនូវសេចក្ដីអនុគ្រោះអំពីសំណាក់លោកគ្រូបណ្ឌិតធម្មាចារ្យ ដើម្បីយើងខ្ញុំបោះពុម្ពចម្លង ចែកជាធម្មទាន ហើយយើងខ្ញុំសូមឧទ្ទិសនូវមហាកុសលនេះប្រគេន និងជូនចំពោះបណ្ឌិត-ធម្មាចារ្យផង ដល់បុព្វការីជនរបស់យើងមានមាតាបិតា គ្រូឧបជ្ឈាយាចារ្យរបស់យើងខ្ញុំផង ដល់ពុទ្ធបរិស័ទទូទៅទាំងអស់ផង និងដល់ពពួកសត្វក្នុងត្រៃភពផង សូមបានអនុមោទនានូវមហាកុសលនេះ ឱ្យបានស្មើៗគ្នា ហើយសូមបាននូវសេចក្ដីសុខចុះ។

**បោះពុម្ពលើក ទី ៤ ចំនួន ២.០០០ក្បាល**

**ដើម្បីចែកផ្សាយជាធម្មទាន**

+ + +

*ថ្ងៃអង្គារ ១៥ កើត ខែភទ្របទ ឆ្នាំឆ្លូវ ព.ស.២៥៤១*

*ត្រូវនឹងថ្ងៃទី ១៦ ខែកញ្ញា ១៩៩៧*